ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Apr-2015, 16:00
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥**

**ម៉ោង ០៩:០៥នាទី**

**សវនាការលើកទី២៣៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ជា ស៊ីវហ័ង

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Maddalena GHEZZI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆវ័ន្ត

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

លោក ត្រាវីស ហ្វារ *(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សួន វិសាល

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉េន ពៅ

លោកស្រី ជេត វណ្ណលី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំច អរុណ

លោកស្រី ស្វ សុទ្ធាវី

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ត្រាវិស ហ្វារ | អង់គ្លេស |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក សួន វិសាល | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ជាំង ស្រីមុំ (2-TCW-834) | ខ្មែរ |
| លោក កែវ ច័ន្ទតាវ៉ា (2-TCW-964) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី ÷ លោកស្រី ជាំង ស្រីមុំ** (2-TCW-834)

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ....................................................ទំព័រ ៣

សួរដោយលោក គង់ សំអុន ផ្តើមពី ....................................................ទំព័រ ១០

**ការសួរសំណួរទៅសាក្សី ÷ លោក កែវ ច័ន្ទតារ៉ា** (2-TCW-964)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................................................ទំព័រ ២០

សួរដោយលោក ត្រាវិស ហ្វារ ផ្តើមពី ....................................................ទំព័រ ២៤

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ....................................................ទំព័រ ៥៣

សួរដោយលោក សួន វិសាល ផ្តើមពី ....................................................ទំព័រ ៥៦

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី....................................................ទំព័រ ៦៣

សួរដោយលោក គង់ សំអុន ផ្តើមពី ....................................................ទំព័រ ៨១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ជាំង ស្រីមុំ បញ្ចប់ ហើយនិងចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-964។

ក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះបានកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការក្នុងថ្ងៃនេះក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ លើកលែងតែលោក អាកទូរ វែកគែន មេធាវីអន្តរជាតិការពារក្តីឱ្យលោក ខៀវ សំផន អវត្តមានដោយសារមូលហេតុសុខភាព។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅក្នុងថ្ងៃនេះដែរ គឺលោកស្រី ជាំង ស្រីមុំ លោកស្រីមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ រីឯសាក្សីបន្ទាប់ដែលត្រូវមកផ្តល់សក្ខីកម្ម បន្ទាប់ពីលោកស្រី ជាំង ស្រីមុំ គឺសាក្សីដែលមានរហស្សនាម 2-TCW-964 សាក្សីបានបញ្ជាក់ថាតាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីរូបនេះបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ ហើយសាក្សីនឹងមានវត្តមាននៅបន្ទប់រង់ចាំ ៗការកោះហៅពីអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

[០៩:០៧:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ឥឡូវនេះ អង្គជំនុំជម្រះមុននឹងបន្តកិច្ចដំណើរការនីតិវិធីសវនាការ ទី១ អង្គជំនុំជម្រះសម្រេចលើសំណើរសុំរបស់លោក នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ នួន ជា ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ដែលបញ្ជាក់ថាដោយមានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន ហើយមិនអាចផ្តង់អារម្មណ៍បានយូរ ហើយដើម្បីមានលទ្ធភាពចូលរួមសវនាការនាពេលអនាមុខ នាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ហើយខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ហើយគាត់ បានប្រាប់ថាមេធាវីការពារក្តីរបស់គាត់បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់ក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់នឹងភស្តុតាងក្នុងការបង្ហាញឬដាក់ជូនតុលាការនេះគ្រប់ពេលនៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៨:៥៥]

ហើយបានឃើញហេតុ -- កំណត់ហេតុពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពរបស់ជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០១៥ បានកត់សម្គាល់ថាស្ថានភាពសុខភាពរបស់ នួន ជា នៅថ្ងៃនេះមានអាការៈឈឺចង្កេះជាប្រចាំ ហើយគាត់មិនអាចអង្គុយយូរ និងយូរបាន។ ហើយនិងបានផ្តល់អនុសាសន៍ថាសូមអង្គជំនុំជម្រះអនុញ្ញាតឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ហើយដោយផ្អែកលើមូលដ្ឋាននេះ និងយោងបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យលោក នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សសន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះសូមដំណឹងដល់ភាគីថា នៅក្នុងការអនុវត្តនាបច្ចុប្បន្ននេះ អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ គឺបានពន្យល់ណែនាំត្រួតៗដល់សាក្សីទាំងឡាយមុនពេលពួកគេមានវត្តមាននៅសាលសវនាការ ហើយទន្ទឹមនឹងពេលនោះដែរ អង្គភាពគាំពារសាក្សីនិងអ្នកជំនាញក៏បានពន្យល់ដល់សាក្សីអំពីវិធានការការពារផងដែរ។ រាល់បញ្ហាទាំងឡាយដែលកើតមានឡើងនៅក្នុងអំឡុងពេលនៃការពន្យល់ណែនាំនោះត្រូវជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង ដោយហេតុថានៅក្នុងសំណុំរឿង០០២/០២នេះ អាចនឹងមានសាក្សីផ្សេងៗទៀត ដែលត្រូវមានវិធានការពិសេស ដែលរួមមានការធ្វើសវនាការជាអសាធារណៈផ្អែកតាមលក្ខណៈនៃបទល្មើសដែលបានចោទប្រកាន់ ហើយជាពិសេសអំពើហិង្សាផ្លូវភេទ។ អង្គជំនុំជម្រះសាលាដំបូងបានណែនាំឱ្យអង្គភាពគាំពារសាក្សីនិងអ្នកជំនាញជម្រាបឱ្យបានច្បាស់លាស់ដល់សាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចមានការបារម្ភពីបញ្ហាបែបនេះថាអាចមានវិធានការនានាអនុលោមតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និងមាត្រា៣១៦នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងនោះរួមមានសវនាការជាអសាធារណៈ នៅពេលមានការអនុញ្ញាត។

អង្គជំនុំជម្រះសាលាដំបូងសូមឱ្យភាគីទាំងអស់ជម្រាបដល់អង្គភាពគាំពារសាក្សីនិងអ្នកជំនាញឱ្យបានដឹងជាមុនអំពីការបារម្ភនានាដែលអាចកើតមានឡើងពាក់ព័ន្ធនឹងបញ្ហានេះមុនពេលស្តាប់សក្ខីកម្មសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលមានការពាក់ព័ន្ធ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី ជាំង ស្រីមុំ។ សូមអញ្ជើញ!

លោក នួន ជា -- លោកៗ វ៉ិចទ័រ កូប៉េ។ បាទ សួមជម្រាបថាលោកមេធាវីទាំងពីរក្រុមមានពេលវេលាមួយពីនេះទៅរហូតដល់សម្រាកនៅព្រឹកនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ក្រុមមេធាវីការពារក្រុម ខៀវ សំផន បានផ្តល់ពេលវេលាក្រុមគាត់ឱ្យក្រុមយើងខ្ញុំ ១៥នាទី។ ដូច្នេះ ខ្ញុំសូមបន្តសួរសំណួរទៅសាក្សីទៀត លោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី ខ្ញុំសុំបង្ហាញឯកសារមួយជូនទៅលោកស្រី នៅលើអេក្រង់។ ខ្ញុំសុំឱ្យ

យោងទៅឯកសារ E3/1398, ERN អង់គ្លេស 00814500, ខ្មែរ 00065933។ បាទគឺទំព័រទី១នៃឯកសារដែលសុំបង្ហាញនេះ តើលោកស្រីមានឃើញឯកសារនេះនៅលើអេក្រង់ទេ?

លោកស្រី តើលោកមានឃើញឯកសារនេះនៅលើអេក្រង់ទេ?

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស បានឃើញ។

**ស៖** លោកស្រីចាំឯកសារនេះបានទេ? ស្គាល់ឯកសារនេះទេ?

**ឆ៖** ចាស បានឃើញ ប៉ុន្តែមិនសូវចាំ។

[០៩:១៥:០៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំក៏មិនបានឃើញឯកសារនេះនៅលើអេក្រង់ដែរ ប្រសិនណាជាមេធាវីការពារក្តីសុំសួរសាក្សីឱ្យកំណត់អត្តសញ្ញាណឯកសារនេះ គាត់គួរណាស់តែផ្តល់ទាំងឯកសារជាក្រដាស និងឯកសារបង្ហាញលើអេក្រង់នោះផងដើម្បីផ្ទៀងផ្ទាត់គ្នា។

**លោក វ៉ិចទ័រ កូប៉េ៖**

ដោយសារខ្ញុំចង់សន្សំសំចៃតាំងពីឯកសារអីទាំងអស់នេះ ដូច្នេះហើយខ្ញុំអត់បានថតចម្លងយកមក១ឱ្យសាក្សីទេ ប៉ុន្តែខ្ញុំនឹងព្យាយាមធ្វើតាមសំណើរបស់សហព្រះរាជអាជ្ញា។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិយកទៅជូនសាក្សីពិនិត្យ។ ឯកសារជាក្រដាស។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំក៏សុំការអនុញ្ញាតចង់ឃើញឯកសារនេះនៅលើអេក្រង់ដែរ ខ្ញុំអត់មាននៅលើអេក្រង់របស់ខ្ញុំដែរ។

**ប្រធានអង្គជំនុំ៖**

ទី១ អង្គជំនុំជម្រះអនុញ្ញាត។ ទី២ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយ នឹងអ្នក

បច្ចេកទេស អាយ.ធី ក្នុងការធ្វើយ៉ាងម៉េចឲ្យប្រព័ន្ធនៃការបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រហ្នឹង បានឃើញគ្រប់ភាគីដែលពាក់ព័ន្ធ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី ខ្ញុំសូមបន្តសួរសំណួរ។ ខ្ញុំឮសួរលោកស្រីនិយាយថា លោកស្រីស្គាល់ឯកសារនេះតែចាំវាមិនបានច្បាស់លាស់ទេ។ ដូច្នេះសូមឲ្យលោកស្រីឆ្លើយបញ្ជាក់ឲ្យបានលម្អិតជាងនេះបន្តិចមើល។

[០៩:១៧:២១]

**លោកស្រី ជាង ស្រីម៉ុំ៖**

**ឆ៖** ចាស សុំទោសនៅក្នុងឯកសារនេះ ខ្ញុំអត់ដែលបានស្គាល់ បាននេះ -- ឃើញនៅពេលនៅក្នុងអេក្រង់ពេលហ្នឹង ចាស ពីមុនមកដូចថា អត់ដែលឃើញ ខ្ញុំអត់។

**ស៖** ពីខាងដើមលោកស្រីបានផ្ដល់សក្ខីកម្មមកថា លោកស្រីគឺជាគ្រូបង្រៀន ៗកុមារៗឲ្យចេះអានចេះសរសេរ។ លោកស្រីចាំទេនៅពេលស្រីធ្វើជាគ្រូបង្រៀន លោកស្រីបានប្រើឯកសារដូចឯកសារដែលខ្ញុំស្នើសុំអង្គជំនុំជម្រះបង្ហាញជូនលោកស្រីអ៊ីចឹង លោកស្រីចាំទេ?

**ឆ៖** ចាសលោក ការចងចាំមិនបានចាំទេ។ កាលខ្ញុំបង្រៀន មិនមានឯកសារច្បាស់លាស់ទេ។ វាគ្រាន់តែរៀនដោយពាក្យ។

**ស៖** ដូច្នេះលោកស្រីមិនបានប្រើសៀវភៅកម្មសិក្សា គឺឯកសារនេះធ្វើជាកម្មសិក្សាបង្រៀនទេ មែនទេ?

**ឆ៖** ចាស អត់មានសៀវភៅច្បាស់លាស់។

**ស៖** សូមលោកស្រីប្រាប់កាលបរិច្ឆេទឲ្យបានច្បាស់លាស់ថ្ងៃខែឆ្នាំណាដែរ ដែលលោកស្រីចាប់ផ្ដើមធ្វើជាគ្រូបង្រៀន ក្រោយថ្ងៃ១៧ មេសា ១៩៧៥នោះ?

[០៩:១៩:៣៩]

**ឆ៖** ចាស ខ្ញុំមិនដឹងកាលបរិច្ឆេទច្បាស់លាស់ទេ គ្រាន់តែនៅដឹងនៅឆ្នាំខ្លះ ឆ្នាំ១៩៧៥-៧៦។ ការបង្រៀននោះគឺមិនមានបានជិតដល់ទេ គ្រាន់តែថែទាំកុមារ និងបាយទឹក និងបាយទឹក និងជួយដឹកនាំកុមារធ្វើពលកម្មតែប៉ុណ្ណោះ។ ការបង្រៀននោះជាជំនួយការក្នុងមួយថ្ងៃៗ ដែលគ្រូប្រចាំថ្ងៃហ្នឹង គេមានវត្តមានទៅណាៗអ៊ីចឹងទៅ។ អ៊ីចឹងខ្ញុំគ្រាន់តែជំនួយការ ដែលក្នុងពេលមួយថ្ងៃៗតែប៉ុណ្ណឹងចាស។

**ស៖** តើលោកស្រីធ្លាប់និយាយ -- អ៊ីចឹងសំណួរសួរឲ្យចំ ថាតើគេបង្រៀនស្អីទៅដល់កុមារៗទាំងនោះ?

**ឆ៖** ចាស ក្នុងនោះរៀន ចាប់ផ្តើមបង្រៀនកុមារ គឺកុមារតូចៗចាប់រៀនប្រកបជាអក្សរប្រកបអ៊ីចឹង ហើយជាពិសេសបង្ហាត់នូវចម្រៀងសិល្បៈ។ ក្រោយពីចម្រៀងសិល្បៈ ដឹកនាំកុមារធ្វើពលកម្មតែប៉ុណ្ណឹង។

**ស៖** តើលោកស្រីធ្លាប់ឮគ្រូបង្រៀនដទៃៗ បង្រៀនប្រធានបទស្តីអំពីជាតិកម្ពុជា នៅចន្លោះឆ្នាំ ៧៥-៧៦ ដែរឬទេ? តើអ្នកណាខ្លះជាៗអ្នកស្ថិតនៅចំណុះឲ្យហៅថា“ជាតិកម្ពុជា”នោះ?

**ឆ៖** សូមទោស ខ្ញុំស្តាប់សំណួរមិនសូវយល់។

**ស៖** បាទ ខ្ញុំរៀបសំណួរឡើងដើម្បីឲ្យវាច្បាស់លាស់។ ដោយសារពេលវេលាខ្ញុំខ្លីផង តើលោកស្រីធ្លាប់ឮគ្រូដទៃទៀតបង្រៀនកូនសិស្ស ដែលសំដៅថា “ជាតិកម្ពុជា” សំដៅទៅលើគ្រប់ជាតិសាសន៍គ្រប់ជាតិពន្ធុទាំងអស់។ មានន័យថាជនជាតិភាគតិចអីអ្វីក៏ដោយទាំងអស់។ លោកស្រីធ្លាប់ឮគេបង្រៀនពីប្រធានបទហ្នឹងទេ?

**ឆ៖** ចាស ចំពោះគ្រូផ្សេងៗដែលគេបង្រៀន ពេលនៅបង្រៀនខ្ញុំមិនសូវ -- ព្រោះអីការបង្រៀនគេមានកន្លែងផ្សេង ៗអ៊ីចឹងខ្ញុំ ហាក់បីដូចខ្ញុំមានភារកិច្ចផ្សេងទៅ ការគេបង្រៀនខ្ញុំអត់បានស្តាប់នូវអត្ថន័យការបង្រៀនរបស់គេ។ ចាស សូមទោសតែប៉ុណ្ណឹង។

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំសូមចូលទៅប្រធានបទចុងក្រោយរបស់ខ្ញុំ គឺប្រធានបទអំពីការរៀបការរបស់លោកស្រី។ តើលោកស្រីធ្លាប់ឮនៅក្នុងវគ្គអប់រំរៀនសូត្រ កិច្ចប្រជុំណាមួយ ឬក៏មានគោលការណ៍ណែនាំណាពីអង្គការទាក់ទងទៅនឹងការកសាងសង្គមគ្រួសារ? តើលោកស្រីធ្លាប់ឮទេ?

[០៩:២៣:៣៦]

**ឆ៖** ចាស ពេលខ្ញុំរៀបការ គឺខ្ញុំមិនបានទទួលការអប់រំពីអ្នកដឹកនាំ ពេលយើងរៀបចំគ្រួសារទៅ មានអនាគតកសាងយ៉ាងម៉េចៗ ពេលខ្ញុំរៀបអាពាហ៍ពិពាហ៍ហ្នឹង គឺអត់បានទទួលការអប់រំទេ។

**ស៖** ដូច្នេះ គេមិនដែលជួបប្រជុំ ឬក៏មានការទាក់ទងមកអ្នកស្រីតាមមធ្យោបាយណាមួយទៀតដែលប្រាប់លោកស្រីអំពីរបៀបជ្រើសរើសគូស្រករដែរឬទេ?

**ឆ៖** ចាស ពីមុនមក មុននឹងការខ្ញុំរៀបចំ គឺការចូលរួមប្រជុំ គេតែងតែលើកឡើងថាយើងម្នាក់ៗគឺប្តេជ្ញាប្រគល់ខ្លួនជូនអង្គការ។ អ៊ីចឹងយើងម្នាក់ៗជាកូនអង្គការ។ អ៊ីចឹងបើអង្គការចាត់តាំង

ឬទៅធ្វើកងទ័ព ឬទៅធ្វើអ្វីមួយ គឺយើងមិនត្រូវប្រឆាំងនឹងបក្សទេ ព្រោះអីយើងម្នាក់ៗយើងជូន -- ប្រគល់ខ្លួនជូនអង្គការហើយ។ អ៊ីចឹងតែអង្គការចាត់តាំងទៅណា គឺយើងត្រូវតែធ្វើតាមអង្គការ។ ចាស ការប្រជុំមានប៉ុណ្ណឹង ហ្នឹងខ្ញុំចាំតែចំណុចសំខាន់របស់ខ្ញុំតែប៉ុណ្ណឹងទេ វាមានពាក្យច្រើនដែរ ប៉ុន្តែខ្ញុំវាមានការភ្លេចភ្លាំងអស់ហើយ វារាប់ឆ្នាំមកហើយចាស។

**ស៖** តើលោកស្រីធ្លាប់បានឮអង្គការនិយាយក្នុងពេលប្រជុំ ឧទាហរណ៍ថា កុំជ្រើសរើសគូស្រករដោយលេងៗ ជ្រើសរើសសើៗ ហើយគឺថាជាការចាំបាច់ត្រូវជ្រើសរើសអ្នកណាម្នាក់ដែលមានគោលជំហរបដិវត្តន៍រឹងមាំ។ តើលោកស្រីធ្លាប់ឮសួរអង្គការនិយាយអំពីរបៀបជ្រើសរើសប្ដីប្រពន្ធហ្នឹងទេ?

**ឆ៖** ចាស ការជ្រើសរើសប្ដីប្រពន្ធ ខ្ញុំមិនដែលបានស្ដាប់ ទទួលការណែនាំអី គឺការប្ដីប្រពន្ធ គឺសម្រេចអ៊ីចឹងតែម្ដង គឺរៀបចំខាងថ្នាក់លើអ្នករៀបចំ គឺអត់មានប្រកាសថា អូ្ហ! អ្នកនេះគូជាអ្នកនេះ អ្នកនេះគូជាមួយអ្នកនោះទេ។ ដល់តែពេលនៅក្នុងកម្មវិធី ហ្នឹងបានចូលមកប្រកាសៗ តែពីមុនមកអត់មានប្រាប់ថា ហ្នឹងចំពោះខ្លួនខ្ញុំផ្ទាល់ពីមុនមកអត់មានប្រាប់ថា អូ្ហ! ថ្ងៃនេះត្រូវថ្ងៃរៀបការនៅថ្ងៃទីប៉ុន្មានៗ អ៊ីចឹងរៀបការនេះត្រូវរើស សម្រេចចិត្តឱ្យរើសខ្លួនឯងក៏អត់មានដែរ នេះគឺសម្រេចចិត្តនៅលើអង្គការថ្នាក់លើអ្នករៀបចំចាស។ អ្នករៀបចំហើយ គឺដល់តែពេលថ្ងៃរៀបការ គឺៗហៅមកគឺក៏ឥតមានបញ្ជាក់ថាថ្ងៃនេះរៀបការដែរ ដល់ទៅហើយប្រាប់ថាកម្មវិធីរៀបការ ប្រកាសឈ្មោះតែម្ដង។ ខ្ញុំមិនដែលបានចូលរួមប្រកាស ឬមួយឱ្យជ្រើសរើសដោយខ្លួនឯងអត់មានទេ។

[០៩:២៧:២១]

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ។ លោកស្រីសាក្សី ប្រហែលជាខ្ញុំយល់មិនបានច្បាស់ដោយសារខ្ញុំមកពីប្រទេសផ្សេង។ ប៉ុន្តែដូចៗលោកស្រីបានឆ្លើយពីមកហើយ គឺថាលោកត្រូវបានអង្គការរៀបការឱ្យដែលមាន -- គឺៗក្រោយ៧៩ –០៧ មករា ៧៩ ក៏លោកស្រីនៅតែរួមរស់ជាមួយគ្នាដដែល ហើយមានកូនមានចៅ។ លោកស្រីអាចពន្យល់ជូនអង្គជំនុំជម្រះថា លោកស្រីគឺមិនបានជ្រើសរើសយកប្ដីលោកស្រីនោះធ្វើជាគូស្រករទេ តែខាងប្ដីលោកស្រីទេដែលបង្ខំឱ្យលោកស្រីវិញ។ តើអ៊ីចឹងដែរឬអត់?

**ឆ៖** ចាស ខ្ញុំសូមបញ្ជាក់ថា ចំពោះរូបខ្ញុំ ចំពោះប្ដីរបស់ខ្ញុំក៏អត់មានបង្ខំដែរ ប៉ុន្តែគឺសម្រេចចិត្តដាក់ខ្លួន ដាក់ចិត្ត បើកាលនោះគឺអង្គការគឺសម្រេចតែរៀបចំទៅលើអ្នកណាមួយហើយ គឺយើងអត់មានប្រឆាំងជាមួយបក្សបានទេ ទោះបីតែយើងមិនពេញចិត្តយ៉ាងណាក៏ដោយ ក៏យើងត្រូវតែសម្រេចចិត្ត

សម្រួមចិត្តនូវការក្នុងការភ័យខ្លាចរហូត ការស្រឡាញ់គ្នា មិនស្រឡាញ់គ្នា ក៏ត្រូវតែស្រឡាញ់ដែរពេលហ្នឹង។ តែយើងដាក់ចិត្តថារួមជាមួយក្នុងគ្រួសារមែនពិត ប៉ុន្តែចិត្តវាមានអត់ទាន់ចិត្តស៊ីសង្វាក់គ្នា ចំពោះប្ដីរបស់ខ្ញុំក៏អ៊ីចឹង ចំពោះខ្ញុំក៏អ៊ីចឹងដែរ។ ប៉ុន្តែនៅក្នុងការភ័យខ្លាចត្រូវតែដាក់ចិត្តនៅក្នុងពេលហ្នឹង បើកាលណាយើងមិនស្របទៅតាមការចាត់តាំងរបស់បក្សទេ គឺខ្ញុំដឹងប្រាកដថា ខ្ញុំមានគ្រោះថ្នាក់ដល់ជីវិត ព្រោះអីគ្រួសារខ្ញុំជាអ្នកពាក់ព័ន្ធ។ អ៊ីចឹងក្នុងការគេតាមដានកំហុសរហូតចាស។ ព្រោះអីពាក្យស្លោកមួយគេថាហើយ តែដករំលើងទាំងគល់ -- "កាប់ទាំគល់ រំលើងទាំងឫស"។ អ៊ីចឹងខ្ញុំប្រៀបដូចជាឫសអ៊ីចឹង ព្រោះអីឪពុកខ្ញុំជាគល់ត្រូវស្លាប់ អ៊ីចឹងខ្ញុំជាឫស ថ្ងៃណា -- អ៊ីចឹងគេត្រូវក្នុងការតាមដានរហូតឲ្យតែមានចំណុចគេថា អ្នកហ្នឹងនៅតែប្រឆាំងនឹងបក្ស។ អ៊ីចឹងគេថា ខ្ញុំហ្នឹងជាមនុស្សសងសឹកឪពុក។

[០៩:២៩:៤៧]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រីសាក្សី ខ្ញុំអស់សំណួរហើយ។ លោកប្រធានសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ឈប់អាល បង្អង់បន្តិចសិនលោក គង់ សំអុន!

សូមអញ្ជើញលោក ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

ដើម្បីឲ្យមានការកត់ត្រាត្រឹមត្រូវនៅក្នុងប្រតិចារឹកសវនាការ ខ្ញុំសូមបញ្ជាក់ថា លើកលែងតែខ្ញុំច្រឡំនោះ កាលពីព្រឹកមិញមានការបង្ហាញឯកសារមួយជូនទៅសាក្សីដែលមានលេខ E3/1398 ហើយលោក កូប៉េ ឯកសារនេះត្រូវបានចុះផ្សាយនៅឆ្នាំ១៩៧៧ បើខ្ញុំមិនច្រឡំទេ។ តើត្រូវទេលោកមេធាវី កូប៉េ? អ៊ីចឹងមែនទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនដឹងថា ខ្ញុំទទួលបានការបកស្រាយឯកសារ E3/1398 បាទ។ និយាយអំពីការបង្រៀននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការបោះពុម្ពផ្សាយលើកទី១ នៅក្នុងឆ្នាំ១៩៧៧។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកមេធាវី ខ្ញុំចង់ដឹងតែប៉ុណ្ណឹងទេ ដើម្បីកត់ត្រាក្នុងប្រតិចារឹកសវនាការ។

អរគុណហើយលោក។

[០៩:៣១:៣០]

**លោក វ៉ិចទ័រ កូប៉េ៖**

ដើម្បីប្រតិចារឹក លោកប្រធាន គឺសំណួរដែលខ្ញុំបានសួរ និយាយអំពីលទ្ធភាពនៃការជ្រើសរើសគូស្រករទាក់ទងទៅនឹងឯកសារនេះ ខ្ញុំមិនបានដាក់ចូលទៅក្នុង*អ៊ីនធីហ្វេស*ទេ ប៉ុន្តែមាននៅលើឯកសារគឺ E3/77 -- បាទសុំកែប្រែគឺ E3/775។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំគ្រាន់តែសុំពិនិត្យថាតើឯកសារដែលមេធាវីការពារក្តីទៅបញ្ជាក់ហ្នឹងវាត្រឹមត្រូវដើម្បីប្រតិចារឹក ឬក៏អត់? តាមដែលខ្ញុំដឹងគឺវាចេញមកពីទង់បដិវត្ត ឬក៏ទង់យុវជនបដិវត្ត ដែលបក្សកុម្មុយនីស្តកម្ពុជាបានចែកទៅឲ្យកម្មាភិបាលតាមមូលដ្ឋាននោះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

សុំអធ្យាស្រ័យ គឺខ្ញុំមិនដឹងថាវាជាការសារភាព ឬក៏វាជាអ្វីមួយនោះទេ យើងមិនដឹងដោយរបៀបណាទេ។

**លោក ឌេល លីសាក់៖**

លោកប្រធាន?

[០៩:៣៣:០០]

**ប្រធានអង្គជំនុំ៖**

ឈប់សិន! ឥឡូវនិយាយឲ្យច្បាស់លាស់មើល៍ ហើយអាចសរុបពេលវេលាមើល៍និយាយតែម្តងបានទេ? ការនិយាយហាក់ដូចជាទៅជាការរំខានកិច្ចដំណើរការនីតិវិធីជឿនលឿនមួយ។ គប្បីលើកអង្គហេតុនេះឲ្យច្បាស់លាស់ ហើយបង្ហាញពីហេតុផលនៃការកត់សម្គាល់របស់ខ្លួនរៀងៗខ្លួនឲ្យបានច្បាស់លាស់ ហើយភាគីមួយគួរតែនិយាយតែម្តងទៅបានហើយ។ មិនមែនដូចប៉ុស្តិ៍វ៉ាដ្ឋ មួយចុច មួយព្

ងើប ងើបហើយមួយអង្គុយៗអ៊ីចឹងទេ អាចដល់ស្អែកទៀតក៏ប្រហែលជាមិនអាចទៅមុខរួចដែរ។ យើងមិនគប្បីប្រើប្រាស់ជ្រែកជ្រៀតពេលវេលានាំឲ្យរំខានដល់សាក្សីនេះ អាចសាក្សីនេះឈានដល់ម៉ោងទី២ ឬក៏អាចឈានដល់ល្ងាចទៀត។ អ៊ីចឹង សាក្សីក្រោយនោះអាចបន្តទៅថ្ងៃខានស្អែកទៀត អ៊ីចឹងស្អែកគាត់ត្រូវត្រឡប់ទៅផ្ទះ។ នេះនីតិវិធីមិនដឹងជាថាយើងដោះស្រាយបញ្ហាយ៉ាងម៉េចទេ។ អាចគិតផងដែរថា តើប្រសិនបើខ្លួនយើងជាសាក្សីដែលត្រូវមកផ្តល់សក្ខីកម្ម ទៅហើយមកវិញៗរបៀបនេះ តើវាមានសតិអារម្មណ៍យ៉ាងម៉េចដែរ បើសិនជាខ្លួនយើងជាសាក្សីដែលត្រូវកោះហៅក្នុងមកផ្តល់សក្ខីកម្មដែលកំណត់តែមួយថ្ងៃ ហើយមកដល់បួនប្រាំលើកនេះ ជាមួយអង្គជំនុំជម្រះនេះ?

សូមអញ្ជើញ! និយាយឲ្យច្បាស់លាស់ទៅ ហើយតែម្តងទៅបានហើយ! គិតឲ្យហើយ ហើយនិយាយឲ្យច្បាស់លាស់តែម្តងឲ្យចប់តែម្តង ហើយភាគីម្ខាងទៀតអាចឆ្លើយតបតែម្តងជាការកត់សម្គាល់ ឬក៏ត្រូវឆ្លើយតប ឬក៏ត្រូវអង្គជំនុំជម្រះសម្រេច។

[០៩:៣៤:៣២]

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន គឺខ្ញុំសុំឆ្លើយតបទៅនឹងបញ្ហាដែលមេធាវីការពារក្តីលើកឡើង។

ចំណុចរបស់ខ្ញុំថា បើសិនណាជាយើងស្នើសុំបង្ហាញភស្តុតាងចេញពីឯកសារហ្នឹង យើងត្រូវតែប្រាប់ជាមុនឲ្យហើយថា តើវាចេញមកពីទង់បក្ស – ឯកសារទង់បដិវត្ត ដែលយកមកប្រើប្រាស់ចំពោះមុខតុលាការ ដែលបក្សកុម្មុយនីស្តកម្ពុជាបានចែកទៅសមាជិករបស់បក្ស។ នេះគឺជាអ្វីមួយដែលខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ដើម្បីប្រតិចារឹក ដូចដែលមេធាវីការពារក្តីបានកំណត់អត្តសញ្ញាណឯកសារនេះរួចមកហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការកត់សម្គាល់នេះ។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណលោកប្រធាន សូមគោរពអង្គជំនុំជម្រះ។ សូមជម្រាបសួរអ្នកស្រី ជាំង ស្រីមុំ ខ្ញុំបាទមានសំណួរមួយចំនួនដើម្បីសួរបន្តពីភាគីដែលបានតាំងសំណួរកន្លងមក។ ខ្ញុំចង់សួរបញ្ជាក់ទៅលើទីតាំងនៃសាកសួរយកកំណត់ហេតុរបស់អ្នកស្រី ថាតើអ្នកស្រីបានឆ្លើយចំពោះមុខការិយាល័យចៅក្រមស៊ើបអង្កេតនៅភូមិឫស្សី ឬក៏នៅភូមិកំសី? ពីព្រោះខ្ញុំឃើញមានភាពផ្ទុយគ្នារវាងចម្លើយរបស់

អ្នកស្រីនៅក្នុងសវនាការនេះ ហើយនិងនៅក្នុងកំណត់ហេតុ អ្នកស្រីអាចបញ្ជាក់បានទេថាតើទីតាំងពិតប្រាកដនៅកន្លែងណា?

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស ទីតាំងច្បាស់លាស់ គឺចាស ពេលព្រឹកនៅធ្វើកំណត់ហេតុហ្នឹងនៅពេលព្រឹកនៅភូមិកំសី ចាស ដល់ក្រោយមកថ្ងៃបញ្ចប់នៅធ្វើនៅផ្ទះខ្ញុំនៅភូមិឫស្សីស្រុក ចាស។

**ស៖** បាទ សូមអរគុណ។ ខ្ញុំបាទសូមសួរបញ្ជាក់បន្ថែមទាក់ទងនឹងការងាររបស់អ្នកស្រីមុនពេលអ្នកស្រីប្ដេជ្ញា គឺនៅពេលអ្នកស្រីបានជម្រាបអង្គជំនុំជម្រះថាអ្នកស្រីធ្វើជាគ្រូបង្រៀន ហើយក្រោយមកថាជាជំនួយការគ្រូបង្រៀន។ អ្នកស្រីអាចចាំរយៈពេលដែលអ្នកស្រីធ្វើការជាគ្រូបង្រៀន ឬជំនួយការគ្រូបង្រៀននោះទេ ថារយៈពេលប៉ុន្មានឆ្នាំ ឬប៉ុន្មានខែ?

[០៩:៣៧:២៩]

**ឆ៖** ចាស ខ្ញុំមិនសូវបានចាំច្បាស់លាស់ទេ ប៉ុន្តែខ្ញុំពេលខ្ញុំនឹកឃើញ ខ្ញុំនៅអង្គភាពកុមារហ្នឹងឆ្នាំ -- ឆ្នាំ១៩៧៦។ ពេលឆ្នាំ១៩៧៧ ខ្ញុំត្រូវរៀបការចាស។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចបញ្ជាក់ថារយៈពេលដែលអ្នកស្រីធ្វើការហ្នឹងលើសពីមួយឆ្នាំ ក្រោមពីរឆ្នាំ តើអ៊ីចឹងបានទេ?

**ឆ៖** ចាស បើសរុបទៅប្រហែលជាពីរឆ្នាំ។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីមានសហការីប៉ុន្មាននាក់ដែរដែលធ្វើការក្នុងអង្គភាពកងកុមារនោះ?

**ឆ៖** ចាស សហការីហ្នឹងមិនសូវបានចាំច្បាស់ទេ ពី១០នាក់ចុះមកក្រោម ប្រហែលជាប៉ុណ្ណឹង ចាស ខ្ញុំវាភ្លេចដែរហើយវាដូចថាការវាអត់បានកត់ទុក វាមិននឹកស្មានថាមានអ្វីកើតឡើងខាងមុខចាស។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចចាំបានទេថានរណាជាមេកង?

**ឆ៖** ចាស ផ្នែកប្រធាននារីកង គឺឈ្មោះ--

**ស៖** សូមទោសអ្នកស្រី គឺនិយាយអំពីមេកងកុមារ ខ្ញុំកំពុងតែនិយាយអំពីមេកងកុមារបាទ។

**ឆ៖** ចាសមេកងកុមារឈ្មោះ ប៉ុន ឈ្មោះអីប៉ុនទេភ្លេចហើយ ចាំតែឈ្មោះ ប៉ុន។

**ស៖** មានរចនាសម្ព័ន្ធម៉េចដែរ មានអនុប្រធាន មានសមាជិក ឬក៏អ្នកទទួលខុសត្រូវយ៉ាងម៉េចអ្នកស្រីអាចជម្រាបបានទេ?

**ធ៖** ចាស ខ្ញុំអត់ដឹងច្បាស់ដែរ ដឹងតែឈ្មោះ ប៊ុន ហ្នឹងជាអ្នកឱបក្តាប់រួម តែក្រោមៗហ្នឹងទៀត មានតែអ្នកដឹកនាំកុមារៗហ្នឹងតែម្តង តែចំពោះឈ្មោះ ប៊ុន ហ្នឹង គេឱបរួមម្តង ឱបក្តាប់រួម ចាស។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចបញ្ជាក់អំពីតួនាទីជាក់លាក់របស់អ្នកស្រី ដែលនិយាយ បើសិនជាអ្នកស្រីមិនអាចបញ្ជាក់ពីតួនាទីជាឋានៈទេ អាចបញ្ជាក់អំពីការងារដែលអ្នកស្រីបានធ្វើជាក់ស្តែងក្នុងរយៈពេលជាងមួយឆ្នាំនោះបានទេ?

[០៩:៤១:១៩]

**ធ៖** ចាស រយៈពេលក្នុងការ -- នៅអង្គភាពកុមារហ្នឹង នាងខ្ញុំជាអ្នកសេដ្ឋកិច្ច រកបន្លែ រកម្ហូប អីចឹងមក ដាំបាយ ដាំទឹក។ ខាងផ្នែកខ្ញុំខាងសេដ្ឋកិច្ច។ ចាស អ្នកដាំបាយផ្សេងអីចឹង សម្រាប់រកម្ហូប រកបន្លែ។ រួចមកជាជំនួយការហ្នឹង ដូចថាជំនួយការបង្រៀនដែលគ្រូអនុវត្តមាន ចាស។ គ្រូអវត្តមានអីចឹង ក្នុងហ្នឹងក៏ ខ្ញុំមានតួនាទីមើលការខុសត្រូវកុមារមួយក្រុម សម្រាប់ដឹកនាំធ្វើពលកម្ម។ ចាសប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចបញ្ជាក់បានទេថា អ្នកណាខ្លះជាគ្រូនៅក្នុងក្រុមអ្នកស្រី?

**ធ៖** ខ្ញុំភ្លេចខ្លះ ចាំខ្លះ។ អ្នកដែលចាំឈ្មោះ យ៉ាត, កែវ ជា, ផល, ឈ្មោះ យ៉ាង ស៊ីយៀន។

**ស៖** បាទ ខ្ញុំសូមបញ្ជាក់ឡើងថា ឈ្មោះដែលអ្នកស្រីរៀបរាប់អម្បាញ់មិញនេះ គឺជាគ្រូបង្រៀន តើអីចឹងមែនទេ?

**ធ៖** ជាអ្នកគ្រូបង្រៀន ចាសគឺអីចឹង។

**ស៖** តើអ្នកស្រីដឹងថា គេមានបានបង្រៀនអ្វីខ្លះទេ?

**ធ៖** ចាស ពេលៗនោះ ពេលដែលគ្រូគ្រប់ផ្នែកគេបង្រៀន -- និយាយទៅខ្ញុំមានភារកិច្ចដោយឡែក។ ការបង្រៀនរបស់គេៗ មានទីកន្លែងរៀងៗខ្លួន អីចឹងខ្ញុំអត់បានចូលរួម ការស្តាប់នូវការគេបង្រៀន ព្រោះខ្ញុំ ពេលនោះខ្ញុំមានភារកិច្ចខាងសេដ្ឋកិច្ច។ ចាស សូមអរគុណប៉ុណ្ណឹង។

[០៩:៤៤:២៥]

**ស៖** បាទ សូមអរគុណ។ ខ្ញុំបាទសូមសួរអំពីបញ្ហារៀបអាពាហ៍ពិពាហ៍របស់អ្នកស្រីវិញម្តង។ គឺនៅពេល -- មុនពេលដែលអ្នកស្រីប្តេជ្ញា ដោយពេលនោះអ្នកស្រីបានដឹងដំណឹងពីមេកង ហើយអ្នកស្រីបានជម្រាបអង្គជំនុំជម្រះកន្លងទៅថាអ្នកស្រីបានទៅកាន់វត្ត ដើម្បីធ្វើការបួងសួងមួយចំពោះមុខព្រះពុទ្ធ។ ខ្ញុំចង់សួរបញ្ជាក់អ្នកស្រីថា "ពាក្យបួងសួង" ដែលអ្នកស្រីបានលើកឡើង ដែលថា សុំឲ្យព្រះជាអ្នកជួយសម្រេចថាឲ្យអាពាហ៍ពិពាហ៍ហ្នឹង ការប្តេជ្ញាហ្នឹងកើតឡើង ឬមិនកើតឡើង ក្នុងករណីដែលអ្នកស្រីថា

"បើសិនជាមនុស្សល្អសូមឲ្យកើតឡើងចុះ បើជាគូព្រេង បើមិនមែនជាគូព្រេងទេ អាហ្នឹងមិនឲ្យកើតឡើងទេ"បាទ។ ក្នុងៗន័យនេះ តើអ្នកស្រីមានភាពមិនច្បាស់លាស់ចំពោះការប្ដេជ្ញាចិត្ត -- សូមទោសចំពោះការប្ដេជ្ញាដែលយើងឥឡូវនេះហៅថាជាការរៀបអាពាហ៍ពិពាហ៍នោះ។ តើអ៊ីចឹងមែនទេ? អ្នកស្រីអាចពន្យល់បានទេ?

**ឆ៖** ចាស ក្នុងការប្ដេជ្ញា គឺខ្ញុំអត់បានព្រាងទុកជាមុន គឺនិយាយទៅវាអត់ដឹងខ្លួនចាស។ អត់ដឹងខ្លួន ពេលដែលអង្គការសម្រេចថាឲ្យរៀបចំប្ដេជ្ញា។ អ៊ីចឹងខ្ញុំមានការរន្ធត់។ ពេលនោះក៏គេបើកឱកាសឲ្យយើងមកស្ដៀកពាក់ខោអាវ។ ខ្ញុំគ្មានជម្រើសអី គឺខ្ញុំដូចថាការប្ដេជ្ញារបស់ខ្ញុំ គឺអត់ពេញចិត្តទាល់តែសោះ ប៉ុន្តែការប្រកែកគឺខ្ញុំអត់មានការប្រកែកទៅរួច។ អ៊ីចឹងខ្ញុំគ្មានជម្រើសអី ការទ័លច្រករបស់ខ្ញុំៗមកចូលនៅក្នុងវិហារដ៏ស្ងាត់ ដូចថាគ្មានលោកសង្ឃលោកអីទេ។ ហ្នឹងគេជម្រុះអស់ហើយ។ ដល់ខ្ញុំគ្មានជម្រើសអី ខ្ញុំនឹកឃើញថាឥឡូវប្រឆាំងក៏ប្រឆាំងទៅមិនរួច ត្រូវតែធ្វើទាំងការជូរចត់។ អ៊ីចឹងមានតែការទ័លច្រកពេក បន់ស្រន់ព្រះអង្គថា "ពិតមែន បើគ្មានជាគូព្រេងរបស់ខ្ញុំទេ សូមឲ្យព្រះអង្គកុំឲ្យមានកម្មវិធីនៅយប់នេះឲ្យសោះ បើពិតមែនជាគូព្រេងរបស់ខ្ញុំ សូមឲ្យមានការរៀបចំនេះទៅចុះ"។ ហ្នឹងខ្ញុំមានការ ហ្នឹងការខ្ញុំមិនពេញចិត្ត ទ័លច្រករបស់ខ្ញុំៗធ្វើយ៉ាងៗហ្នឹងហើយ។ បើកាលណាជាមានកម្មវិធីខ្ញុំមិនពេញចិត្តក៏ត្រូវតែធ្វើដែរនៅពេលហ្នឹង។ ខ្ញុំសម្រេចចិត្តអ៊ីចឹងហើយ។

[០៩:៤៧:៣៧]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរអ្នកស្រីបញ្ជាក់បន្ថែមអំពីក្រោយរៀបអាពាហ៍ពិពាហ៍។ អ្នកស្រីបានឆ្លើយបញ្ជាក់ជូនអង្គជំនុំជម្រះកន្លងមកថា អ្នកស្រីនៅពេលដែលរៀបអាពាហ៍ពិពាហ៍ហើយ គឺបានទៅរស់នៅធ្វើការផ្សេងពីគ្នា ពីស្វាមីរបស់អ្នកស្រី រហូតដល់មានការរៀបចំឲ្យមានការមករស់នៅជាមួយគ្នានៅក្នុងផ្ទះមួយ។ អ្នកស្រីអាចបញ្ជាក់បានទេថា រយៈពេលពីអ្នកស្រីរៀបការហើយ ប្ដេជ្ញាហើយ រហូតមកដល់មករស់នៅក្នុងផ្ទះមួយជុំគ្នាហ្នឹងមានរយៈពេលប៉ុន្មានថ្ងៃ ប៉ុន្មានខែ?

**ឆ៖** ការរៀបចំផ្ទះមួយដែលចាត់តាំងឲ្យនាងខ្ញុំទាំងពីរនាក់មកនៅហ្នឹង គឺរយៈពេលតិចណាស់ប្រហែលជាមួយអាទិត្យ ពីរអាទិត្យប៉ុណ្ណឹងចាស។ ក្រោយមក គេចាត់តាំងឲ្យទៅនៅកងសព្វៗខ្លួន រៀងខ្លួនដោយឡែកពីគ្នា។ ក្នុងពេល -- ចាសតែប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ អ្នកស្រីអាចបញ្ជាក់ពីលក្ខណៈរបស់ផ្ទះហ្នឹងទេ ថាអ្នកស្រីបានមករស់នៅក្នុងផ្ទះដែលៗអ្នកស្រីមករស់នៅជាមួយស្វាមីរបស់អ្នកស្រីហ្នឹង។ ជាផ្ទះប្រភេទយ៉ាងម៉េច? មានទំហំ

កម្ពស់ ឬក៏ស្ថានភាពជញ្ជាំង កម្រាលជាដើម។

[០៩:៤៩:៤៦]

**ផ៖** ចាស ផ្ទះនោះសង់អំពីឈើប្រក់ក្បឿង។ ទំហំប្រហែលជាមុខប្រាំ បណ្ដោយប្រាំមួយប៉ុណ្ណឹង។ រនាបក្ដារ ប៉ុន្តែច្រៀកប្រហែលជាពីរ មួយតឹកអីហ្នឹង ប៉ុនៗបីម្រាមដៃ។

**ស៖** ជញ្ជាំងអ្វីដែរ?

**ផ៖** --

**ប្រធានអង្គជំនុំ៖**

កុំអាលៗទាន់ឆ្លើយតប! ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។

**លោកស្រី ជាំង ស្រីមុំ៖**

**ផ៖** ចាស សូមទោស។ ជញ្ជាំងធ្វើជារនាបឫស្សី មាត់ទ្វារក្ដារខ្លះ ចាស។ ចាស ប៉ុណ្ណឹង។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ ចុះនៅខាងក្រៅផ្ទះវិញ អ្នកស្រីមាន -- នៅផ្ទះហ្នឹង មានដើមឈើមានព្រៃអីច្រើនទេ? មានដំណាំអីផ្សេងៗទៀតទេ?

**ផ៖** ចាស ផ្ទះហ្នឹងមាន។ មានដើមស្វាយ មានដើមដូង ចាស ព្រោះអីភូមិចាស់បូរាណ។

**ស៖** បាទ ចុះកម្ពស់ៗមានជណ្ដើរប៉ុន្មានកាំដែរផ្ទះហ្នឹង?

[០៩:៥១:៤៦]

**ផ៖** ចាស វាអត់ចាំនូវជណ្ដើរប៉ុន្មានកាំទេ ប៉ុន្តែកម្ពស់ហ្នឹងប្រហែលជាមួយម៉ែត្រជាងអីហ្នឹងពីកម្ពស់ពីដីទៅ។ មួយម៉ែត្រអី ពីរម៉ែត្រប៉ុណ្ណឹង។ ចាស ការស្មាន ភ្លេចអស់ហើយ មិនបានព្រាងទុកមិនបានកត់សម្គាល់ក្នុងចិត្តទេ ចាស។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីមានរបស់ប្រើប្រាស់សម្រាប់ដំណេកទេ នៅពេលទទួលទានដំណេកនៅលើផ្ទះនោះ?

**ផ៖** ចាស មានកន្ទេល ៗស្លឹកត្នោត និងកើយសាក់កាដូប៉ុណ្ណឹង ចាស។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីមានចងមុងទេ?

**ផ៖** ចាស អត់មានមុងទេ ចាស។

**ស៖** ក្នុងរយៈពេលកន្លងមក អ្នកស្រីបានជម្រាបជូនអង្គជំនុំជម្រះថា អ្នកស្រីបានឃើញឈ្លប

ដែលមកលបមើលអ្នកស្រី។ អ្នកស្រីអាចបញ្ជាក់បានទេថា ម៉ោងប៉ុន្មានដែរ នៅពេលដែលឈ្លបនោះមកៗលបមើលអ្នកស្រីនៅក្រោមផ្ទះរបស់អ្នកស្រី?

[០៩:៥៣:៣៧]

**ឆ៖** ចាស ប្រហែលជាម៉ោងប្រាំបី ឬមួយម៉ោងប្រាំបួន។ ចាស វាយើងដឹងតែពេលយប់។ ពេលយប់មិនមែនព្រលប់ ឬមួយយប់ជ្រៅពេក។ ចាស ពេលហ្នឹង ប្រហែលជាម៉ោងប្រាំបី ឬប្រាំបួនប៉ុណ្ណឹង ចាស។

**ស៖** បាទ សូមអរគុណ។ គេមកក្នុងរយៈពេលយូរប៉ុនណាដែរ នៅយប់នុ៎ង?

**ឆ៖** ចាស ពេលមក អាចដឹងមក ព្រោះអីយើងលបមើលឃើញទៅ វាដើរនៅក្រោមផ្ទះ តែពេលយើងឃើញទៅ ក្រោយមកមិនដឹងថាគេនៅកៀនកោះ នៅកន្តុកកន្តៀតណា ក៏យើងអត់ដឹងទៅមុខទៀត។ យើងចេះតែសម្ងំតែប៉ុណ្ណឹងទៅ ចាស។ ពេលចេញយើងអត់ដឹងទេ ពេលចូលមកក៏អត់ដឹងដែរ។ ប៉ុន្តែដល់មកនៅក្រោមពីយើង យើងអាចដឹង។ ដឹង យើងលបមើលឃើញ ប៉ុន្តែដល់ពេលគេថយទៅវិញមិនដឹងពេលណាដែលគេចេញទៅទេ អត់ដឹងទេ។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីស្គាល់ឈ្លបណានៅក្នុងភូមិនេះទេ ក្នុងសម័យនុ៎ង?

**ឆ៖** ចាស ស្គាល់ៗ ប៉ុន្តែអ្នកដែលមកហ្នឹង មិនដឹងជាអ្នកណា ក៏អត់ដឹងស្គាល់ច្បាស់ដែរ។ ស្គាល់ ឈ្លបស្គាល់ឈ្មោះ ជិន មួយទៀតឈ្មោះ តាប់ និងឈ្លបផ្សេងៗទៀតអត់ស្គាល់ឈ្មោះអស់ចាស។

**ស៖** បាទ សូមអរគុណ។ ពេលក្រោយ -- ក្រោយភ្ញាក់ពីដំណេកនៅយប់នោះ អ្នកស្រីបានទៅសួរព័ត៌មានទាក់ទងនឹងការមកខាងក្រោមផ្ទះរបស់អ្នកស្រីហ្នឹង ដល់ឈ្លបដែលអ្នកស្រីស្គាល់ហ្នឹងដែរទេ?

[០៩:៥៦:០៧]

**ឆ៖** ចាស ពេលនោះគឺអត់ហ៊ានសួរទេ ធ្វើអត់ដឹងៗ ធ្វើអត់ឃើញ។ សួរក៏អត់ហ៊ានសួរទៅអ្នកណា ឬមួយដេញដោល អត់មានហ៊ានសួរតាមដានកិច្ចការអស់ហ្នឹងទេ ចាស។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរសំណួរមួយចំនួនទាក់ទងទៅនឹងការទទួលទានអាហារ។ អ្នកស្រីបានបញ្ជាក់អំពីកងផ្សេងៗ អំពីការហូបរួមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកស្រីអាចជម្រាបបានទេថា ការហូបរួមនោះរវាងក្នុងដំណាក់កាលដំបូងពេលអ្នកស្រីនៅកងកុមារ តើការហូបរួមនោះនៅក្នុងក្រុមរបស់អ្នកស្រី ហូបរួមទាំងអស់គ្នា ឬមួយមានការបែងចែករវាងកុមារហូបផ្សេង

ហើយនិងក្រុមអ្នកធ្វើការហូបផ្សេង?

**ឆ៖** ចាស ក្នុងការហូបរួមនៅអង្គភាពកុមារនោះ គឺហូបផ្សេងពីគ្នា គឺកុមារ គឺរៀបចំគ្រូធំៗ និងអ្នកចុងភៅ គឺរៀបចំឲ្យកុមារដាក់តុដង្ហែគ្នា តែចំពោះគ្រូៗយើងហូបបាយផ្សេងពីកុមារ មិនមែនហូបបាយរួមជាមួយកុមារទេ។

**សៈ** បាទ សូមអរគុណ។ ចុះសម្រាប់អ្នកដែលធ្វើការ ដែលអ្នកស្រីមានប្រសាសន៍ថា ១០នាក់ជាងជាអ្នកធ្វើការនៅកងកុមារនោះ ហូបជុំគ្នាទាំងអស់គ្នា ឬក៏មានការបែងចែកជាក្រុមតូចៗទៀតដែរ?

**ឆ៖** ចាស អ្នកដឹកនាំទាំងនោះ ទាំង១០នាក់ហ្នឹង គឺហូបរួមគ្នាៗ មូលគ្នា អត់មានបែងចែកទេ គឺហូបរួមគ្នា។

**សៈ** បាទ សូមអរគុណ។ ចុះនៅពេលអ្នកស្រីចេញពីកងកុមារ ការហូបចុកយ៉ាងម៉េចដែរ អ្នកស្រីអាចជម្រាបបានទេ?

[០៩:៥៩:២១]

**ឆ៖** ចាស ក្រោយពីការចេញពីកងកុមារ ខ្ញុំមករួមរស់នៅក្នុងសហករណ៍ជាមួយប្រជាជន។ ការហូបចុករួមគ្នាជាមួយប្រជាជន ដល់ម៉ោង គឺយើងហូបបាយរួមគ្នា គឺបាយ គឺឯកភាពគ្នាតែមួយចានៗដូចគ្នា គឺបើបបរៗដូចគ្នាទាំងអស់។ សម្ល គឺដួសចែកគ្នាក្នុង ដូចថាមួយតុហ្នឹងយើងដាក់រៀបដង្ហែគ្នាអ៊ីចឹងហើយ ប៉ុន្តែក្នុងមួយចានហ្នឹង វាមានបួននាក់ៗ អ៊ីចឹងទៅ។ ចាស ហូបទៅរបៀបអ៊ីចឹង។

**សៈ** បាទ សូមអរគុណ។ អ្នកស្រីអាចបញ្ជាក់បានទេពីការហូបចុករវាង ប្រជាជនពេញសិទ្ធិ ដែលអ្នកស្រីបានជម្រាប ហើយនិងប្រជាជនត្រៀម។ តើគេហូបជុំគ្នាទេទាំងពីរក្រុមហ្នឹង?

**ឆ៖** ចាស ប្រជាជនពេញសិទ្ធិ និងប្រជាជនត្រៀម គឺប្រជាជនត្រៀម គឺយើងនៅរួម ហូបបាយរួមគ្នា។ ប្រជាជនពេញសិទ្ធិគេដូចថា នៅៗសហ -- នៅកន្លែងមួយ នៅកន្លែងអង្គភាពមួយអ៊ីចឹងទៅ ឬមួយអ្នកពេញសិទ្ធិៗ គេសម្រាប់ឲ្យមើលការខុសត្រូវ។ មានអ្នកពេញសិទ្ធិហ្នឹង គេមើលការខុសត្រូវសម្រាប់សហករណ៍ត្រៀមហ្នឹងចាស ជាប្រធាន ឬមួយក៏អ៊ីចឹងទៅ ឬមួយអនុប្រធាន ឬមួយជាចុងភៅ ឬមួយជាអ្នកសេដ្ឋកិច្ចអ៊ីចឹងទៅ អ្នកពេញសិទ្ធិ។ មិនសូវមានការច្របូកច្របល់ជាមួយអ្នកត្រៀមទេ។

**សៈ** បាទ សូមអរគុណ។ ឥឡូវអ្នកស្រីអាចបញ្ជាក់ជាលក្ខណៈទូទៅ ខ្ញុំអត់និយាយអំពីអ្នកដែលមានតួនាទីនៅក្នុងរោងបាយ ឬក៏សហករណ៍ទេ។ ខ្ញុំចង់និយាយអំពីប្រជាពលរដ្ឋ ប្រជាជនជាទូទៅ

ដែលយើងហៅថា ប្រជាជនពេញសិទ្ធិ និងប្រជាជនត្រៀមហ្នឹង តើគេមានរោងបាយនៅញុំាអាហារចែកក្នុងរបបជាមួយគ្នា ឬក៏មានរោងបាយដាច់ដោយឡែកពីគ្នា របបខុសគ្នា?

[១០:០២:១៣]

**ឆ៖** ចាស នៅក្នុងឃុំហ្នឹង វាបែកចែកសហករណ៍ វាមានច្រើនក្រុម។ ដែលក្រុមៗដែលត្រៀមហ្នឹង ដូចថាក្រុមមូលដ្ឋាន ប្រជាជននៅក្នុងមូលដ្ឋាន ឬមួយត្រៀម និងប្រជាជនថ្មី ដូចជាប្រជាជនថ្មី ប្រជាជន១៧ហ្នឹង គេមានសហករណ៍ផ្សេង។ ចាស វាមានបែកអ៊ីចឹង មានបែកសហករណ៍ផ្សេង មានបាយផ្សេងពេលធ្វើការ អ៊ីចឹងទៅ វាមានបង្កើតសហករណ៍ -- មានសហករណ៍ផ្សេង ហូបបាយដោយឡែកពីគ្នាហ្នឹង។

**ស៖** បាទ ខ្ញុំចង់បញ្ជាក់បន្ថែមពីព្រោះថា អត់ច្បាស់ថា តើក្នុងសហករណ៍មួយដែលសុទ្ធតែជាអ្នកពេញសិទ្ធិ ជាប្រជាពលរដ្ឋពេញសិទ្ធិ ហើយសហករណ៍មួយទៀត សុទ្ធតែជាអ្នកត្រៀម អ្នកស្រីចង់និយាយអ៊ីចឹង ឬមួយក៏អ្នកស្រីចង់និយាយថានៅក្នុងសហករណ៍នីមួយៗហ្នឹងមានចម្រុះគ្នា?

**ឆ៖** ចាស ខ្ញុំមិនសូវបានចាំច្បាស់លាស់ទេ វាយូរមកហើយ ប៉ុន្តែសហករណ៍ហ្នឹង គឺបាយរួមហ្នឹង វាមាននៅដូចថា នៅក្នុងឃុំទាំងមូលហ្នឹងមិនមែនមានមួយកន្លែងទេ វាមានពីរបីកន្លែងអ៊ីចឹង។ អ៊ីចឹង ខ្ញុំចាំច្បាស់ថា សហករណ៍មួយដែលប្រជាជនមួយក្រុម ដែលជា១៧ ឬមួយជាអាណិកជន -- ជនភាគតិចអីអ៊ីចឹងទៅ គេបង្កើតជាឲ្យនៅភូមិមួយ នៅមួយកន្លែងអ៊ីចឹង តែប្រជាជនមូលដ្ឋាន គឺនៅមួយកន្លែង ចាស។ នៅមួយកន្លែង ដល់ពេលហើយ វាមិនមានការច្បាស់លាស់ទេ ដល់ពេលក្រោយមក គឺប្រជាជនមូលដ្ឋានហ្នឹង ដែលអ្នកពេញសិទ្ធ អ៎! មិនពេញសិទ្ធិហ្នឹង ហើយអ្នកប្រជាជនថ្មីហ្នឹង ជាសហ-ករណ៍មួយ រួមបាយគ្នា រួមនៅហូបបាយរួមគ្នា។ គេប្រមូល អាហ្នឹងដូចថាគេប្រមូលសរុបហើយ។ ពីមុននៅបែងចែក វាមានពីរបីកន្លែង។ ខ្ញុំមិនសូវចាំច្បាស់ឥឡូវនេះ។ ក្រោយមកចុងក្រោយ គឺសរុបរួមគ្នា។ សរុបរួមគ្នាហ្នឹងរហូតដល់ឆ្នាំ១៩៧៩ហ្នឹង រហូតបែក -- រំដោះនេះបាននេះ បានបែកគ្នានៅពេលហ្នឹង។

[១០:០៥:៣៧]

**ស៖** បាទ សូមអរគុណ។ ចំពោះរបបអាហារនៅក្នុងចម្លើយរបស់អ្នកស្រី ចម្លើយទី១១នៃឯកសារ D232/58 អ្នកស្រីបានបង្ហាញថា "ចំពោះអ្នកហូបតិច របបអាហារអាចគ្រប់គ្រាន់ តែមិនគ្រប់ គ្រាន់ទេចំពោះអ្នកហូបច្រើន"។ តើអ្នកស្រីអាចបញ្ជាក់ពីចំណុចនេះបន្ថែមបានទេថា តិច ឬច្រើន

ហ្នឹងប៉ុន្មាន ដែលហៅថាគ្រប់គ្រាន់និងមិនគ្រប់គ្រាន់សម្រាប់អ្នកដែលហូបច្រើនហ្នឹង?

**ឆ៖** ចាស អ្នកហូបច្រើននិងអ្នកហូបតិចនោះ គឺៗអាហារៗគឺមានកំណត់ចាស គឺមានកំណត់។ ដល់តែពេលអ្នកហូបច្រើនទៅ វាហូបអត់ឆ្អែតនៅពេលហ្នឹង តែបើអ្នកហូបតិចទៅ គេឆ្អែតទៅ គេធម្មតារបស់គេទៅ។ តែអ្នកហូបច្រើន គ្នាហូបអត់ឆ្អែត ចាសវាបញ្ហានៅពេលហ្នឹង។

**ស៖** បាទ សូមអរគុណ។ ចុះ ទាក់ទងទៅនឹងការដែលឱ្យហូបឆ្អែតក្នុងរយៈពេលមួយខែម្តងដែលអ្នកស្រីបញ្ជាក់ថាអាចហូបតាមចិត្ត។ អ្នកស្រីដឹងថាអ្នកណាជាអ្នកសម្រេចឱ្យហូបឆ្អែតក្នុងមួយខែម្តងនេះដែរទេ?

**ឆ៖** ចាស ហ្នឹងនៅក្នុងឃុំហ្នឹង គេកំណត់អ៊ីចឹងថាវាមានថ្ងៃ៣០ ជាថ្ងៃហូបឆ្អែតអ៊ីចឹង ដូចថាជាអចិន្ត្រៃយ៍គេដាំបាយជ្រាយ ឬមួយបបរអ៊ីចឹង ដាក់ពាងដាក់អ៊ីចឹង។ ដល់តែពេលថ្ងៃ៣០ហ្នឹង គេដាំបាយរឹងបាយស្រួយអ៊ីចឹង ឱ្យប្រជាជនហូបៗដោយថាការដួសហ្នឹងដាក់មកអត់មានកំណត់។ ពេលអចិន្ត្រៃយ៍ គេដួស ពេលបាយម្តងៗគេដួស ដូចថាមួយកន្ធ ឬមួយចានអ៊ីចឹង កំណត់ក្នុងមួយកន្ធហ្នឹងវាមានគ្នាប៉ុន្មាននាក់ អ៊ីចឹងយើងចាប់ទៅ យើងអ្នកហូបហ្នឹងយើងចែករំលែកគ្នាទៅ។ បើលើសចែកគ្នាតិចៗទៅ តែដល់ចំពោះថ្ងៃ៣០ហ្នឹង គេហូបអត់មានកំណត់គឺហូបៗមួយឆ្អែតអ៊ីចឹងទៅ ដួស អស់ឡើងដួសៗ អ៊ីចឹងណា។

[១០:០៨:២២]

**ស៖** បាទ សំណួររបស់ខ្ញុំសួរថា តើអ្នកស្រីដឹងថាតើអ្នកណាជាអ្នកសម្រេចឱ្យមានថ្ងៃ៣០ហូបឆ្អែតអ៊ីចឹងដែរទេ? អ្នកស្រីស្គាល់ទេ?

**ឆ៖** ចាស ខ្ញុំអត់ស្គាល់ទេ។ នេះដូចថាជាផែនការៗថ្នាក់លើ គ្រាន់តែដឹងថាថ្នាក់លើៗផែនការថ្នាក់លើ មិនដឹងថាថ្នាក់លើហ្នឹងជាអ្នកណាក៏ខ្ញុំអត់ដឹងដែរចាស។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសុំសួរអ្នកស្រីទាក់ទងទៅនឹងបញ្ហាគ្រួសាររបស់អ្នកស្រីក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ អ្នកស្រីក្រោយពីរៀបអាពាហ៍ពិពាហ៍ហើយ ក្រោយពីប្តេជ្ញាហើយ អ្នកស្រីបានរស់នៅជាមួយស្វាមីរបស់អ្នកស្រីរហូត ឬក៏មានបែកចេញពីគ្នាទៅស្រុកផ្សេងតំបន់ផ្សេងដែរទេ?

**ឆ៖** ចាស ពីក្រោយការរួច គឺគ្រួសារនាងខ្ញុំមិនបាននៅមូលគ្នាទេ នៅកន្លែងផ្សេងពីគ្នា គឺមិនបានឆ្លងស្រុកឬខេត្តទេ គឺគ្រាន់តែឆ្លងឃុំ តែនៅក្នុងស្រុកត្រាំកក់ជាមួយគ្នា ប៉ុន្តែដោយឡែកនៅឃុំខុសគ្នា។ ចាស ឧទាហរណ៍ខ្ញុំនៅឃុំញ៉ែងញ៉ង គាត់នៅក្នុងឃុំលាយបូរ តែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចបញ្ជាក់បានទេ រយៈពេលដែលអ្នកស្រីនៅក្នុងផ្ទះជាមួយ ហើយនិងនៅឃុំផ្សេងគ្នានោះ វាខុសគ្នាយ៉ាងម៉េចដែរ? វាមានរយៈពេលខុសគ្នាយ៉ាងម៉េចដែរ? ខ្ញុំចង់ដឹង
ថាតើអ្នកស្រីភាគច្រើននៅក្នុងផ្ទះជាមួយ ឬក៏ភាគច្រើននៅផ្ទះបែកពីគ្នា?

**ឆ៖** ចាស ភាគច្រើន គឺនៅបែកគ្នារហូត នៅផ្ទះបែកគ្នា មានជួបគ្នាដូចថា មានពេលថ្ងៃ៣០ អ៊ីចឹង ៗអង្គការអនុញ្ញាតឲ្យមកជួបដែលគ្រួសារ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីដូចអស់ពេលហើយ លោកមេធាវី។

អង្គជំនុំជម្រះសូមអរគុណ ចំពោះលោកស្រី ជាំង ស្រីមុំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះប៉ុន្មានថ្ងៃកន្លងមកនេះ។ ហើយរហូតមកដល់នេះ ការស្តាប់សក្ខីកម្មរបស់លោកស្រី ក្នុងឋានៈជាសាក្សីបានចប់ហើយ។ ហើយវត្តមានរបស់លោកស្រីនៅបន្ទប់សវនាការនេះ លែងមានភាពចាំបាច់ទៀតហើយ។ លោកស្រីអាចវិលត្រឡប់ទៅលំនៅដ្ឋាន ឬទៅគោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ សូមលោកស្រីធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីនេះវិលត្រឡប់ទៅវិញចុះ។ ហើយតទៅនេះអង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ សាមសិបនាទី – ដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១២ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ ហើយតទៅនេះ ចាប់ផ្តើមស្តាប់សាក្សី

ដែលមានរហស្សនាម 2-TCW-964។

មន្ត្រីរដ្ឋបាលតុលាការកោះអញ្ជើញសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលកាន់បន្ទប់សវនាការ)*

[១០:៣៥:៥៤]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី តើលោកឈ្មោះអី?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប សូមណែនាំអំពីការប្រើប្រាស់ក្បាលមីក្រូហ្វូននោះ នៅពេលដែលសាក្សីត្រូវឆ្លើយតប សាក្សីរង់ចាំក្បាលមីក្រូហ្វូនហ្នឹងឲ្យសញ្ញាភ្លើងក្រហម។ មានន័យថាក្បាលមីក្រូហ្វូនចាប់ផ្តើមប្រតិបត្តិការ សឹមចាប់ផ្តើមនិយាយ ដើម្បីឲ្យសំឡេងរបស់សាក្សីចែកចាយទៅគ្រប់ភាគីដែលពាក់ព័ន្ធរួមមាន សាធារណជន ជាពិសេសទៅអង្គភាពបកប្រែភាសា ដើម្បីបកប្រែភាសាសាក្សីទៅជាពីរភាសាផ្សេងទៀត ភាសាអង់គ្លេស និងភាសាបារាំង។ អ៊ីចឹងពេលដែលសួរទៅ សាក្សីអាចនឹងគិតស្តាប់ចម្លើយនេះ ហើយនិងគិតថាឆ្លើយតបបង្អង់បន្តិច គិតថាឆ្លើយតបយ៉ាងម៉េច។ អ៊ីចឹង គឺមានឱកាសក្នុងការគិត ក្នុងការឆ្លើយតបផង ហើយវាស្របជាមួយនឹងក្បាលមីក្រូហ្វូនប្រតិបត្តិការផង។ ព្រោះក្បាលមីក្រូហ្វូននេះ មិនអាចបើកឲ្យសាក្សីភ្លាមៗឆ្លើយតបភ្លាមៗបានទេ ព្រោះទម្រាំតែបកប្រែចប់។ អ៊ីចឹងបង្អង់ធ្វើម៉េចឲ្យបកប្រែចប់សិន បានសាក្សីឆ្លើយតបទៅ អាហ្នឹងអាចធ្វើឲ្យដំណើរការហ្នឹងរលូនល្អ ហើយសង្ឃឹមថាសាក្សីស្តាប់យល់អំពីវិធីក្នុងការឆ្លើយតបនឹងសំណួរហើយ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** តើលោកសាក្សី លោកឈ្មោះអី?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បាទ ខ្ញុំបាទឈ្មោះ កែវ ច័ន្ទតារា ហៅ យ៉ារ។

**ស៖** តើលោកកើតនៅខែ -- ថ្ងៃខែឆ្នាំណាលោកចាំទេ?

**ផ៖** បាទ ខ្ញុំចាំតែឆ្នាំ គឺកើតនៅក្នុងឆ្នាំ១៩៣៦។

[១០:៣៧:៤៦]

**ស៖** អរគុណ ហើយទីកន្លែងកំណើតរបស់លោក តើនៅកន្លែងណា?

**ផ៖** បាទ ខ្ញុំនៅក្នុងភូមិមហាសេនា ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** អរគុណ ហើយចុះទីលំនៅដ្ឋានរបស់លោកសាក្សីបច្ចុប្បន្ននេះ តើលោកនៅទីកន្លែងណា?

**ផ៖** បាទ នៅកន្លែងដូចជម្រាបខាងលើ ទាន។

**ស៖** បាទ អរគុណ ហើយលោកប្រកបមុខរបរអ្វីដែរសព្វថ្ងៃនេះ?

**ផ៖** បាទ ខ្ញុំជាមន្ត្រីនគរបាលចូលនិវត្តន៍ពីក្រសួងមហាផ្ទៃ។

**ស៖** អរគុណ ហើយចុះឪពុករបស់លោកគាត់ឈ្មោះអី និងម្ដាយរបស់លោកគាត់ឈ្មោះអី?

**ផ៖** ឪពុករបស់ខ្ញុំឈ្មោះ សុខ ឃី ស្លាប់។ ម្ដាយរបស់ខ្ញុំឈ្មោះ កែវ ច័ន្ទយិន គាត់ស្លាប់ប៉ដែរ។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

**ផ៖** បាទ ប្រពន្ធរបស់ខ្ញុំបាទ ឈ្មោះ កៅ សុខុន។ កូនមាន៧នាក់ ស្លាប់អស់២ នៅសល់៥។

**ស៖** អរគុណលោក កែវ ច័ន្ទតារ៉ា តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺថាលោកមិនមានឪពុកម្ដាយ បុព្វញាតិ កូន ឬបច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃ ប្រពន្ធ ត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២នេះទេ។ តើពិតមែនដែរឬទេ?

**ផ៖** បាទ ពិតមែនទាន។

**ស៖** បាទ អរគុណ ហើយថា លោកបានស្បថរួចហើយ មុននឹងចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ។ តើពិតមែនដែរឬទេ?

**ផ៖** បាទ យើងខ្ញុំបានស្បថរួចស្រេចអស់ហើយនៅចំពោះមុខអ្នកតាដំបងដែក។

[១០:៤០:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយតទៅនេះយើងប្រាប់អំពីសិទ្ធិនិងករណីយកិច្ចដល់លោក ក្នុងនាមលោកជាសាក្សី។ អំពីសិទ្ធិ លោក កែវ ច័ន្ទតារ៉ា ក្នុងនាមជាលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏ធ្វើឲ្យ

លោកធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនឆ្លើយ -- ផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ករណីយកិច្ច លោក កែវ ច័ន្ទតារ៉ា ក្នុងនាមលោកជាសាក្សីត្រូវផ្តល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរដែលនាំឲ្យចម្លើយរបស់លោក ឬការធ្វើអះអាង អំណះអំណាងរបស់លោកមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចអង្គជំនុំជម្រះបានប្រាប់អំពីសិទ្ធិរួចដល់លោករួចមកហើយអម្បាញ់មិញនេះ។

ក្នុងនាមលោកជាសាក្សីត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចង់ចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក កែវ ច័ន្ទតារ៉ា តើលោកដែលធ្លាប់បានផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ហើយប្រសិនបើធ្វើ តើធ្វើប៉ុន្មានដង? ហើយធ្វើនៅទីកន្លែងណាខ្លះ?

[១០:៤១:៥០]

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បាទ ខ្ញុំបាទបានធ្វើច្រើនដងហើយ ប៉ុន្តែមិនចាំថ្ងៃខែដែលធ្វើនោះទេ ដោយយ៉ាងទាបបំផុតក៏បានប្រហែលជាប្រាំទៅប្រាំមួយដងដែរ ដែលអ្នកចុះស៊ើបអង្កេតអំពីសាក្សីដែលជាប់ពិរុទ្ធកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

**ស៖** អរគុណ។ ហើយនៅពេលមុនចូលមកមុខអង្គជំនុំជម្រះនាពេលនេះ តើលោកបានពិនិត្យមើល ឬអាននូវកំណត់ហេតុដែលបានផ្តល់សក្ខីកម្មកាលពីពេលមុននោះ ដែលលោកបានធ្វើជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** បាទ ដោយច្រើនដងច្រើនគ្រា ហើយពេលវេលាក៏វែងឆ្ងាយមកពេក ខ្ញុំចាំខ្លះមិនចាំខ្លះ។

**ស៖** លោកបានពិនិត្យមើលឡើងវិញដែរទេ? មើលឡើងវិញត្រួសៗដែរទេ អម្បាញ់មិញនេះមុនពេលចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនេះ?

**ឆ៖** ខ្ញុំបានពិនិត្យហើយ ប៉ុន្តែមានសំណួរមួយដែលសរសេរដោយអក្សរដៃ ខ្ញុំអានពុំទាន់ច្បាស់ ហើយក៏មិនបានអានឡើងវិញដែរបាទ។

**ស៖** ហើយតាមសមត្ថភាពដែលលោកបានអាចដឹងនិងចងចាំ តើលោកអាចបញ្ជាក់បានដែរឬទេថា កំណត់ហេតុស្តាប់ចម្លើយដែលលោកបានអាន ដើម្បីរំឭកការចងចាំ គឺពិតជាត្រឹមត្រូវ ឬក៏វាមានស៊ីសង្វាក់គ្នា ស្របគ្នាទៅនឹងចម្លើយដែលលោកបានធ្វើសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលកន្លងមកដែរឬទេ?

**ឆ៖** បាទ មានត្រឹមត្រូវខ្លះ មិនត្រឹមត្រូវខ្លះ។ ដោយក្នុងសំណួរមិនដឹងជាថ្ងៃខែប៉ុន្មានទេដាក់ឪពុកខ្ញុំទៅជា កែវ ច័ន្ទទីយិន ការពិតឪពុកខ្ញុំឈ្មោះ សុខ ឃី។ បាទ មានការខុសខ្លះបន្តិចបន្តួច តែក្នុងពេលនេះខ្ញុំអាចឆ្លើយតម្រូវវិញទៅតាមអ្វីដែលពិតនៅក្នុងចិត្តរបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី។ ហើយក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិវិធាន ៩១ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរទៅសំណួរដេញដោលចំពោះសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសូមបញ្ជាក់ថា សហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលកន្លះថ្ងៃក្នុងការសួរសាក្សីរូបនេះ គឺមួយវគ្គនៃសវនាការនេះរហូតដល់ថ្ងៃត្រង់ ហើយនិងមួយវគ្គនៅរសៀលបានន័យថា ចាប់ពីចាប់ផ្តើមរហូតដល់ម៉ោងសម្រាក។ សូមអញ្ជើញបាទ!

[១០:៤៤:៥៨]

**លោក ត្រាវិស ហ្វារ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីទាំងអស់ទាំងក្នុងនិងក្រៅបន្ទប់សវនាការ។

ជម្រាបសួរលោក កែវ ច័ន្ទតារ៉ា ថ្ងៃនេះ ខ្ញុំសួរសំណួរមួយចំនួនទៅលោកដែល នូវអ្វីដែលបានកើតឡើងជាយូរយារមកហើយ។ ហើយសូមឲ្យលោកមេត្តាជួយឆ្លើយឲ្យបានល្អតាមដែលលោកចងចាំទៅបាន ហើយបើសិនណាជាលោកមិនចងចាំទេ សូមឆ្លើយថាលោកមិនចងចាំទេ។ សូមមេត្តាកុំឆ្លើយស្មាន ហើយបើសិនណាជាសំណួរខ្ញុំវាមិនច្បាស់ ឬក៏ស្មុគស្មាញ សុំសួរខ្ញុំឲ្យខ្ញុំសួរឡើងវិញ កែសម្រួលសំណួរឡើងវិញ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** ខ្ញុំសូមចាប់ផ្ដើមសួរព្រឹត្តិការណ៍នៅក្នុងឆ្នាំ១៩៧០ នៅក្នុងកិច្ចសម្ភាសន៍ នៅក្នុងឯកសារ D25/24 លោកឆ្លើយថាលោកចូលទៅក្នុងព្រៃម៉ាគី ក្នុងព្រៃក្នុងនាមជាវេជ្ជបណ្ឌិតជាមួយមនុស្សម្នាក់ជាវេជ្ជបណ្ឌិតឈ្មោះ ជួន ជឿន។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ជួន ជឿន ជាអ្នកណា? ហើយតើលោកធ្វើអីក្រោយពីលោកបានចូលក្នុងព្រៃម៉ាគីហ្នឹង?

[១០:៤៦:១៦]

**លោក ខៀវ សំផន៖**

**ឆ៖** បានជាខ្ញុំចូលទៅក្នុងព្រៃម៉ាគី ពីព្រោះសម្ដេច នរោត្តម សីហនុវរ្ម័ន បច្ចុប្បន្នជាព្រះបរមរតនកោដ្ឋ។ ព្រះអង្គអំពាវនាវពីក្រុងប៉ារីសមកថា៖ "កូនចៅបើស្រឡាញ់លោក ចូលព្រៃម៉ាគីតស៊ូដើម្បីរំដោះរូបលោកឲ្យចូលមកកាន់តំណែងវិញ ឬជួយដល់រូបលោកផង"។ ដូច្នេះ ខ្ញុំកាលនោះ ត្រូវបបួលគ្នីគ្នាចូលទៅព្រៃម៉ាគីតស៊ូ ប៉ុន្ដែមុននឹងចូលដល់ព្រៃម៉ាគីតស៊ូ ខ្ញុំត្រូវទៅផ្ទះកំណើតរបស់ខ្ញុំ ក្នុងភូមិមហាសេនា ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ ជួបឪពុកម្ដាយខ្ញុំ។

**ស៖** ក្នុងឯកសារ E3/5153 ត្រង់ទំព័រ 00724 ហើយខ្មែរ 00--

**អ្នកបកប្រែ៖**

សុំអធ្យាស្រ័យលោកប្រធានតំណាងសហព្រះរាជអាជ្ញាអាន ERN ញាប់ពេកលោកប្រធានតាមអត់ទាន់។

**លោក ត្រាវិស ហ្វារ៖**

**ស៖** ERN ភាសាខ្មែរ 00172043, ERN អង់គ្លេស 00205088 ហើយបារាំង 00205093 នៅក្នុងកិច្ចសម្ភាសន៍នេះ លោកបានឆ្លើយថា លោកចូលរួមនូវក្នុងភូមិក្បាលអូរ ឃុំជាងទង ស្រុកត្រាំកក់ ហើយគេឲ្យលោកទៅធ្វើការនៅមន្ទីរពេទ្យ៧២ -- បាទមន្ទីរពេទ្យ២២ នៅក្នុងអំឡុងនៃរបបខ្មែរក្រហម ហើយតើអ៊ីចឹងថាតើលោកទទួលបានការងារហ្នឹងដោយរបៀបណាដែរ?

[១០:៤៨:២១]

**លោក ខៀវ សំផន៖**

**ឆ៖** ខ្ញុំចូលទៅដល់ដំបូង ពួកខ្មែរក្រហមទាំងអស់គឺខ្ញុំអត់ស្គាល់នរណាម្នាក់ទេ។ គេមកណែនាំ

ខ្ញុំ ថាឲ្យខ្ញុំហ្នឹងខំក្បត់ធាតុដើមឲ្យអស់ ពីព្រោះលោកជាបញ្ញវន្តអនុធន។ ហើយក្រោយមក ក៏គេណែនាំខ្ញុំ ថា លោកជានិស្សិត លោកជាបណ្ឌិត លោកត្រូវខំក្បត់ធាតុដើម ដើម្បីរស់ក្នុងរបបបដិវត្តន៍។

**ស៖** ខ្ញុំសួរលោកអំពី តាម៉ុក ជាពិសេសសួរអំពី តាម៉ុក។ លោកបានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍ជាមួយនឹង គឺ E3/5153 នេះដែលលោកថា លោកបានជួប តាម៉ុក ជាញឹកញាប់ ហើយ តាម៉ុក ស្គាល់ម្ដាយរបស់លោក។ តើ -- សូមលោកជួយជម្រាបជូនអង្គជំនុំជម្រះផងថា តើម្ដាយរបស់លោកស្គាល់ តាម៉ុក ដោយរបៀបណា? ហើយលោកបានជួប តាម៉ុក ញឹកញាប់ហ្នឹងប៉ុនណាដែរ?

**ឆ៖** បាទ តាម៉ុក នេះ ដែលស្គាល់នឹងម្ដាយខ្ញុំក្នុងរយៈពេលដែលគាត់បួស។ ប្រវត្តិរបស់ តាម៉ុក ជាអ្នករៀនខាងពុទ្ធសាសនា ផ្នែកខាងសាលាបាលីជាន់ខ្ពស់នៅវត្តមហាមន្ត្រី។ ផ្ទះគាត់ឆ្លងចេញពីផ្ទះខ្ញុំទៅផ្ទះគាត់ ដីចំនួនប្រហែលជា៨គីឡូម៉ែត្រ។ សម័យនោះគឺដោយដើរ ឬជិះកង់ឌុប។ តាម៉ុក តែងតែចូលផ្ទះខ្ញុំដើម្បីឆាន់ចង្ហាន់ថ្ងៃត្រង់ដែលចុះពីឡានផ្លូវជាតិលេខ៣មក នៅផ្ទះម្ដាយខ្ញុំ គាត់រាប់អានគ្នារហូត។ ពេលដែលខ្ញុំចេញពីភ្នំពេញទៅដល់ផ្ទះខ្ញុំបាទហើយ និរសាររបស់ខ្មែរក្រហមហ្នឹងមកយកខ្ញុំពីផ្ទះទៅក្នុងថ្ងៃនោះភ្លាម ខ្ញុំអត់ទាន់បានជួបឪពុកម្ដាយខ្ញុំឲ្យបានច្បាស់លាស់និយាយគ្នាច្រើនទេ គឺទៅរស់នៅក្នុងភូមិដំណាក់ស្នួល។ ថ្ងៃដំបូងខ្ញុំមិនទាន់ចូលដល់ភូមិដំណាក់ស្នួលទេ មានភូមិមួយនៅខាងអាយជាងនេះ ឈ្មោះភូមិទួលផ្អឹក។ ខ្ញុំសម្រាកបានប្រហែលជាពីរម៉ោង មាននិរសាផ្សេងទៀតមកយកពីទីនេះទៅកាន់ភូមិដំណាក់ស្នួល។ កន្លែងនីមួយៗរបស់ខ្មែរក្រហមគឺមិនមែនឲ្យយើងនាំនិរសារម្នាក់ហ្នឹងនាំយើងទៅចូលនៅកន្លែងទីៗបញ្ចប់ហ្នឹងទេ គេបណ្ដាក់គ្នាហៅយើងរហូត។ និរសារទី១ មិនអាចយកយើងទៅជួបនឹងក្នុងកន្លែងទីៗមួយនោះទេ គឺដំណាក់ៗៗគឺបួនដំណាក់បានខ្ញុំបាទបានចូលទៅដល់កន្លែងមន្ទីរពេទ្យហៅថាពេទ្យតំបន់ មិនមែនពេទ្យភូមិភាគទេ ពេទ្យតំបន់នៅក្នុងភូមិដំណាក់ស្នួល។ ហើយអ្នកដែលធ្លាប់ស្គាល់ខ្ញុំ ធ្លាប់មកព្យាបាលជំងឺនៅក្នុងមន្ទីរពេទ្យ ព្រោះខ្ញុំកាលដែលខ្ញុំនៅក្នុងមន្ទីរពេទ្យជំនាន់សង្គមរាស្ត្រនិយមនេះ ខ្ញុំធ្វើការ -- សូមទោសផងចុះខ្ញុំសូមនិយាយជាភាសាបារាំងខ្លះ ពីព្រោះខ្ញុំវាពិបាកនិយាយភាសាខ្មែរ ទានណាស់បាទ។ នៅក្នុងមន្ទីរពេទ្យហ្លុងដាស្យុងកាល់ម៉ែត្រ ខ្ញុំធ្វើការនៅបន្ទប់ *រ៉េអានីម៉ាស្យុង* ខ្ញុំមិនដឹងថាខ្មែរថាម៉េចដែរ។ បាទហើយនៅក្នុងមន្ទីរពេទ្យមួយទៀតដែលខ្ញុំធ្វើការ--

[១០:៥២:០៣]

**ស៖** សូមអធ្យាស្រ័យលោកដែលកាត់ផ្ដាច់លោកត្រឹមនេះ។ ខ្ញុំចង់សួរឲ្យលោកផ្ដោតសំខាន់ទៅលើសំណួររបស់ខ្ញុំ។ លោកមានឯកសារច្រើន ហើយលោកមានព័ត៌មានច្រើនត្រូវជម្រាបជូនអង្គជំនុំ

ជម្រះ ប៉ុន្តែជាការប្រសើរគឺថាសូមឆ្លើយមួយដំណាក់ម្តងៗ។ តើលោកយល់បានទេ? បាទសូមអរគុណលោក។ លោកបានទើបតែឆ្លើយអម្បាញ់មិញថា តាម៉ុក គឺថាបានទៅឆាន់ចង្ហាន់នៅផ្ទះម្តាយរបស់លោក។ តើលោកអាចអាចឆ្លើយបានទេ តាម៉ុក នេះអង្កាល់នៅជាសង្ឃហ្នឹងបានឆាន់នៅផ្ទះម្តាយរបស់លោកហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ខ្ញុំមិនបានកត់ត្រាទេ ប៉ុន្តែប្រហែលជាច្រើនលើកណាស់បាទ ហើយពេលខ្លះខ្ញុំនៅសិក្សាភ្នំពេញនេះ ខ្ញុំក៏អត់ដឹងដែរ ដែលពេលគាត់ទៅៗផ្ទះខ្ញុំទៅស្រុកកំណើតរបស់គាត់ហ្នឹង ក៏ខ្ញុំមិនអាចដឹងដែរ ខ្ញុំដឹងពេលតិចណាស់បាទ ប៉ុន្តែឮម្តាយខ្ញុំនិយាយប្រាប់ថា តាម៉ុក នេះព្រោះគាត់មិនមែនឈ្មោះតាម៉ុក អ៊ីចឹងទេ បាទនៅឈ្មោះនៅក្នុងកាលដែលនៅបួសគឺ អាចារ្យជឿន – អ៊ុង ជឿន អ៊ីចឹង។ ជីតារបស់គាត់ឈ្មោះ អ៊ុង ហើយគាត់ពេលដែលគាត់ទៅដល់ផ្ទះខ្ញុំហ្នឹង ពេលខ្លះខ្ញុំនៅរៀននៅ ហ្វាក់មេដេស៊ីន នៅភ្នំពេញ។

[១០:៥៣:៥០]

**ស៖** បាទ សូមអរគុណលោក។ ឥឡូវនេះខ្ញុំសូមចូលទៅប្រធានបទស្តីអំពីការចាប់ខ្លួនលោកម្តង។ តើលោកអាចជម្រាបអំពីកាលៈទេសៈដែលនាំឲ្យមានការចាប់ខ្លួនលោកនៅក្នុងឆ្នាំ៧៣ និង ៧៤?

**ឆ៖** បាទ នៅក្នុងឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៤នេះ មិនទាន់ដល់ការចាប់ខ្លួនទេ គ្រាន់តែគេដកសិទ្ធិខ្ញុំថាខ្ញុំនេះជាមនុស្សសីហនុនិយម។ ពេលនោះគេកំពុងតែអំពាវនាវដល់អ្នកសីហនុនិយមទាំងអស់ឲ្យចេញទៅតស៊ូ។

**ប្រធានអង្គជំនុំ៖**

សាក្សីយើងមើលទៅដូចជាសាក្សីមានឯកសារអីអាននៅមុខទេដឹង បានឃើញចេះតែសម្លឹងខាងក្រោម មន្ត្រីរដ្ឋបាលតុលាការទៅត្រួតពិនិត្យមើលហើយបើមានឯកសារកុំ -- មិនឲ្យមើលឯកសារទេសាក្សី លើកលែងតែភាគីពាក់ព័ន្ធហ្នឹង សូមឲ្យលោកពិនិត្យឯកសាររួច សឹមឆ្លើយ អាហ្នឹងបានអាចមើលបានណ៎ា។

[១០:៥៥:៣៨]

**សួរដោយលោក ត្រាវិល ហ្វារ៖**

**ស៖** ដូច្នេះ នៅពេលដែលគេចាប់ខ្លួនលោក តើគេមានដែលប្រាប់អំពីមូលហេតុនៃការចាប់ខ្លួននោះទេ ឬក៏ក្រោយមកលោកដឹងថាមូលហេតុអីបានជាគេចាប់ខ្លួនលោកទេ?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** ពេលដែលគេនាំយកទៅដល់ក្នុងមន្ទីរឃុំឃាំង គឺនៅក្នុងឆ្នាំ១៩៧៥ មិនមែន៧៣ ទេ រហូតដល់ -- ពីខែកុម្ភៈ ពាក់កណ្ដាល -- ចុងខែកុម្ភៈរហូតដល់ខែមីនា -- ខែមេសា -- ខែមីនា បាទ ១៩៧៥ ខែមីនា រហូតដល់ ៧៥ ខែមេសា គឺឆ្លងឆ្នាំចាស់ទៅឆ្នាំថ្មីពាក់កណ្ដាលខែម្ភៃក៏ទានណា។ អ៊ីចឹង ខ្ញុំបូកសរុបពេលដែលខ្ញុំនៅក្នុងមន្ទីរឃុំឃាំងឃើញ ២៩ថ្ងៃ នៅក្នុងមន្ទីរក្រាំងតាចាន់។

**ស៖** ហើយ លោកដឹងទេថា ហេតុអ្វីបានជាគេចាប់ខ្លួនលោក លោកដឹងអំពីមូលហេតុនៃការចាប់ខ្លួនទេ?

**ឆ៖** ដំបូងឡើយគេមិនប្រាប់ថាមកចាប់យើងទេ គឺមកនាំដោយស្រួលបំផុត។ បាទ គឺគេមកប្រាប់ថា អង្គការថ្នាក់លើឲ្យលោកប្រមូលឯកសារដែលលោកចេះក្នុងវិជ្ជាពេទ្យ សម្ភារៈពេទ្យទៅបង្រៀនអង្គការថ្នាក់លើតាមតំបន់នានា ដែលគេមករៀនសូត្រ ជាវិជ្ជាពេទ្យ។ ប៉ុន្តែដល់ខ្ញុំចូលមួយដំណាក់ ពីនីរសារដំណាក់ទី១ ទៅទី២ ទី៣ យប់ហើយ ទើបខ្ញុំចូលទៅដល់មន្ទីរក្រាំងតាចាន់។

[១០:៥៧:៤៨]

ពេលខ្ញុំចូលទៅដល់មន្ទីរឃុំឃាំងក្រាំងតាចាន់ គេថាយើងទៅនេះ គឺទៅមន្ទីរអប់រំ មន្ទីរកែប្រែ ហើយគេអត់ប្រាប់ថា ក្រាំងតាចាន់អ៊ីចឹងទេ។ តែទៅដល់កន្លែងនោះ ខ្ញុំចូលផុតទ្វារអគារគុកហ្នឹង គេរុញទ្វារបិទសុទ្ធតែលួសបន្លា ខ្ញុំស្មាបទៅក្នុងពេលយប់ ទើបដឹងថាមន្ទីរឃុំឃាំងក្រាំងតាចាន់ហើយ។ ពេលនោះ ខ្ញុំភ្ញាក់ខ្លួនណាស់ ខ្ញុំឃើញអ្នកទោសទាំងអស់នៅក្នុងមន្ទីរក្រាំងតាចាន់ ដល់ព្រឹកឡើងភ្លឺខ្ញុំរាប់ឃើញចំនួនមនុស្សជាង ៤០នាក់ ប្រហែលជា៤៥-៤៦នាក់ទាំងស្រីទាំងប្រុស នៅចម្រុះគ្នាជាប់ខ្នោះជើងខ្សែដែកតែមួយ។

**ស៖** លោកសាក្សី ខ្ញុំសូមត្រឡប់ទៅពេលដែលលោកទៅដល់មន្ទីរសន្តិសុខក្រាំងតាចាន់។ នៅក្នុង D25/24 ត្រង់ទំព័រ 00163457 ហើយខ្មែរ 00223452, អង់គ្លេស 00178091។ លោកបានឆ្លើយថា៖ "ពួកគេបានសួរចម្លើយខ្ញុំ អស់រយៈពេល៥ថ្ងៃ មុនគេយកខ្ញុំទៅក្រាំងតាចាន់"។ បញ្ចប់ការដកស្រង់។ សូមលោកជម្រាបជូនអង្គជំនុំជម្រះសង្ខេប តើក្របីព្រៃនៅឯណា? ហើយសូមរៀបរាប់ទីកន្លែងក្របីព្រៃនេះ ដែលគេបានសួរចម្លើយលោកនោះ?

**ឆ៖** មន្ទីរក្របីព្រៃនៅឆ្ងាយពីផ្ទះខ្ញុំទៅប្រហែលជា១០គីឡូម៉ែត្រជាង។ ហើយពីក្របីព្រៃទៅមន្ទីរក្រាំងតាចាន់ក៏ជិត១០គីឡូម៉ែត្រដែរ។ គេយកខ្ញុំទៅទីនោះ ទៅក្របីព្រៃ។ គេសួរសាកតែអំពីខ្ញុំទៅ

ទទួលបំពាក់បំប៉នពីក្រុម សេ.អ៊ី.អា -- ប៉ុន្តខ្ញុំឥឡូវហ្នឹងមិនទាន់ដឹងរឿង សេ.អ៊ី.អា ហ្នឹងស្អីផងដែរ -- សេ.អ៊ី.អា និង កា.សេ.បេ -- វាមិនអាន កា.ហ្សេ.បេ ទើបខ្ញុំបើក*ឌីត្សិនែរ* មើលឃើញ កា.ហ្សេ.បេ -- គឺពីអ្នកណា?

**សៈ** តើអ្នកណាជាអ្នកសួរចម្លើយលោកនៅឯក្របីព្រៃហ្នឹង?

**ឆៈ** គឺមិនមែននៅ មនុស្សនៅក្នុងមន្ទីរក្របីព្រៃហ្នឹងទេ។ គេអ្នកមកសួរនោះ ខ្ញុំទៅដល់មន្ទីរក្រាំងតាចាន់ឃើញមនុស្សហ្នឹងទៀត គឺអាចារ្យ ឆេន។

[១១:០១:២៣]

**សៈ** ដូច្នេះលោកនិយាយលោកឃើញ តាឆេន នៅឯក្របីព្រៃ ឬក៏ឃើញ តាឆេន នៅឯក្រាំងតាចាន់?

**ឆៈ** ប្រហែលជាពេលនោះ អាចារ្យឆេន គេមកសួរផ្ទាល់នៅក្នុងមន្ទីរក្របីព្រៃហើយ ទើបគេនាំខ្ញុំទៅក្រាំងតាចាន់តែម្តង ប៉ុន្តែគេទៅមុន។ គេសួរខ្ញុំរួច គេទៅបាត់ទៅ។ ប្រាំថ្ងៃក្រោយមក បានគេមកនាំខ្ញុំទៅមន្ទីរក្រាំងតាចាន់។ ហើយក៏ខ្ញុំអត់ដឹងថាមន្ទីរក្រាំងតាចាន់ហ្នឹងជាគុកដែរ ទាល់តែចូលទៅ ដូចខ្ញុំនិយាយឃ្លាមុនណ៎ាទានណ៎ា ទាល់តែចូលទៅដល់ទ្វារគុក គេរុញទ្វារអគារហ្នឹងមក បានដឹងថាសុទ្ធតែលួសបន្លា អ៊ីចឹងគឺគុកហើយបាទ។ កន្លែងក្របីព្រៃអត់មានគុកដាក់ទេ ប៉ុន្តែបើមនុស្សណាដែលគួរសម្លាប់ គឺគេសម្លាប់នៅក្របីព្រៃហ្នឹងភ្លាមៗបាទ។ ហ្នឹងក៏ទីពិឃាដមួយដែរក្របីព្រៃហ្នឹង ប៉ុន្តែមនុស្សណាដែលគួរគេសួរចម្លើយដើម្បីរាវរកសាក្សីបន្តទៅទៀត អ្នកពាក់ព័ន្ធខ្សែរយៈតទៅទៀត គឺគេយកទៅសួរចម្លើយនៅឯមន្ទីរក្រាំងតាចាន់។

**សៈ** សូមសួរមួយសំណួរទៀតអំពីពេលវេលាដែលលោកនៅឯងក្របីព្រៃ មុននឹងបន្តសួរអំពីក្រាំងតាចាន់។ នៅក្នុងផ្នែកតែមួយ គឺឯកសារ D25/24 ដែលនិយាយអំពីការសួរចម្លើយរបស់លោកនៅឯក្របីព្រៃ។ លោកបាននិយាយថា “គេបានសួរខ្ញុំថាតើអ្នកឯងស្អប់បដិវត្តន៍ប៉ុនណាដែរ?” តើគេមានប្រាប់លោកទេ ពេលដែលគេសួរទៅលោកថាហេតុអីបានជាលោកស្អប់បដិវត្តន៍ហ្នឹង? តើគេមានប្រាប់មូលហេតុទេ?

[១១:០៣:១៥]

**ឆៈ** ខ្ញុំអត់សួរ ហ៊ានសួរគេវិញទេទាន តែក្នុងពេលនោះ ខ្ញុំឮពួកឃើញ ពេលដែលខ្ញុំមកផ្ទះម្តងៗនៅរៀនៗពេទ្យហ្នឹង ពួកគេប្រធានភូមិពួកខ្មែរក្រហម នីរសារភូមិខ្មែរក្រហម។ ពួកខ្ញុំទៅមុនៗ គេតែង

បបួលដើរនេសាទ។ ហើយពេលខ្លះ ខ្ញុំរវល់ពេកទៅ ខ្ញុំអត់ទៅ។ ខ្ញុំឲ្យសំណាញ់ ឲ្យកាំភ្លើងបាញ់សត្វទៅ គេទៅបាញ់ចុះ។ តែគេអត់ចេះប្រើរបស់អស់ទាំងហ្នឹង ប្រហែលជាពួកនេះគេរាយការណ៍ទៅផ្សេងទៅទៀត រាយការណ៍ពីភូមិទៅ ពីមូលដ្ឋានខ្ញុំទៅផ្សេងទៀត មិនមែនជារឿងធ្លាក់មកពីមន្ទីរសំណាក់ស្ងួលកន្លែងពេទ្យនោះទេ។ បាទគឺជាពាក្យសម្ដីដែលសួរនេះ គឺកើតឡើងមកពីរបាយការណ៍របស់ប្រធានភូមិដែលឈ្មោះ គល់ មឿន, គល់ ស៊ន។ បាទស្ដាប់អស់ហើយអ្នកទាំងអស់នេះ។

**ស៖** ឥឡូវនេះបន្តទៅពេលវេលាដែលគេឃុំលោកនៅក្រាំងតាចាន់។ សំណួរទី១ ថាតើលោកដឹងទេ អ្នកណាជាអ្នកសម្រេចបញ្ជូនលោកពីក្របីព្រៃទៅក្រាំងតាចាន់?

**ឆ៖** ខ្ញុំគិតស្មានថា ប្រហែលជាមានបញ្ជាពីថ្នាក់លើមកឲ្យដកខ្ញុំចេញពីក្រាំងតាចាន់ អ៎! ក្របីព្រៃ គឺមិនសម្លាប់នៅទីហ្នឹងទេ ឲ្យទៅក្រាំងតាចាន់ ដើម្បីសាកសួរព័ត៌មានឲ្យបានច្បាស់លាស់ជាងនេះទៀត ឬច្រើនទៀតនោះ គឺទៅដល់មន្ទីរក្រាំងតាចាន់។

[១១:០៥:១០]

**ប្រធានអង្គជំនុំ៖**

លោកសាក្សី លោកមិនគប្បីឆ្លើយនូវសំណួរណាដែលប៉ាន់ស្មាននោះទេ ឬក៏ប្រហែលឡើយ។ លោកសាក្សីដឹង គឺឆ្លើយថា ដឹង។ យើងបានប្រាប់ហើយអំមិញ។ ណេះ! ដឹង ឮ ឃើញច្បាស់ ហើយនិងការកត់សម្គាល់ ការសង្កេត។ អ៊ីចឹង គឺកាលណាលទ្ធភាព លទ្ធផលនៃចម្លើយស្មានៗហ្នឹង គឺវាអត់មានរួមវិភាគទានដល់អង្គជំនុំជម្រះយកទៅពិចារណា ក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះទេ។

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** ឥឡូវនោះ ខ្ញុំត្រឡប់ទៅដល់ពេលលោកទើបទៅដល់ក្រាំងតាចាន់។ នៅពេលដែលលោកទៅដល់ក្រាំងតាចាន់ តើលោកដឹងថា មនុស្សប្រភេទណាដែលគេឃុំឃាំង ឬក៏អ្នកទោសរបៀបណាដែលគេឃុំឃាំងនៅក្រាំងតាចាន់?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បាទ អ្នកដែលគេឃុំខ្លាំងនោះ គឺយើងត្រូវជាប់ខ្នោះតែមួយខ្សែដូចគ្នាទេ។ ហើយលំបាកនៅក្នុងមន្ទីរក្រាំងតាចាន់នោះ ក៏កន្លែងតែមួយហ្នឹងទេ។ បាទ គឺខ្សែខ្នោះ គេដាក់ក្ដារពីរសន្លឹក តែខាងក្រោយខ្នងនេះ គេដាក់ឈើដែលមានសុទ្ធតែក្រមរបួនប្រាំដើមឲ្យសម្រាប់យើងដេក បាន--

**ប្រធានអង្គជំនុំ៖**

សាក្សីគ្រាន់តែឆ្លើយតបនឹងសំណួរទេ សំណួរដូចមិនអ៊ីចឹងទេ។ តំណាងសហព្រះរាជអាជ្ញាសូមសួរសំណួរសាថ្មីម្តងទៀត ដើម្បីឱ្យគាត់ស្តាប់យល់នូវសំណួរដែលលោកសួរ។ គាត់មិនឆ្លើយតបនឹងសំណួរដែលលោកសួរទេ។

[១១:០៦:៤៩]

**លោក ត្រាវិស ហ្វារ៖**

បាទសូមអរគុណលោកប្រធាន។

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** លោកសាក្សី សំណួររបស់ខ្ញុំ គឺថាតើមនុស្សប្រភេទណាដែលគេឃុំឃាំងនៅក្រាំងតាចាន់ជាមួយលោក? តើគេជាមនុស្សប្រភេទណាដែរ?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** ខ្ញុំអត់ដឹងថា មនុស្សប្រភេទណាទេ ព្រោះយើងនៅមន្ទីរក្រាំងតាចាន់។ យើងអត់ដឹងថាប្រវត្តិរបស់គេមកពីៗណានោះទេ។

**ស៖** ខ្ញុំសូមអានសម្រង់មួយចេញពីចម្លើយរបស់លោក និងសូមសួរថាតើលោកចាំអំពីព័ត៌មានដែលលោកឆ្លើយនេះឬក៏អត់។ គឺឯកសារ D25/24, ទំព័រជាអង់គ្លេសគឺ 00223455, ហើយបារាំង 00178093, ហើយខ្មែរ 00163460។ បាទ នេះគឺជាចម្លើយរបស់លោកនៅក្នុងកិច្ចសម្ភាសន៍។ “សំណួរ៖ តើអ្នកណាមកពីណា? ឆ្លើយ៖ គឺជាទាហាន លន់ នល់ ជាកម្មាភិបាលខ្មែរក្រហម។ ខ្ញុំបានជួបអ្នកដែលជ្រើសរើសទាហាន ទាហាន លន់ នល់ គេយកទៅព្រៃកន្ទួត។ កម្មាភិបាលដែលអាចចោទថាជាជនក្បត់ ក៏ចាប់ទៅទីនោះដែរ”។ បញ្ចប់ការដកស្រង់។ តើលោកចាំព័ត៌មានដែលលោកបានឆ្លើយទេ?

[១១:០៨:៤២]

**ឆ៖** ខ្ញុំចាំ។ អ្នកដែលទៅអូរកន្ទួតនោះ គឺមន្ទីរនេះ គេដាក់មិនមែនតែទាហានទេ គឺឱ្យតែអ្នកនៅក្នុងសមរភូមិ ហើយគេវាយបែក កន្លែងនោះ មនុស្សសល់ប៉ុន្មានពីងាប់ នៅក្នុងទីនោះ គេយកទៅដាក់នៅអូរកន្ទួត។ តែមនុស្សដែលនៅក្រាំងតាចាន់នេះ ចម្រុះទាំងអស់ គឺមិនពិតថាជាទាហាន មិនពិតថាជាកម្មាភិបាល មិនពិតថាជាអ្នកណាៗទេ ហើយយើងក៏អត់ដឹងថាគេនិន្នាការអ្វីខ្លះដែរ ក្រៅពីគេប្រាប់យើង

ផ្ទាល់នៅក្នុងមន្ទីរគុក។

**ស៖** ដូច្នេះខ្ញុំសូមសួរបញ្ជាក់ គឺទាហាន លន់ នល់ ដែលប្រាប់លោកថា ពួកគេគឺជាទាហាន លន់ នល់។ តើអ៊ីចឹងមែនទេ?

**ឆ៖** ក្រៅពីមនុស្សធ្លាប់នៅភូមិជិត នៅភូមិជាមួយគ្នា គេមិនដែលប្រាប់យើងទេ លុះតែយើងធ្លាប់ស្គាល់ ថាអ្នកហ្នឹងធ្វើទាហាន នៅជាមួយ លន់ នល់ ឬមួយជាគ្រូបង្រៀន ប៉ុនគេ *ត្រង់ស្វែរវេ* ទៅជាទាហាន ទៅជាអីហ្នឹង ហ្នឹងគឺបានប្រាប់យើង។ បាទ តែនៅក្នុងមន្ទីរក្រាំងតាចាន់នេះ អ្នកដែលមិនស្គាល់ មិនដែលនៅភូមិជាមួយគ្នា គេអត់ប្រាប់ទេ។

[១១:១០:២០]

**ស៖** ហើយនៅក្នុងសម្រង់ដែលខ្ញុំទើបលើកមក លោកឆ្លើយថា “ទាហានលន់ នល់ ត្រូវគេយកទៅព្រៃក្តួច”។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ព្រៃក្តួចហ្នឹងស្ថិតនៅកន្លែងណាដែរ? ហើយហេតុម៉េចបានជាលោកដឹងថា ទាហានលន់នល់ ត្រូវបានគេយកទៅព្រៃក្តួច?

**ឆ៖** ក្រោយពីពេលបែកទូទាំងប្រទេសហើយ រំដោះ៧៩ ទើបយើងដឹង។ ក្នុងពេលនោះ គឺយើងអត់ដឹងទេ បាទ តែមន្ទីរព្រៃក្តួចនេះ មិនមែនព្រៃក្តួចទេ គឺមន្ទីរ២០៤ ឈ្មោះលេខគេអ៊ីចឹង នៅឯអូរកន្ទួត មិនមែនព្រៃក្តួចទេ ដុបកន្ទួត មានភ្នំមួយតូចនៅទីនោះ ហើយអ្នកដែលគេយកទៅទីនោះ តិចណាស់ដែលបានមកវិញ គឺ១០០ មានពីរ ឬមួយ ដូចតែក្រាំងតាចាន់ អ៊ីចឹងដែរ។ អ៊ីចឹងអ្នកស្លាប់ក្នុងសមរភូមិដែលពួកខ្មែរក្រហមរើបែក ហើយនាំយកទៅទីនោះ ក៏អត់សូវបានមកផ្ទះវិញដែរ រួចមួយ រួចពីរ ដោយសារតែអ្នកបច្ចេកទេសចេះធ្វើខាងគ្រឿងឈើ ចេះធ្វើស្ពាន ចេះធ្វើផ្ទះសម្បែង ហ្នឹងបានរួចមក។

**ស៖** លោកទើបតែជម្រាបថា លោកទើបតែដឹងក្រោយរបបនោះដួលរលំនៅឆ្នាំ១៩៧៩។ លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា លោកទទួលព័ត៌មានហ្នឹងក្រោយពីរបបហ្នឹងដួលរលំ គឺនៅពេលណាដែរ?

**ឆ៖** បាទ នៅក្នុង -- បើខ្ញុំធ្វើមេឃុំក្នុងឆ្នាំ១៩៧៩ មកឆ្នាំ៨២ ធ្វើមេឃុំតាភេម។ ហើយពួកអ្នកជាប់និន្នាការខ្មែរក្រហមទាំងអម្បាលម៉ាន គេចាប់យកទៅកសាង កែប្រែឲ្យរៀនសូត្រនៅកោះអណ្តែត។ បាទ មានគុកគេមួយនៅកោះអណ្តែតហ្នឹង។

[១១:១២:៤៥]

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅដល់ការសម្លាប់នៅក្រាំងតាចាន់ នៅក្នុងកិច្ចសម្ភាសន៍២០០៨ គឺ

ឯកសារ E3/5153 ទំព័រ 00172045, ខ្មែរ 00205091, អង់គ្លេស 002056 *(ស៊ីក)* លោកបានឆ្លើយដូចខាងក្រោមនេះអំពីការសម្លាប់នៅក្រាំងតាចាន់។ សូមដកស្រង់៖ “ទីកន្លែងសម្លាប់មនុស្សប្រហែលជា ១០០ម៉ែត្រពីគុក។ ខ្ញុំគេប្រើឲ្យខ្ញុំអូសសាកសពដែលជិតស្លាប់ ឬក៏ស្លាប់ ដោយពេលគេវាយដំទៅកន្លែងដែលសម្លាប់មនុស្សហ្នឹង។ នៅឯទីតាំងសម្លាប់មនុស្ស ខ្ញុំឃើញអ្នកយាមវាយអ្នកទោសជាមួយនឹងដំបងឫស្សី ហើយជួនកាលអារ-កអ្នកទោសតែម្តង។ ខ្ញុំឃើញគេប្រើដាវដើម្បីកាត់ក្បាលអ្នកទោសជាញឹកញាប់”។ បញ្ចប់ការដកស្រង់។ សូមលោកជម្រាបផងថា អ្នកណាដែលជាអ្នកប្រើលោកឲ្យជួយអូស ឲ្យជួយទាញខ្មោចយកទៅកន្លែងគេកប់ហ្នឹង?

**ឆ៖** អ្នកដែលប្រើយើងឲ្យទៅអូសនោះ គឺមេកងឈ្លបនៅទីនោះ ហើយមេពិឃាដនៅកន្លែងហ្នឹង ដែលយើងចេះតែខ្លាចគេរហូត សព្វថ្ងៃនៅមានជីវិតទេទាន ប៉ុន្តែទុរន់ទុរាចាស់ណាស់ទៅហើយ គឺឈ្មោះ ដាំ មិនដឹងត្រកូលអីទេ ឈ្មោះ ដាំ មាឌធំមាំខ្ពស់។ ហ្នឹងគេអ្នកប្រើកម្លាំងរបស់គេ មិនមែនតែ ដាំ ហ្នឹងមួយទេ មានគ្នាគេប្រហែលជាជិត២០នាក់ នៅកន្លែងហ្នឹងសម្រាប់បម្រើការងារក្នុងការសម្លាប់មនុស្ស ហើយប្រើមនុស្សឲ្យទៅកាប់រណ្តៅសម្រាប់កប់មនុស្ស។

[១១:១៥:00]

**ស៖** សូមលោកជម្រាបជូនអង្គជំនុំជម្រះផងថា តើការសម្លាប់ហ្នឹង វាកើតឡើងដោយរបៀបណាដែរ?

**ឆ៖** ការសម្លាប់នេះច្រើនរបៀបណាស់។ ពេលខ្លះអ្នកទោសយកទៅដល់កន្លែងហ្នឹង សម្លាប់ភ្លាម អត់សួរ។ មិនដឹងជាបានព័ត៌មានពីណាមកទេ។ ខ្ញុំជម្រាបអង្គប្រជុំជំនុំជម្រះ ថ្ងៃមួយ ល្ងាចប្រហែលជាម៉ោងប្រាំ ខ្ញុំឃើញគេនាំនារីម្នាក់ដែលដឹកដៃកូនតូចអាយុប្រហែលជាបីឆ្នាំ កូនមួយពនឹងដៃបីនឹងដៃហ្នឹង ប្រហែលជាទើបនឹងកើតទេ ពីព្រោះម្តាយនៅធ្លាក់ឈាមតាមសំពត់។ គាត់ដើរអត់កើតទេព្រោះឈាមធ្លាក់មកសំពត់វាសើម គាត់ស្លៀកលើជង្គង់។ ហើយមកឈរនៅមុខ គេនាំមក នីរសារពីរនាក់ កាំភ្លើងពីរដើម នាំមកឈរនៅមុខមន្ទីរពេទ្យ -- នៅមុខកន្លែងឃុំឃាំងហ្នឹង អគារឃុំឃាំងហ្នឹង។ នីរសារម្នាក់ គេទៅជួបប្រហែលជាជួបអ្នកមេគេហើយ មកដល់កន្លែងហ្នឹង គេប្រាប់គ្នាគេថា អត់ដាក់គុកទេ ក៏គេនាំនារីហ្នឹងទៅដល់អាគ្រលុកខាងត្បូងផុត ខាងកើតផុត នៅមន្ទីរក្រាំងតាចាន់ហ្នឹង។ ខ្ញុំនៅក្បែរមាត់ទ្វារមុខខាងត្បូងដែរ ខ្ញុំមើលទៅឃើញ។ ដំបូង ឈ្លបពីរនាក់ហ្នឹងក៏ដើរចេញពីហ្នឹង មានពីរនាក់ផ្សេងទៀត ទៅជួបនារីហ្នឹង នៅក្នុងក្រោមដើមអំពិលទឹកបាវាំងហ្នឹង ហើយមានដើមថ្នាំមួយនៅ

ពីខាងជើង។ វាទៅភើចកូននារីហ្នឹងដែលនៅបីនឹងដៃហ្នឹង បោកនឹងគល់ថ្នាន់ហ្នឹង បោះដាក់គ្រលុកហ្នឹងទៅ។ នាងនោះដួលៗ អាកូនធំហ្នឹង – កូនអាយុបី ប្រហែលជាបីឆ្នាំហ្នឹង យំ។ វាចាប់កូនហ្នឹង បោកនឹងគល់អំពិលបារាំងហ្នឹង បោះដាក់គ្រលុកហ្នឹងទៀត នារីហ្នឹងដួលសន្លប់ហើយ ប៉ុនវាវាយថែមពីរបីដំបងទៀត វានាំគ្នារុញទម្លាក់ក្នុងគ្រលុកហ្នឹងទៅ។ អ៊ីចឹងអត់បាច់ចាំជំនុំជម្រះអីដូចកន្លែងយើងនេះទេ គឺវាសម្លាប់អ៊ីចឹង! តែមិនដឹងជាព័ត៌មានហ្នឹង គេសម្រេចទោសហ្នឹងពីណាមក យើងក៏អត់ដឹងដែរ ឬសម្រេចក្នុងពេលដែលឈ្លបនាំទៅហ្នឹង ទៅសួរមេគេនៅក្រាំងតាចាន់ គេថាឲ្យសម្លាប់ទៅ ក៏វាសម្លាប់ទៅក៏វាមិនដឹងដែរអាហ្នឹង។ ខ្ញុំដែលជម្រាបនូវការស្មានណ៍ាទាន អ្វីដែលឃើញនឹងភ្នែកមែន ប៉ុន្តែយើងអត់ដឹងអស់អាថ៌ក្នុងរឿងហ្នឹងទេ។ បាទ អ៊ីចឹងខ្ញុំសូមជម្រាប សូមលោកឈ្លាសវៃដោយខ្លួនឯងផងទៅរឿងខ្ញុំនិយាយនេះ។

[១១:១៧:៥៤]

**ស៖** តើលោកអាចស្មានបានទេ គឺអ្នកទោសដែលលោកបានឃើញគេសម្លាប់នោះ ប្រហែលជាប៉ុន្មាននាក់ដែរលោក នៅឯក្រាំងតាចាន់ហ្នឹង?

**ឆ៖** ពេលដែលយើងជាប់នៅក្នុងមន្ទីរឃុំឃាំងនោះ យើងមិនអាចស្មានបានទេ។ មួយថ្ងៃមិនទាបជាង៥០នាក់ទេ គេសម្លាប់។ ហើយដូចខ្ញុំជម្រាបខាងដើម មិនមែននិន្នាការតែរឿងត្រឹមខ្មាំង លន់នល់ ខ្មាំងអីទេ គឺអ្នកនៅក្នុងជួរកម្មាភិបាលរបស់ខ្មែរក្រហមហ្នឹង ច្រើនជាងគេ។ ខ្លះដែលខ្ញុំស្គាល់ នៅក្នុងភូមិជាមួយគ្នា គឺខំបម្រើតាំងពីឆ្នាំ១៩៧០នោះ ក៏គេយកទៅសម្លាប់នៅកន្លែងហ្នឹងដែរ ហើយខ្លាំងបំផុតពេលឆ្នាំ១៩៧៥។

**ស៖** នៅពេលលោកនៅក្រាំងតាចាន់ លោកដែលធ្លាប់បានដឹងថា គេមានប្រើប្រាស់មីក្រូហ្វូនបំពងសំឡេងទេលោក?

**ឆ៖** នេះប្រាកដជាមានខ្លាំងណាស់។ បើកាលណាព្រលឹមឡើង ឬព្រលប់ឡើង គេចាក់មីក្រូក្បាលបួននោះ ឧបល័រ មិនមែនមីក្រូហ្វូន ប៉ុន្តែគេនិយាយនៅណា ក៏ថានៅឯណាដែរ ប៉ុន្តែគេចាក់ជាបទចម្រៀង ចម្រៀងបដិវត្តន៍គេហ្នឹង ចាក់លាន់ទាំងបួនហ្នឹង គឺសម្លាប់ចោលហើយថ្ងៃហ្នឹង រាប់រយនាក់ហើយ បាទ។ ចាក់នេះប្រហែលជាកុំឲ្យឮសូរស្រែកឡូឡា។ អ្នកដែលត្រូវទោសនោះ យ៉ាងម៉េចទេមិនដឹងទេ តែឮសូរចាក់មីក្រូ។ យើងឥឡូវចាក់មីក្រូ សប្បាយ តែចាក់មីក្រូនៅមន្ទីរក្រាំងតាចាន់ គឺទឹកភ្នែក។ សម្លាប់ច្រើនណាស់ មាន១០០នាក់ជាងហើយនៅក្នុងថ្ងៃដែលចាក់មីក្រូនោះ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ
ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

**ស៖** តើលោកចាំឈ្មោះកម្មាភិបាលខ្មែរក្រហមណាម្នាក់ពីភូមិរបស់លោកដែលលោកបានឃើញបានជួបគ្នានៅឯក្រាំងតាចាន់ទេ?

**ឆ៖** លោកសួរនេះសំដៅចង់ថាអ្នកទៅក្រាំងតាចាន់ហ្នឹងជាប់ទោសជាមួយគ្នា ឬមួយអ្នកដែលនៅធ្វើការនៅមន្ទីរក្រាំងតាចាន់?

**ស៖** គឺអ្នកដែលជាប់ឃុំឃាំងជាប់គុកនៅឯក្រាំងតាចាន់ជាមួយលោក ហើយជាអ្នកភូមិរបស់លោក?

**ឆ៖** បាទ មានច្រើនណាស់ ប៉ុន្តែគាត់ស្លាប់អស់ទៅហើយ មិនបាននៅរស់ទេ។

**ស៖** តើថ្ងៃនេះ លោក -- នៅថ្ងៃនេះ លោកអាចនៅចាំឈ្មោះអ្នកទាំងនោះខ្លះៗបានទេ?

[១១:២១:៣០]

**ឆ៖** បាទ ចាំឈ្មោះបានប្រាកដទាន។ បាទ គឺទី១ គឺព្រះរាជអាជ្ញា សួន ជាព្រះរាជអាជ្ញានៅខេត្តតាកែវ សាលាដំបូងខេត្តតាកែវ។ អ្នកស្រុក សៅ ជាមេឃុំនៅក្នុងឃុំសំរោង ពេលដែលគេរំដោះពួកខ្មែរក្រហមរំដោះឃុំរបស់គាត់នៅក្នុងកណ្ដាប់ដៃនៃខ្មែរក្រហម ក៏រត់ចូលទៅក្នុងទីក្រុងតាកែវជាមួយពួក លន់ នល់។ ហើយអាសួងង់ សួង ដែលគាត់នៅធ្វើការនៅខេត្តតាកែវរហូត ទាល់តែធ្លាយបែកតាកែវហ្នឹង ក៏យកខ្លួនគាត់មកតែម្ដងបាទ។ និងក្មេងៗដែលនៅរៀនឯភ្នំពេញនោះ ថ្ងៃដែលបែក១៩៧៥ ខែមេសាហ្នឹង គឺច្រើនណាស់ដែលមក ហើយស្គាល់បាទ មកនៅមន្ទីរក្រាំងតាចាន់។ ព្រោះថាខ្ញុំឃើញដូចជាមួយចំនួនធំដែលខ្ញុំសួរវាទៅវាថាខ្ញុំគេយកមកដាក់នៅវត្តចំប៉ាៗ ហើយបានគេបញ្ជូនមកមន្ទីរក្រាំងតាចាន់នេះ។ ខ្ញុំថាម៉េចចុះចាំឆ្លើយគេឲ្យពិតធ្វើអី កុហសគេខ្លះទៅដើម្បីឲ្យនៅរស់។ គេថាកុហកណាបងបើគេយកពួកគេយកពួកយើងដែលស្គាល់ៗគ្នាទៅអង្គុយមួយរង់អ៊ីចឹង។ ហើយគេយកម្នាក់ចេញទៅ គេសួរ "មើលអ្នកឯងស្គាល់គ្នាទេ១០នាក់ហ្នឹង?" យើងថា "ស្គាល់ៗ"។ គេយកមកអង្គុយរង់គ្នាអ៊ីចឹង គេយកម្នាក់ចេញទៅ។ មួយសន្ទុះ គេយកម្នាក់ហ្នឹងមកឲ្យអង្គុយហ្នឹងវិញ គេយកម្នាក់នៅបៀតហ្នឹងយកទៅទៀត យកអាម្នាក់នៅក្បែរហ្នឹងទៅទៀត យកមក គេយកអាអ្នកទី១ដែលយកទៅសួរមុន គេថា "នែ៎! អាអ្នកដែលគេយកទៅក្រោយនេះប្រាប់អ្នកឯងអស់ហើយ អ្នកឯងធ្វើអីធ្វើការអីអ្នកឯងធ្វើការនៅឯណាៗគេប្រាប់អស់ហើយ។ បើអ៊ីចឹងនិយាយឲ្យត្រង់មក អង្គការឲ្យរស់ បើនិយាយមិនត្រង់គឺស្លាប់"។ សួរទាល់តែអស់ទាំងអស់គ្នានោះ។ ហើយយកទៅសម្លាប់ទាំងអស់ហ្នឹងតែម្ដង ទាំង១០នាក់ហ្នឹង។ នែ៎! ល្បិចសួររបស់ខ្មែរក្រហមខ្លាំងអ៊ីចឹង។

[១១:២៣:៥២]

**ស៖** បាទ សូមអធ្យាស្រ័យលោក ដែលខ្ញុំរំខានលោក ប៉ុន្តែដោយសារតែខ្ញុំមានពេលវេលាតិចណាស់ ហើយខ្ញុំចង់បានព័ត៌មានឲ្យបានច្រើន។ ខ្ញុំសួរអំពីឧប្បត្តិហេតុនៃការវាយដំស្លរចម្លើយនៅក្រាំងតាចាន់។ លោកបានរៀបរាប់នៅក្នុងឯកសារ D25/24ហ្នឹង ត្រង់ទំព័រ 00163459 ហើយខ្មែរ 00223456, អង់គ្លេស 00178094។ នេះគឺអ្វីដែលលោកបាននិយាយបានឆ្លើយ។ សូមដកស្រង់៖ --

**ប្រធានអង្គជំនុំ៖**

ឈប់សិន! សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ដើម្បីជាមតិខ្ញុំបាទ ខ្ញុំដឹង ខ្ញុំចង់ឡើងជំទាស់តាំងពីមុននោះ ទាក់ទងទៅនឹងការសម្លាប់ការប្រហារជីវិតនេះ។ មាន -- មិនមានអ្វីដែលត្រូវអានចម្លើយពីឯកសារហ្នឹងហើយសូមសួរឲ្យសាក្សីបញ្ជាក់យ៉ាងដូច្នេះទេ។ ព្រះរាជអាជ្ញាគួរតែសួរសំណួរបើកតែម្តងពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ណាមួយមិនមែនគ្រាន់តែអានចេញពីឯកសារហើយ សួរឲ្យសាក្សីឆ្លើយថា វាអ៊ីចឹង ឬក៏អត់នោះទេ។

**លោក ត្រាវិស ហ្វារ៖**

លោកប្រធាន ខ្ញុំសូមធ្វើការឆ្លើយតប។ យើងមានការអនុវត្តទៅតាមអ្វីដែលធ្លាប់បានធ្វើនៅក្នុងការជំនុំជម្រះ។ មិនគួរណាឡើងជំទាស់នូវអ្វីដែលយើងធ្លាប់បានអនុវត្តធ្លាប់បានធ្វើកន្លងមក ដោយសារតែខ្ញុំចង់បានព័ត៌មានបន្ថែមទើបខ្ញុំបានអានចេញអំពីឯកសារនេះ។ សូមអរគុណលោកប្រធាន។

[១១:២៥:៤៨]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ សម្រាប់-- ខ្ញុំសូមឆ្លើយតបខ្លីទេ ដើម្បីឆ្លើយទៅនឹងតំណាងសហព្រះរាជអាជ្ញា។ គឺថាមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅៗពេលដែលពាក់ព័ន្ធទៅនឹងពេលវេលាជាក់លាក់ណាមួយ សំណួរគួរសួរជាសំណួរបើកជាជាងការសួរសំណួរបិទ។ នេះគឺជាសេចក្តីសម្រេច បានសម្រេចឡើងដោយលោកចៅក្រម លោកស្រីចៅក្រម ខាតវ៉ាយថ៌ ដែលគាត់បានសម្រេចផ្ទាល់មាត់នាពេលនោះ។ ប៉ុន្តែពេល -- ប៉ុន្តែក៏ខ្ញុំយល់ថាពេលណាយើងគួរសួរសំណួរបើក ពេលណាយើងគួរសួរសំណួរបិទ បាទ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២៧:០៨]

**ប្រធានអង្គជំនុំ៖**

បាទ នេះជាសំណួរបញ្ជាក់ដើម្បីឲ្យបំភ្លឺបន្ថែមលើសំណួរដែលបានសួររួចហើយប៉ុណ្ណោះ។ ដូច្នេះ សេចក្ដីជំទាស់របស់លោក វ៉ិចទ័រ កូប៉េ លើសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ អំមិញគឺមិនត្រឹមត្រូវទេ។ សាក្សីត្រូវឆ្លើយតបទៅនឹងសំណួរដែលនឹងសួរដោយសហមេធាវី -- ដោយ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

សូមអញ្ជើញលោកតាំងសំណួរឲ្យបានជាក់លាក់ទៅ ហើយដើម្បីឲ្យសាក្សីស្ដាប់បាន។

**លោក ត្រាវិស ហ្វារ៖**

បាទ លោកប្រធាន ខ្ញុំនឹងអនុវត្តតាម។

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** លោកសាក្សី ខ្ញុំសូមអានផ្នែកមួយនៃចម្លើយដែលគេបានសម្ភាស ហើយខ្ញុំនឹងសួរសំណួរ ពីរបីទៅត្រង់ផ្នែកនេះ។ ចំណុចនេះគឺរៀបរាប់អំពីព្រឹត្តិការណ៍នៅក្រាំងតាចាន់។ គឺអ្វីដែលលោកនិយាយ គឺដូចនេះ សូមដកស្រង់៖ "មានស្ត្រីបីនាក់ មកពីស្រែអំបិលដែលគេបានវាយដំ គេបានស្រាតខោអាវ ទាំងអ្នកទោសនោះចេញ ហើយគេបានចាក់អាស៊ីតដាក់លើស្ត្រីទាំងអស់នោះ។ ចាក់ទឹកហើយអូសស្ត្រី នោះចេញទៅក្រៅទាំងស្រាតនទលគោក។ ខ្ញុំបានឃើញព្រឹត្តិការណ៍នេះផ្ទាល់ភ្នែក"។ បញ្ចប់ការដក ស្រង់។ សំណួររបស់ខ្ញុំ តើលោកបានឃើញព្រឹត្តិការណ៍ហ្នឹងពិតប្រាកដនៅកន្លែងណា? ព្រឹត្តិការណ៍ នៃការវាយដំធ្វើទារុណកម្ម ដែលលោកបានឃើញនោះ ឃើញពិតប្រាកដនៅត្រង់កន្លែងណាមួយនៃ ក្រាំងតាចាន់ហ្នឹង?

[១១:២៨:៤៥]

**ឆ៖** មន្ទីរឃុំឃាំងនៅក្រាំងតាចាន់ មានប្រវែងបណ្ដោយប្រហែលជា ២០ម៉ែត្រ ទទឹងប្រហែល ជា៤ម៉ែត្រ ដែលយើងជាប់គុកខ្សែខ្នោះតែមួយ ខ្នោះដៃ។ ខាងលិចនេះ មានរោងមួយជាប់នៅក្នុងគុកនេះ ជញ្ជាំងស្លឹកដូង។ អ្នកទោសទាំងអស់ទៅអង្គុយមើល ដោយអង្គុយផ្ទាល់ដី។ ពួកវាអង្គុយលើកំណាត់កង់ ដើមដូងៗ។ ពេលនោះគេឲ្យយើងទៅអង្គុយតាំងព្រលប់។ អ្នកដែលគេឲ្យទៅអង្គុយនោះ គេចង់សម្លុត ទឹកចិត្តឲ្យភ័យខ្លាចដើម្បីនិយាយអ្វី និយាយពិត តែនិយាយមិនពិតគេធ្វើដូចនារីហ្នឹងអ៊ីចឹង ឲ្យយើងឃើញ ហើយយើងខ្លាច យើងភ័យ យើងនិយាយពិត។ ពេលនោះអ្នកទោសដែលត្រូវសួរចម្លើយថ្ងៃស្អែកទៅ

អង្គុយនៅទីនោះ។ ហើយនារីដែលគេនាំមកនោះ គេនាំមកអាក្រាត។ នារីនេះមានម្នាក់ឈ្មោះ នារីសៀត ដែលមានស្រុកកំណើតនៅភូមិតាប្រឹម ឃុំ-- ខ្ញុំភ្លេចឃុំហើយ ខាងស្រុកទ្រាំង។ ភូមិតាប្រឹម នារីនេះ ចូលធ្វើបដិវត្តន៍ហ្នឹងយូរហើយ ចូលទៅយូរហើយ តាំងពីខ្ញុំនៅក្នុងមន្ទីរពេទ្យ គេបំណងថាឲ្យនារីបីនាក់ហ្នឹងមកធ្វើរៀនពេទ្យដែរ។ តែមិនដឹងយ៉ាងម៉េចបានជាគេឲ្យទៅនៅស្រែអំបិល។ បីឆ្នាំបានឃើញនារីនេះមកចូលក្នុងគុកក្រាំងតាចាន់ គេយកទាំងស្រាតនទល។ នាំចូលទៅ។ អ្នកដែលនាំចូលទៅគ្នាគេបីនាក់ ម្នាក់កាន់ដង្កាប់ ម្នាក់កាន់ដបទឹកអាស៊ីត ម្នាក់ទៀតគេមានទឹកយួរទៅ ពីដើម -- កាលពីពេលនោះ មានថាំងឈើ យួរថាំងឈើហ្នឹងចូលទៅ។ ប្រហែលជាទឹកហ្នឹងទឹកសាបទេ ហើយចូលទៅដល់គេឲ្យនារីហ្នឹង អង្គុយផ្ទាល់ដី ស្រាតអស់ហើយ គ្មានខោស្លីប លីអូអីទេ អត់ទេ ស្រាតទាំងតែម្តង។ គេយកដង្កាប់នេះ ច្របាច់ឮសូរខ្ទបៗកាន់ដើរចូលទៅសំដៅនារីនោះ។ គេចាប់ដង្កាប់នឹងទាំងច្រមុះ ស្លឹកត្រចៀក ថ្ពាល់ កន្ត្រាក់។ សាច់ត្រង់ណាដែលគេចាប់ទៅជាប់ សាច់មុខមនុស្សហ្នឹង បបូរមាត់ដាច់ឃើញចេញឈាមៗ។ ក្រោយចេញឈាមនារីនោះ គ្រាន់តែលាន់មាត់ថា "អឺស!ៗ"។ ហើយម្នាក់ដើរចូលទៅទៀតគេយកទឹកអាស៊ីតហ្នឹងក្រវីដាក់ ប្រកាច់ ននាលពេញដីទាំងអស់គ្នា។ អត់ហ៊ានស្រែកថា "អូយ!អីមួយម៉ាត់" ទេ។ យើងទាំងអស់គ្នា ស្លុតចិត្ត ដែលនៅអង្គុយហ្នឹង គ្នាប្រហែលជាជាងៗ ១០នាក់ ខ្ញុំមិនបានរៀបច្បាស់ដែរ។ ប្រហែលជាជាង១០នាក់ ដែលបំណងសួរចម្លើយនៅពេលក្រោយទៀត។ ហើយគេលើកនារីនោះ យកទឹកៗត្រជាក់យើងទៅជះដាក់។ នារីបីនាក់នៅសន្លប់ដដែល -- ពីរនាក់ នារីម្នាក់ងើបអង្គុយ។ ងើយអង្គុយ គេសួរៗថា៖ "អ្នកណាដែលទៅបំពាក់បំប៉នឲ្យនាងឯងនៅស្រែអំបិល? ឈ្មោះអី? នារីនោះ ដូចជាឡេងឡង់និយាយអីនិយាយលែងកើតអីហើយ អត់ដឹង គេក៏សម្រេចលើកនារីនោះ ជញ្ជាំងស្លឹកដូងពីខាងលិច មានទំពក់ដែកលានចេញមកស្រួចៗ គេយកថ្ពក់ត្រង់ចង្កាហ្នឹងទម្លាយទៅមាត់ បង្ខិលផ្ងាមកអីអ៊ីចេះវិញ។ ហើយម្នាក់ទៀត គេចូលមកកំបិតគេសស្វាចរះពីដើមទ្រូងហ្នឹងទៅទល់គ្នានឹងឆ្អឹងថ្ងាសខាងក្រោមនេះ។ ភើចចេញមកកន្ត្រាក់យកថ្លើមនឹងជាប់បេះដូងមួយផង។ ភើចចេញមក យួរដើរកាត់ក្បាលយើងទាំងអស់គ្នា។ ផ្លូវដើរមាន ប៉ុន្តែគេយួរចង់ឲ្យថ្លើមហ្នឹងដែលមានជាប់ដោយឈាមនិងទឹករំអិល បោកក្បាលយើងទាំងអស់គ្នា អ្នកអង្គុយព្រោងព្រាតហ្នឹង អ្នកអង្គុយចាំមើលហ្នឹង ផ្ដាប់ៗអ៊ីចឹងទៅ។ គេទៅដល់មាត់ទ្វារគេថា -- ហៅគ្នាគេ ខ្ញុំភ្លេចឈ្មោះហើយ។ "អ្អែង!យកទៅឆាអីក"។ អ៊ីចឹងពាក្យថា "ឆាអីក" នេះខ្ញុំមិនទាន់សួរគេឲ្យដឹងថាឆាយ៉ាងម៉េចទេ។ "យកឆាអីក! ទុកផឹកស្រា ហើយប្រមាត់នេះ អ្អែងហាលទុកឲ្យអញ"។ គេធ្វើអ៊ីចឹងនារីទាំងបីនាក់។ យើង

ទាំងអស់គ្នាជាង១០នាក់នៅអង្គុយទីនោះ។ នៅអង្គុយមើលសម្លឹងតែហ្នឹងរហូតទល់ភ្លឺ។ យើងឃើញនារីម្នាក់ប្រសឹកងឹកៗ អ៊ីចឹងទៅ។ ដែលភើចយកថ្លើមបាត់ បេះដូងបាត់ហើយហ្នឹង ជួនបើកភ្នែក ជួនបិទមិនដឹងរឿងអីទេ។ ខ្ញុំជាពេទ្យ ខ្ញុំយល់មិនដល់ ហើយយើងនៅដល់ភ្លឺបានគេមកហៅ យើងទៅដាក់ក្នុងខ្មោះ។ ក្រោយមក គេហៅយើងម្នាក់មួយៗទៅសួរចម្លើយ។ សូមអស់ហើយបាទ។

[១១:៣៤:២០]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដល់ពេលសមស្របនឹងសម្រាកហើយ ហើយអង្គជំនុំជម្រះគ្រាន់តែសូមធ្វើការកត់សម្គាល់ថា យុត្តាធិការពេលវេលាដែលយើងធ្វើសវនាការ គឺអង្គហេតុដែលកើតឡើងនៅក្នុងចាប់ពីថ្ងៃទី១៧ មេសា ៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ៧៩។ ដូច្នេះភាគីប្រយ័ត្ន -- ភាគពាក់ព័ន្ធប្រយ័ត្នប្រយែងអំពីសំណួរទាំងឡាយជួនកាលសួរច្រើន ប៉ុន្តែវាជាសំណួរដែលមិនពាក់ព័ន្ធជាមួយនឹងអង្គហេតុយុត្តាធិការដែលអង្គជំនុំជម្រះដំណើរការសវនាការទេ។ នេះសូមបញ្ជាក់ឲ្យបានច្បាស់លាស់។

ហើយឥឡូវនេះដល់ពេលវេលាសមស្របនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ត្រឹមនេះ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះសូមអញ្ជើញចូលវិញដើម្បីបន្តិចកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យនៅបន្ទប់សម្រាកឬក៏កន្លែងណាមួយសម្រាប់សាក្សីនៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់នេះ ហើយឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងមួយសាមសិបនាទី គឺអញ្ជើញគាត់ឲ្យចូលមុនអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

ហើយបង្គាប់ឲ្យមន្ត្រីអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់សម្រាកនៅខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់មកចូលរួមសវនាការនៅរសៀលនេះវិញ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៥ នាទី ដល់ម៉ោង១៣:៣៣ នាទី)*

[១៣:៣៣:៤៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ ហើយសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានពេលវេលាពីនេះទៅត្រឹមឈប់សម្រាកនៅរសៀលនេះ ត្រូវម៉ោងសម្រាកៗនៅពាក់កណ្ដាលរសៀលនេះ។

**លោក ត្រាវិស ហ្សារ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ត្រាវិស ហ្សារ៖**

**ស៖** លោកសាក្សី ខ្ញុំសូមចូលទៅដល់ការដោះលែងខ្លួនលោកចេញពីមន្ទីរសន្តិសុខក្រាំងតាចាន់ គឺឯកសារ D25/24។ នៅត្រង់ទំព័រ 00163458 ហើយនិងខ្មែរ 00223453 ហើយជាអង់គ្លេស 00178092។ លោកបានឆ្លើយដូចតទៅនេះ។ ឆ្លើយអំពីថា តាម៉ុក គឺបានដោះលែងលោកចេញពីមន្ទីរសន្តិសុខក្រាំងតាចាន់។ លោកបាននិយាយថា គាត់បាន -- "តាម៉ុក បានទៅក្រាំងតាចាន់ ទៅយកខ្ញុំចេញមក គាត់ទៅជាមួយ តាជឹម គឺជិះម៉ូតូសេអិលទៅ។ ពួកគាត់មិនបានចូលទៅក្នុងគុកទេ ប៉ុន្តែហៅជាងថា តើឪកទ័រហ្នឹងនៅឯណា? ដោះលែងគាត់ទៅ។ គេបានឲ្យបាយទឹកខ្ញុំ ហើយពួកគាត់ក៏ចេញទៅត្បូង ដល់ពេលគាត់ត្រឡប់មកពីទិសខាងត្បូងវិញ គាត់យកខ្ញុំចេញពីក្រាំងតាចាន់ចេញទៅជាមួយគាត់"។ ដូច្នេះ ខ្ញុំសំណួរទី១របស់ខ្ញុំ ប្រសិនណាជាលោកអាចឆ្លើយបាន។ តើ តាជឹម ជាអ្នកណាដែលទៅក្រាំងតាចាន់ជាមួយ តាម៉ុក ហ្នឹង?

[១៣:៣៦:១២]

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** ក្រោយពេលដែលខ្ញុំចាកចេញពីគុកក្រាំងតាចាន់ បានដឹងថា តាជឹម ជាគណៈស្រុក១០៨ ពេលនោះ -- អ៎! គណៈស្រុកត្រាំកក់ហ្នឹង ប៉ុន្តែខ្ញុំមិនភ្លេចលេខហើយ មិនដឹងគេប្រើជាលេខក្នុងពេលនោះ។

**ស៖** សូមអរគុណ ហើយសូមឆ្លើយឲ្យបានខ្លីបន្តិចលោក។ តើ តាម៉ុក យកលោកទៅឯណា នៅ

គាត់ទៅយកលោក ដោះលែងចេញពីមន្ទីរសន្តិសុខក្រាំងតាចាន់នុ៎ង?

**ឆ៖** យកមកមន្ទីរពេទ្យ២២-ក ២២-គ និង២២-ឃ ខាងជើងវត្តពត់ដោះ គឺមន្ទីរពេទ្យភូមិភាគ។

**ស៖** បាទ សូមអរគុណ។ តើ តាម៉ុក ដែលនិយាយប្រាប់លោកទេ ធ្វើម៉េចបានជា តាម៉ុក មានលទ្ធភាពទៅដោះលែងលោកបាន?

**ឆ៖** ខ្ញុំដូចជាមិនអាចដឹងដែរក្នុងរឿងនេះ ប៉ុន្តែពេល តាម៉ុក យកមកហ្នឹងគឺ តាម៉ុក ត្រូវការខ្ញុំខ្លាំងណាស់។ បើសិនណាវ៉ាដ្យូក្រាហ្វីមួយដែលរើបានពីខេត្តកំពង់ស្ពឺមកគេរៀបចំអត់កើតផង។ ដូច្នេះប្រហែលជាគាត់យល់ថា ខ្ញុំជំនាញខាងហ្នឹង មកឲ្យរៀបចំម៉ាស៊ីនវ៉ាដ្យូក្រាហ្វីហ្នឹង ដើម្បីប្រើប្រាស់នៅក្នុងមន្ទីរពេទ្យពេលហ្នឹង។

[១៣:៣៧:៥៦]

**ស៖** ក្រៅពី តាម៉ុក តើលោកធ្លាប់បានឃើញមេដឹកនាំខ្មែរក្រហមណាផ្សេងទៀត<ទេ> នៅ<ពេលដែលលោកនៅឯក្រាំងតាចាន់>? ហើយបើធ្លាប់បានឃើញ តើមេដឹកនាំនោះជាអ្នក<ណា>ដែរ?

**ឆ៖** ខ្ញុំមិនដែលស្គាល់សោះ ហើយពីមុនមកក៏មិនដែលឮឈ្មោះមនុស្សនេះដែរ។ ស្រាប់តែពេលមួយ រសៀលប្រហែលជាម៉ោងពីរ ឃើញគេអើតឈូសៗមកចំកន្លែងខ្ញុំ ព្រោះខ្ញុំអង្គុយជាប់នៅមាត់ទ្វារគុក។ គេថា "តាជា ណ៎! តាជា" តែខ្ញុំមើលឆ្ងាយ ដីចម្ងាយប្រហែលជា៨០ម៉ែត្រ ប៉ុន្តែខ្ញុំនៅវ័យក្មេងដែរមើលឃើញមិនច្បាស់ដែរទេ គេថា "តាជា" ហើយខ្ញុំពីមុនមកក៏មិនដែលស្គាល់ តាជា ដែរ។ ហើយក៏ខ្ញុំមិនដឹងថា ជា ហ្នឹងវាមានច្រើនដែរ ទៅដល់មន្ទីរពេទ្យ២២-ក, គ ហ្នឹងមិត្តមួយឈ្មោះ ជា ដែរ មកពីហាណូយ ប៉ុន្តែគាត់បច្ចេកទេសខាងពេទ្យ។ តែគេនិយាយថា "តាជា" នោះ – គេហៅថា "តា" នៅក្នុងរបប តាម៉ុក នៅក្នុងរបបខ្មែរក្រហម ប្រហែលជាថ្នាក់មេដឹកនាំក៏មិនដឹង ប្រហែលជាអ៊ីចឹងហើយព្រោះគេហៅ "តា" បាទ។

**ស៖** លោកទើបតែប្រាប់ថា លោកស្ថិតនៅក្នុងចម្ងាយប៉ុន្មាននៅពេលឃើញបុគ្គលរូបនោះ។ សូមលោកជម្រាបមើល តើមានចម្ងាយប៉ុនណាដែរពីកន្លែងលោកហ្នឹងទៅកន្លែងឃើញលោកឃើញបុគ្គលម្នាក់ដែលទើបនិយាយអម្បាញ់មិញ?

[១៣:៣៩:៤១]

**ឆ៖** តាជា គេមិនដែលទៅបៀតគុកនោះទេ។ គេដើរជិតមន្ទីររបស់កម្មាភិបាលថ្នាក់ខ្ពស់របស់គេនៅខាងឆ្ងាយៗពីកន្លែងអគារគុកហ្នឹងប្រហែលជា ៨០ម៉ែត្រទៅ ៧០ម៉ែត្របាទ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ
ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

**សៈ** ហើយលោកក៏និយាយឈ្មោះ តាជា។ តើធ្វើម៉េចបានលោកស្គាល់ថា បុគ្គលរូបនោះឈ្មោះ តាជា?

**ឆៈ** កម្មាភិបាលថ្នាក់ស្រុកមួយរូបដែលនៅជាប់គុកក្រាំងតាចាន់ហ្នឹងដែរ គេធ្លាប់ធ្វើការជាមួយពួកគេហ្នឹង មិនដឹងជាពីពេលណាមកទេ គេថា "តាហ្នឹង តាជា"។ ហើយខ្ញុំក៏សន្ទតថា ប្រហែលជាកម្មាភិបាលជាន់ខ្ពស់របស់ខ្មែរក្រហមហើយ តាជា ហ្នឹង។ នឹកស្មានទេណ៎ា មិនប្រាកដ។

**សៈ** នៅក្នុងចម្លើយរបស់លោកត្រង់E3/5153 ទំព័រជាភាសាខ្មែរ 0017044*(ស៊ីក),* អង់គ្លេស 00450-- ហើយបារាំង 00205094។ លោកបានរៀបរាប់នៅក្នុងឱកាសមួយផ្សេងទៀត នៅក្នុងអំឡុងនៃកម្ពុជាប្រជាធិបតេយ្យនៅពេលដែលលោកបានឃើញ នួន ជា ថ្លែងសុន្ទរកថា។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថានៅពេលនោះគាត់មានបានឧទ្ទេសនាមឈ្មោះរបស់គាត់ទេ មុនពេលគាត់ថ្លែងសុន្ទរកថានុ៎ង?

[១៣:៤១:៤៩]

**ឆៈ** បាទ តាជា ថ្លែងសុន្ទរកថាមិនមែននៅក្នុងមន្ទីរក្រាំងតាចាន់ទេ គឺខ្ញុំជាប់នៅក្នុងក្រាំងតាចាន់ ១៩៧៥។ ១៩៧៥នេះ ក្នុងពាក់កណ្ដាលខែមីនា និងដើមខែមេសា ២៩ថ្ងៃ។ ដល់ខ្ញុំចេញពីមន្ទីរក្រាំងតាចាន់ទៅវិញ គេអត់ខ្ញុំមកនៅផ្ទះទេ អត់ឲ្យនៅផ្ទះនៅភូមិមហាសេនាហ្នឹងទេ។ គេជម្លៀសខ្ញុំឲ្យទៅនៅឆ្ងាយពីនុ៎ងប្រហែលជាជាង២០គីឡូម៉ែត្រពីផ្ទះខ្ញុំ។ ពេលនោះ គេប្រមូលពួកដែល គេហៅថាពួក១៨ហ្នឹងណ៎ា មិនមែន១៧មេសា ដែលបែកចេញពីភ្នំពេញទៅទេ មិនមែនពួកក្រុម លន់ នល់ នោះទេ។ ទៅមើលសៀកនៅក្នុងទីក្រុងតាកែវ ហើយខ្ញុំក៏នៅឆ្ងាយពីទីក្រុងនោះប្រហែលជា២គីឡូទេ។ ឲ្យមកមើលសៀក សៀកហ្នឹង សុំនិយាយវែងបន្តិចចុះ សៀកហ្នឹងគឺក្រុមចិន សៀកនេះចម្លែកបាទ មានកង់មួយជើងតែមួយ នារីម្នាក់ហ្នឹងជិះលើកង់ដែលមានកែបជើងតែមួយហ្នឹង មានមនុស្សទៅឈរអមៗៗៗជាន់លើស្មាគ្នាហ្នឹង ម្ខាងប្រាំបី -- ម្ខាងបួនៗ ប្រាំបីនាក់។ តោងពីស្មាពីលើមួយ ឡើង១០នាក់ ១១នាក់ហ្នឹងធាក់កង់។ មុនដែលពេលសម្ដែងសៀកហ្នឹង តាមខ្ញុំមើលមុខមាត់គាត់ ខ្ញុំប្រហាក់ប្រហែលណាស់ប្រហែល តាជា ដែលជួបនៅក្រាំងតាចាន់ហ្នឹងណាស់។ គាត់ឡើងថ្លែងសុន្ទរកថាប្រហែលជា ៧ ឬ ៦ នាទីបាទ។ ហើយខ្ញុំចាប់អារម្មណ៍តែពាក្យប៉ុន្មានម៉ាត់នោះទេ គាត់ថា "ប្រទេសយើងសព្វថ្ងៃនេះ ជាប្រទេសកសិកម្ម ប៉ុន្តែយើងធ្វើប្រទេសនេះឲ្យទៅជាកសិឧស្សាហកម្ម"។ បាទ ខ្ញុំអត់ទាន់យល់ពាក្យអស់

ទាំងហ្នឹងទេ ព្រោះខ្ញុំរៀនច្រើនតែក្នុងភាសាបារាំង អ៊ីចឹងខ្ញុំមកបើកវចនានុក្រមមើល គឺកសិឧស្សាហ-កម្មហ្នឹងប្រហែល -- គឺធ្វើកសិកម្មផង គឺឧស្សាហកម្មផង។ អ៊ីចឹង ខ្ញុំនឹកសប្បាយចិត្តក្រោយពីការជាប់គុកក្រាំងតាចាន់ដែលសោកស្ដាយបំផុតនោះ ខ្ញុំនឹកឃើញថាប្រទេសកម្ពុជានឹងកសិឧស្សាហកម្មហើយ។ ផ្ទុយទៅវិញ សុំនិយាយបើករង្វង់ក្រចកបន្តិចទៅ--

[១៣:៤៤:២២]

**ប្រធានអង្គជំនុំ៖**

បាន។ហើយ សាក្សីមិនចាំបាច់ទេ សាក្សីឆ្លើយតបតែភាពចាំបាច់ទៅនឹងសំណួរដែលសួរបានហើយណា៎ បាទ។។

**សួរដោយលោក គ្រាវិស ហ្វារ៖**

**ស៖** ឥឡូវនេះ ខ្ញុំសូមបង្ហាញលោកអំពីព្រឹត្តិការណ៍ក្រោយការដោះលែងខ្លួនលោកចេញពីក្រាំងតាចាន់ភ្លាម។។ នៅក្នុងចម្លើយរបស់លោក E3/5153 ទំព័រ 00172400, ខ្មែរ 00245090, ជាអង់គ្លេស 00205095។ សំណួរសួរថាតើលោកធ្លាប់បានឃើញខ្មែរក្រហមទេក្រោយថ្ងៃ១៧ មេសា ៧៥ ក្រោយពីគេជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយដែលនៅពេលប្រជាជនទាំងនោះទៅដល់ត្រាំកក់? ហើយលោកឆ្លើយដូចតទៅនេះ សូមដកស្រង់៖ “ខ្ញុំបានឃើញ តាម៉ុក នៅវត្តចំប៉ាក្បែរផ្ទះរបស់ខ្ញុំនៅភូមិមហាសេនា ខ្ញុំអត់ស្គាល់មេដឹកនាំដទៃទៀតទេ ខ្ញុំដឹងថាប្រជាជនដែលមកវត្តចំប៉ាប្រហែល ៧០ភាគរយត្រូវបានសម្លាប់នៅក្រាំងតាចាន់ នៅក្របីព្រៃ នៅប៉ុស្ដិ៍១៦០ និងនៅមន្ទីរ។១៦០ នៅនិងមន្ទីរមួយទៀតនៅកន្ទួត”។ បញ្ចប់ការដកស្រង់។ សំណួរទី១របស់ខ្ញុំខ្លីទេ តើពីវត្តចំប៉ាទៅផ្ទះរបស់លោកមានចម្ងាយប្រវែងប៉ុន្មានដែរ?

[១៣:៤៦:១៤]

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បាទ បើគិតពីរបងវត្តមកផ្ទះខ្ញុំ ឆ្លងថ្នល់មួយប្រវែង ២០ម៉ែត្រ។

**ស៖** សូមលោកជម្រាបជូនអង្គជំនុំជម្រះថាតើវត្តចំប៉ាគេប្រើប្រាស់ជាអ្វីដែរ នៅពេលដែលគេជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយនៅពេលប្រជាជនទាំងនោះទៅដល់នៅ។ទីនោះនៅក្រោយថ្ងៃ១៧ មេសា ៧៥?

**ឆ៖** វត្តចំប៉ា គេប្រើជាមន្ទីររបស់ខ្មែរក្រហមសុទ្ធសាធទៅហើយ លែងវត្តហើយ គឺជាទ្រុងជ្រូក

នៅលើព្រះវិហារគេចិញ្ចឹមជ្រូក នៅតាមកុដិនាៗគឺជាគេដាក់កងកុមារ។ កងកុមារនេះមានប្រធានម្នាក់ៗ គេហៅគ្រូ ប៉ុន្តែអត់បានបង្រៀនអក្សរអីទេ។

**ស៖** តើខ្លួនលោកផ្ទាល់បានឃើញអ្នកដែលគេជម្លៀសហ្នឹងទៅដល់នឹងវត្តចំប៉ាហ្នឹង ផ្ទាល់ភ្នែកទេ?

**ឆ៖** បាទឃើញផ្ទាល់។

**ស៖** សូមលោកប៉ាន់ប្រមាណមើល តើអ្នកដែលគេជម្លៀសចេញពីក្រុងទៅដល់វត្តចំប៉ាហ្នឹងមានចំនួនប្រហែលជាប៉ុន្មានដែរ?

**ឆ៖** ពេលគេជម្លៀសមនុស្សចេញពីក្រុងភ្នំពេញទៅដល់វត្តចំប៉ា ពេលហ្នឹងខ្ញុំមិនទាន់រួចពីក្រាំងតាចាន់ទេ។ នៅក្នុងរយៈពេលប្រហែលជា ១២ថ្ងៃ ឬ១១ថ្ងៃហ្នឹងខ្ញុំនៅមន្ទីរក្រាំងតាចាន់ ឃើញគេបញ្ជូនមនុស្សខ្លះៗដែលខ្ញុំធ្លាប់ស្គាល់ទៅដល់ក្រាំងតាចាន់ហើយ។ ដល់ខ្ញុំត្រលប់មករួចពីក្រាំងតាចាន់មកវិញនោះ មកនៅ មកជួបផ្ទះខ្ញុំក្នុងគ្រួសារខ្ញុំ ពេលនោះមនុស្សអត់ទាន់ចេញអស់ពីវត្តចំប៉ាទេ បាទ គឺច្រើនណាស់មនុស្សនោះរាប់ពាន់បាទ ច្រើនពេកនៅក្នុងវត្តចំប៉ានោះ។ ខ្ញុំចេះតែនឹកស្មានស្ទើរតែមកអស់ពីភ្នំពេញបើមនុស្សនៅវត្តចំប៉ាប៉ុណ្ណឹងប្រហែលជាមិនអីចឹងទេ។

**ស៖** លោកបានឆ្លើយថាលោកបានឃើញ តាម៉ុក នៅវត្តចំប៉ា។ ថាតើគាត់កំពុងធ្វើអ្វី នៅពេលដែលលោកឃើញគាត់នៅឯវត្តចំប៉ាហ្នឹង?

[១៣:៤៨:៥៥]

**ឆ៖** ពេលឃើញ តាម៉ុក ហ្នឹងខ្ញុំអត់ដែលបានហ៊ានចូលទៅក្នុងកន្លែងគេនោះទេ កន្លែងពួកប្រជាជនភៀសខ្លួនគឺប្រជាជន១៧មេសាហ្នឹង យើងនៅតែផ្ទះឈរមើលទៅបាន យើងនៅក្រៅវត្តឈរមើលទៅបាន ប៉ុន្តែតាម៉ុកកំពុងតែខ្វែងខ្វាត់លើកដៃលើកជើងចង្អុលចុះឡើង ប្រហែលជាគាត់មានប្រសាសន៍យ៉ាងនេះយ៉ាងនោះអី យើងអត់ដឹងទេ អត់បានឃើញ អត់បានឮទេ គ្រាន់តែបានឃើញកាយវិការរបស់គាត់។

**ស៖** លោកបាន<លើកឡើងថាគាត់បាន>ធ្វើកាយវិការ <>និងនិយាយ<។> តើលោក<បានឃើញថា>តើគាត់ធ្វើកាយវិការ< និង>និយាយ<ជាមួយអ្នកណា>?

**ឆ៖** ខ្ញុំក្រោយពេលដែលគេជម្លៀសប្រជាជនចេញអស់--

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ
ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន ខ្ញុំបាទសូមបដិសេធចំពោះសំណួរនេះ -- សូមជំទាស់ចំពោះសំណួរនេះដោយយល់ឃើញថាជាប្រភេទសំណួរដែលនាំឲ្យសាក្សីធ្វើការសន្និដ្ឋាន ពីព្រោះសាក្សីមិនបានស្ដាប់ឮផ្ទាល់នូវអ្វីដែលជាសម្ដីរបស់ តាម៉ុក និយាយនៅពេលនោះទេ គ្រាន់តែឃើញពីចម្ងាយដែលសាក្សីបានបញ្ជាក់រួចហើយ។ ការឲ្យសាក្សីវាយតម្លៃថាតើមានន័យយ៉ាងណា និយាយយ៉ាងណានោះ វាជាការសន្និដ្ឋាន។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់នឹងសំណួរនេះជាការត្រឹមត្រូវ។ សំណួរនេះនាំឲ្យសាក្សីឆ្លើយស្មានៗមិនមានផលប្រយោជន៍ នៃការរួមវិភាគទាននៃការស្វែងរកការពិតនៅក្នុងរឿងក្ដីនេះទេ។ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ។

[១៣:៥០:៤៣]

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** លោកបានឆ្លើយថា លោកមិនបានចូលទៅតំបន់នោះទេ នៅថ្ងៃ -- ក្រោយថ្ងៃ១៧ មេសា ៧៥។ ហេតុអ្វីក៏លោកមិនអាចចូលទៅកន្លែងនុ៎ងបាន?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បាទ មានគេមកប្រាប់យើងហើយ ប្រជាជនដែលនៅក្នុងមូលដ្ឋាននោះ "អ្នកណាចូលទៅពាក់ព័ន្ធជួបបង ជួបប្អូន ជួបជីដូនជីតា ឪពុកម្ដាយ ដែលបែកចេញពីភ្នំពេញទៅ អ្នកនោះសន្និសម្ព័ន្ធជាមួយខ្មាំង" គេនិយាយអ៊ីចឹង។ គេផ្ដាច់មនោសញ្ចេតនាទាំងស្រុងរវាងបងប្អូន កូនប្រពន្ធ ម៉ែឪ អត់ឲ្យទៅទាក់ជាមួយជន១៨មេសា និងជន១៧មេសានេះទេ។

**ស៖** ហើយនៅក្នុងចម្លើយ ដែលខ្ញុំទើបដកស្រង់ក្នុងឯកសាររបស់សហចៅក្រមស៊ើបអង្កេត លោកនិយាយថា "អ្នកដែលគេភៀសខ្លួនប្រមូលផ្ដុំនៅវត្តចំប៉ាជាច្រើនត្រូវបានគេសម្លាប់ចោល"។ ហើយលោកឃើញសម្លាប់នៅក្រាំងតាចាន់ ក្របីព្រៃ នៅមន្ទីរ១៦០ និងមន្ទីរ២០៤។ ខ្ញុំក៏សូមសួរទីតាំងឧក្រិដ្ឋកម្មបីកន្លែងទៀតដែរ ដែលលោកបានលើកឡើងយកមកនិយាយ។ សូមលោកជម្រាបជូនអង្គជំនុំជម្រះ

សង្ខេប ថាតើក្របីព្រៃហ្នឹងគឺនៅកន្លែងណាដែរ?

**ឆ៖** បាទ ក្របីព្រៃនៅក្នុងឃុំសំរោង ភូមិក្របីព្រៃហ្នឹងតែម្ដង។

**ស៖** រួចចុះមន្ទីរ១៦០ហ្នឹងនៅឯណាដែរ? មានទីតាំងនៅត្រង់ណាដែរ?

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយតបសាក្សី!

[១៣:៥២:៥៣]

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** មន្ទីរ១៦០ហ្នឹងគឺទីតាំងនៅភូមិព្រៃក្ដួចបច្ចុប្បន្ននេះ គឺឃុំត្រពាំងក្រញូង។

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** ចុះមន្ទីរ២០៤ នៅទីណាដែរ ហើយជាអ្វីដែរ?

**ឆ៖** មន្ទីរ២០៤ នៅក្នុងឃុំអូរសារាយ តែមិនដឹងឃុំអីដែរ។

**ស៖** ហើយធ្វើម៉េចបានជាលោកដឹងថា អ្នកដែលគេជម្លៀសហ្នឹងត្រូវបានគេយកទៅសម្លាប់នៅទីតាំងទាំងនេះ?

**ឆ៖** ក្រោយពេលរំដោះ១៩៧៩ ខ្ញុំជាមេឃុំៗតាភេម។ ហើយពេលនោះ ឃុំព្រៃក្ដួចមិនទាន់មាន ឃុំត្រពាំងក្រញូងមិនទាន់មាន ឃុំអូរសារាយក៏មិនទាន់មាន។ អ៊ីចឹង ខ្ញុំត្រូវធ្វើការទៅដល់កន្លែងនោះ ហើយខ្ញុំទៅឃើញឆ្អឹងសាកសពរបស់មនុស្សដែលគេយកពិឃាដនៅក្នុងមន្ទីរ២០៤ ក៏ដូចជាមន្ទីរ១៦០ ក៏ដូចជាមន្ទីរព្រៃក្ដួច ក៏ដូចជាក្រាំងតាចាន់ដែរ ប៉ុន្តែក្រាំងតាចាន់កប់។ ឆ្អឹងទាំងអស់នោះកប់ ដោយខ្ញុំបានរួមជីករណ្ដៅជាមួយគេផង ចូលរួមអូសខ្មោចដាក់ក្នុងរណ្ដៅ ហើយលុបដីផង។ តែមន្ទីរទាំងអស់នោះ ឆ្អឹងចោលនៅកណ្ដាលវាល ជ្រូកព្រៃអូសយកទៅស៊ីនៅឆ្ងាយៗក៏មាន ឆ្កែចចកអូសយកទៅស៊ីនៅរតាត់រតាយជើងភ្នំក៏មាន។

[១៣:៥៤:៥៤]

**ស៖** សូមអរគុណលោក។ ឥឡូវនេះ ខ្ញុំសួរលោកអំពីប្រធានបទមួយផ្សេងទៀត គឺពីឆ្នាំ១៩៧៥ ដល់ ១៩៧៩។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកឆ្នាំ២០០៨ គឺ E3/5153 ត្រង់00172044 ហើយខ្មែរ 00205090, ជាអង់គ្លេស 00205094 លោកបានឆ្លើយអំពីការជួប តាម៉ុក នៅក្នុង -- នៅចន្លោះពី៧៥ ទៅដល់៧៩។ នេះគឺជាអ្វីដែលលោកបានឆ្លើយ។ សូមដកស្រង់៖ "ខ្ញុំបានជួប តាម៉ុក ជាញឹកញាប់

គាត់បានមកភូមិដែលខ្ញុំរស់នៅ ហើយខ្ញុំក៏បានជួបគាត់នៅការដ្ឋានការងារ។ ខ្ញុំជួបគាត់នៅឯបារាយ"។ បញ្ចប់ការដកស្រង់សម្ដី។ ខ្ញុំសូមឲ្យលោកផ្ដោតទៅកន្លែងការដ្ឋានការងារនៅពេលជួបលោកតាម៉ុកនៅឯការដ្ឋាន។ សំណួរទី១ តើការដ្ឋានហ្នឹងជាការដ្ឋានអ្វីដែរ នៅពេលដែលលោកបានជួប តាម៉ុក ចន្លោះពីឆ្នាំ១៩៧៥ ទៅ៧៩?

**ឆ៖** សំណួរលោកត្រង់នេះ បើខ្ញុំឆ្លើយខ្លី ក៏ពិបាកស្ដាប់ អស់លោកទាំងអស់។ បើខ្ញុំឆ្លើយពេកក៏ហួសពេលវេលា។ អ៊ីចឹងនៅក្នុងការដ្ឋានដែលខ្ញុំទៅធ្វើការនោះ គេអត់ឲ្យធ្វើពេទ្យទៀតទេ តែជួនខ្លះគេហៅមកក្នុងមន្ទីរពេទ្យខេត្តតាកែវ គេសួរអានេះគេសម្រាប់ធ្វើអី ថ្នាំនេះគេធ្វើអី ថ្នាំសម្រាប់ចាក់ ឬមួយកាច់ផឹក ឬមួយគេលេបយ៉ាងណា។ ហ្នឹងគេសួរម្ដងមួយយាម តែក្នុងការដ្ឋានធ្វើស្រែនោះ គឺគេឲ្យខ្ញុំបើកត្រាក់ទ័រមួយមានសណ្ដោងអូសរ៉ឺម៉ក និងម៉ាស៊ីនទៅបូមទឹកស្រែប្រាំង។ ជួនកាលគេឲ្យខ្ញុំទៅរួមជាពួកជាងដើម្បីបញ្ចាំងភ្លើងក្នុងពេលយប់ជីកប្រឡាយ។ យប់ឡើងឲ្យប្រជាជនជីកប្រឡាយ ថ្ងៃឡើងប្រជាជនទាំងអស់នោះត្រូវស្ទូងដក កាប់គាស់ធ្វើស្រែចម្ការ។

[១៣:៥៧:២៥]

**ស៖** ដូច្នេះលោកនិយាយអំពីម៉ាស៊ីនបូមទឹក ពីប្រជាជនស្ទូងស្រូវ ឬក៏ជីកប្រឡាយ ឬក៏លើកទំនប់។ តើប្រជាជននៅត្រង់កន្លែងនោះ គេធ្វើអ្វីខ្លះ?

**ឆ៖** ប្រជាជននៅកន្លែងនោះ គាត់លំបាកណាស់។ ខ្ញុំរាប់រៀបឲ្យលោកបានជ្រាប ប៉ុន្តែខ្ញុំថាកន្លែងណាក៏ដូចជាកន្លែងណាដែរ ឲ្យតែតំបន់ខ្មែរក្រហមកាន់កាប់ វាអ៊ីចឹងដូចតែគ្នា គឺធ្វើការគ្មានដាក់ដៃដាក់ជើងទេ គ្មានពេលវេលាសម្រាកទេ ហើយកូនតូចៗ អ្នកមានកូន យកទៅឲ្យយាយមើលក្នុងកូនមួយ -- ក្នុងយាយម្នាក់ ឲ្យមើលកូន១០នាក់ទៅ១៥នាក់។ ម៉ែឪត្រូវទៅស្ទូងទៅដក ទៅច្រូតទៅកាត់។ ស្រែធ្វើតាំងពីស្រែប្រាំង ស្រែវស្សា ស្រែបណ្ដែញទឹក។ ហើយចំណែកពួកខ្ញុំ គេឲ្យយុវជនចំនួន២០នាក់ថែទាំម៉ាស៊ីនបូមទឹកដាក់ស្រែ២០ ហើយខ្ញុំទទួលខុសត្រូវមើលលើយុវជននោះទាំងអស់។ ដើរចល័ត ចេះតែដើរអ៊ីចឹងទៅ មើលស្រែប្រាំងណាអត់ទឹកឲ្យបូមដាក់អ៊ីចឹងទៅ។ ម៉ាស៊ីនណាខូចត្រូវជួសជុល គេឲ្យក្រុមជាងជាមួយខ្ញុំមាន តាញ៉ឹង តាអីហ្នឹង គឺចំនួនបួននាក់ ជាងជួសជុលម៉ាស៊ីន។ ខ្ញុំសូមជម្រាបបើករង់ក្រចកជម្រាបលោកផងដែរ។ ខ្ញុំជំនាញពេទ្យ គេឲ្យទៅធ្វើយ៉ាងហ្នឹង តើពិបាកយ៉ាងណា។ យកផ្លូវរទេះភ្លើងទៅបរលើផ្ទល់ជាតិ តើពិបាកយ៉ាណា។ សូមអស់លោកជ្រាបផង។

[១៣:៥៩:១១]

**សៈ** ឥឡូវលោកបាននិយាយថាលោកបានឃើញ តាម៉ុក នៅកន្លែងការដ្ឋានណាមួយនៅក្នុងបណ្ដាការដ្ឋានទាំងនេះ។ តើ តាម៉ុក ធ្វើអ្វីនៅពេលដែលលោកឃើញនៅការដ្ឋានហ្នឹង?

**ធៈ** អរគុណណាស់ដែលបានសួរដល់កន្លែងនេះ។ តាម៉ុក ហ្នឹងជាមនុស្សមួយគួរឲ្យយកចិត្តទុកដាក់ទៅវិញ។ ខ្ញុំសូមសរសើរផងដែរក្នុងចំណោមខ្មែរក្រហម។ គាត់ចុះទៅការដ្ឋានជីកប្រឡាយ គាត់ដើរទៅក្លែងខ្លួនធ្វើឲ្យគេស្គាល់ថា តាម៉ុក ទេ។ ទៅដល់ បើឃើញមេកងណា នៅអង្គុយស្ងៀម គាត់ទៅសុំដងរែកគេ សុំបង្គីដែលទំនេរថាសូមរែកផង។ ប៉ុនដល់បានបង្គីនឹងដករែក ពន្លយកទៅជិតអាមេប្រធានកងនោះ ដាក់បង្គីចោល ដាក់អីចោល ដងរែង លេងអាប្រធានកងនោះ វៃប្អូនប្រាំដងរែងអីចឹងទៅរត់ពាសទឹកពាសដីទៅ។ គាត់ថា "គេធ្វើការគ្រប់គ្នា អ្អែង អាងបានធ្វើមេនៅស្ងៀម"។ ខ្ញុំសរសើរវីរភាព តាម៉ុក កន្លែងនេះដែរ។ បាទ សូមអរគុណ ខ្ញុំឆ្លើយប៉ុណ្ណឹង។

**សៈ** នៅពេលដែលគាត់វៃមេកងហ្នឹង តើគាត់មានបានប្រាប់ថា គាត់ជាអ្នកណាទេ?

**ធៈ** គេខ្លះគេស្គាល់។ គេអត់ប្រាប់ខ្លួនគាត់ថា គាត់អ្នកណាទេ ប៉ុន្តែគេនៅកន្លែងហ្នឹង មានគេអ្នកស្គាល់ហើយ បាទ។

**សៈ** តើលោកដែលមានឱកាសនិយាយជាមួយ តាម៉ុក ផ្ទាល់ម្ដងណាទេ នៅពេលដែលលោកបានឃើញគាត់តាមការដ្ឋានការងារហ្នឹង?

[១៤:០១:០២]

**ធៈ** តាំងពីខ្ញុំជម្លៀសខ្លួនទៅតំបន់រំដោះនេះ ខ្ញុំមិនដែលបានទៅសន្ទនាអីជាមួយគាត់ក្នុងមនោសញ្ចេតនាទេ។ ដែលតែគាត់ណែនាំខ្ញុំថា "ឯងនេះ ជាបញ្ញវន្ត ជាអនុធន ត្រូវឯងខំក្បួត់ធាតុដើមឲ្យអស់ហើយខំកសាងខ្លួនឲ្យទៅជាកម្មករ កសិករក្រីក្រ ឲ្យគេមើលឃើញថា យើងបានលត់ដំខ្លួនក្នុងកម្មករកសិករក្រីក្រហើយ កុំឲ្យគេយកឯងទៅកសាងទៀត"។

**សៈ** លោកនៅនឹកឃើញទេ តើតាម៉ុក ប្រាប់លោកថាអីចឹង នៅកន្លែងណា? ពេលណា?

**ធៈ** បាទ នឹកឃើញ។ គាត់ប្រាប់ខ្ញុំតាំងពីខ្ញុំទៅដល់មន្ទីរដំណាក់ស្លួល ក្នុងពេទ្យតំបន់។ រហូតមកដល់ផ្ទះ ថ្ងៃដែលគាត់ចេញពីវត្តមក ចេញពី -- ទៅចាត់ចែងការងារនៅក្នុងវត្ត។ មនុស្ស១៧មេសាមក ក៏គាត់មកជួបខ្ញុំនៅផ្ទះហ្នឹងម្ដងទៀត។ គាត់សួរពីសុខទុក្ខម្ដាយខ្ញុំ ហើយគាត់ថា "ឯងមិនត្រូវនៅផ្ទះនេះទេ ត្រូវទៅនៅឆ្ងាយពីទីនេះ ទើបល្អ"។ ដូច្នេះ ខ្ញុំត្រូវបានចាកចេញ ក្រោយពេលគេយករំដោះប្រជាជន១៧ចេញពីវត្តចំប៉ាអស់ និងមួយចំនួនគេយកទៅសម្លាប់ក៏អស់ដែរនោះ ឲ្យទៅនៅឃុំបារាយ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

ហើយស្រុក១០៨ ខាងជើងខេត្តតាកែវ បច្ចុប្បន្ននេះ គឺស្រុករកាក្រៅ។

[១៤:០២:៥៩]

**ស៖** សូមអរគុណលោក។ ប្រធានបទចុងក្រោយ<ដែលខ្ញុំចង់ពិនិត្យ> គឺពាក់ព័ន្ធនឹងអំឡុងពេលក្រោយខែមករា ១៩៧៩ នៅពេលដែលលោកក្លាយទៅជាមេឃុំតាភេម ហើយ<មានការគាស់កាយ>រណ្ដៅសាកសព<នៅក្រាំងតាចាន់។ នៅក្នុងកិច្ចសម្ភាសន៍ >ឯកសារ D25/24, ត្រង់<ទំព័រ> 00163462 <ជាភាសា>ខ្មែរ, 00223457 <ជាភាសា>អង់គ្លេស< និង 00178095 ជាភាសាបារាំង គេសួរលោកថាតើសាកសពប៉ុន្មានដែលត្រូវបានគាស់មកនោះ។> លោកបានឆ្លើយថា សូមដកស្រង់៖ "ប្រាំបីរណ្ដៅមាន< ១០.០៤៥នាក់ (រាប់ក្បាលជាក់ស្ដែង) ប៉ុន្តែ >មានរណ្ដៅ<ច្រើន>ទៀតដែលមិនទាន់<គាស់"។> ហើយ<ចំណុចដកស្រង់>ក្រោយមក <"បន្ទាប់ពីធ្វើស្តូបហើយ ខ្ញុំរាប់ទៅឃើញតែ ១០,០១១ នាក់ទេ"។ បញ្ចប់ការដកស្រង់។> សំណួរទី១របស់ខ្ញុំទាក់ទងទៅនឹងរណ្ដៅសាកសពចំនួនប្រាំបីនេះ។ តើរណ្ដៅសាកសពចំនួនប្រាំបីនេះ <>នៅឯណា< នៅ>គុកក្រាំងតាចាន់នោះ?

[១៤:០៤:២៧]

**ឆ៖** អរគុណណាស់ លោកសួរកន្លែងនេះ។ ខ្ញុំនឹងបានឆ្លើយឲ្យធូរចិត្តខ្ញុំ ក្នុងពេលដែលខ្ញុំរងទុក្ខលំបាកក្នុងក្រាំងតាចាន់២៩ថ្ងៃ។ ទិដ្ឋភាពក្នុងកន្លែងនោះ មិនមែនមានតែប្រជាពលរដ្ឋ១៧មេសា មិនមែនមានតែ១៨មេសា ហើយក៏មិនមែនមានប្រជាពលរដ្ឋដែលជាខ្មាំងសត្រូវដែរ អ្នកដែលចូលរួមតស៊ូជាមួយពួកខ្មែរក្រហម ក៏បានទៅស្លាប់នៅកន្លែងហ្នឹងច្រើនដែរ។ ជាពិសេសមានទាំងជនជាតិបារាំង ជនជាតិអាល្លឺម៉ង់ ព្រះសង្ឃ និងស្ដេចផងដែរ។ ព្រះសង្ឃគឺមានព្រះតេជគុណ ទេព ផុន ជាដើម។ បាទ ហើយជនជាតិបារាំង ខ្ញុំគ្រាន់តែឮ ឃើញពេលដែលវាទៅដល់ ក៏ខ្ញុំសួរបានមួយម៉ាត់ពីរ ពេលដែលខ្ញុំនៅជាប់នៅក្នុងគុកក្រាំងតាចាន់នោះ។ ថ្ងៃដែលបំបែក នៅថ្ងៃ១៧ មេសា មានគេបញ្ជូនបារាំងទៅមិនដឹងជាមកតាមរយៈណា ហើយ--

**ស៖** សូមទោសលោក ខ្ញុំសូមកាត់ផ្ដាច់លោកត្រឹមនេះ សំណួរខ្ញុំនេះ<ពាក់ព័ន្ធ>ជាក់លាក់<>ទៅនឹងការគាស់រណ្ដៅសាកសព<។>នៅក្នុងឆ្នាំ១៩៧៩ នៅពេលដែលលោកបានចូលរួមជាក់ស្ដែងនៅក្នុងការគាស់រណ្ដៅសាកសពនេះ។ លោកបានឆ្លើយថា៖ "លោកបានចូលរួមគាស់រណ្ដៅសាកសពចំនួនប្រាំបី ដែលមានសាកសពចំនួន ១០.០៤៥នាក់"។ តើរណ្ដៅសាកសពទាំងប្រាំបីនេះ វានៅជិតមន្ទីរសន្តិសុខក្រាំងតាចាន់ ចម្ងាយប៉ុនណាដែរ?

**ឆ៖** បាទ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំអត់ជំទាស់នឹងសំណួរទេ ប៉ុន្តែខ្ញុំបានពិនិត្យឃើញសាក្សីគាត់អានទៅលើក្រដាសគាត់ និងមានការគូសចំណាំជាច្រើនដង ខ្ញុំមិនដឹងថាជាក្រដាសអ្វី។ សូមលោកប្រធានអាចជួយពិនិត្យ បាទ។

**ប្រធានអង្គជំនុំ៖**

យើងបានពិនិត្យរួចហើយ ក្រដាសហ្នឹង ក្រដាសសទេ គាត់គ្រាន់តែសុំក្រដាសស ដើម្បីគូសវាសជាការកត់ត្រា ដើម្បីគាត់ងាយចងចាំទេ យើងបានដកតាំងពីពេលព្រឹកម្ល៉េះ។

បាទ សូមអញ្ជើញ អត់អីទេ យើងបានចាត់ចែងរួចហើយ យើងបានឆ្លើយឆ្លងគ្នារួចហើយ យើងចាត់វិធានការតាំងពីព្រឹកមិញម្ល៉េះ។

បាទ សួរសំណួរម្តងទៀត បាទ!

[១៥:០៧:១៦]

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** បាទ សំណួររបស់ខ្ញុំ គឺសួរជាក់លាក់អំពីរណ្តៅសាកសពចំនួនប្រាំបី ដែលលោកបានចូលរួមជាក់ស្តែងក្នុងការគាស់រណ្តៅសាកសពនៅក្នុងឆ្នាំ១៩៧៩ ដែលថាលោកបានគាស់សាកសពជាងមួយម៉ឺននាក់ឯណោះ។ ខ្ញុំចង់សួរទីតាំង ថាតើទីតាំងសាកសពទាំង -- រណ្តៅសាកសពទាំងប្រាំបីហ្នឹងវាមានចម្ងាយប្រវែងប៉ុន្មានដែរ ពីមន្ទីរសន្តិសុខក្រាំងតាចាន់?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បាទ ក្នុងមណ្ឌលក្រាំងតាចាន់នេះ មានប្រវែងណ្តោយប្រហែលជា២៥០ម៉ែត្រ ទទឹង២០០ម៉ែត្រ ហើយរណ្តៅសាកសពទាំងអស់នោះ គឺអត់មានទៅកប់ឆ្ងាយ កាប់រណ្តៅឆ្ងាយពីកន្លែងនោះទេ គ្រាន់តែជួរក្បែររបងខាងត្បូង និងជួរក្បែរស្រែរបស់ប្រជាជនទៅខាងកើត។ តែយើងគាស់អត់ទាន់អស់រណ្តៅនោះទេ។ ពេលដែលខ្ញុំកាប់រណ្តៅដាក់ខ្មោចនោះ ក្នុងរយៈពេល២៩ថ្ងៃនេះ ខ្ញុំបានកាប់រណ្តៅប៉ុន្មាន ខ្ញុំគាស់ប៉ុណ្ណឹង គឺខ្ញុំបានកាប់រណ្តៅជាមួយនឹងពួកអ្នកទោសទាំងអស់ដែរ ចំនួនប្រាំបីរណ្តៅ ប៉ុន្តែ

រណ្តៅមានច្រើនជាងនេះទៀត។ អ៊ីចឹងខ្ញុំសន្និដ្ឋានថា ខ្មោចដែលខ្ញុំគាស់ ហើយលើកយកមក ខ្ញុំរកបានឃើញក្បាល១ខ្មោច១នេះ។ ដោយឡែកក្បាលកូនក្មេងអត់មាននៅសល់ទេ នៅសល់តិច១។ អង្គការ *អុកស្វាម* អត់បានទទួលស្គាល់ថាជាឆ្អឹងមនុស្សផង។ វានិយាយភាសាបារាំងថា "*សែលេហ្សុស ដឺប៊ឺ អេ ដឺប៊ិហ្វ៊ឺះ សែណែប៉ា ឡេហ្សុសអេឡោម៉ឺះ*" – វាថាមិនឆ្អឹងមនុស្សទេ គឺឆ្អឹងគោ ឆ្អឹងក្របី ឆ្អឹងវាច្រើនគរអ៊ីចឹង។ មានតែគេកាប់គោ កាប់ក្របី យកឆ្អឹងយកទៅគរចោលនៅកន្លែងហ្នឹង។ តែដល់ឃើញក្បាលមនុស្ស បានវាទទួលស្គាល់ថាជាក្បាលមនុស្ស ដែលពិឃាដដោយបនប្រល័យពូជសាសន៍ខ្មែរក្រហម។ ពេលនោះ ឆ្អឹងដែលខ្ញុំគាស់បាន ខ្ញុំគរទុកក្បែរមាត់រណ្តៅ។ ហើយសូមដឹងគុណអង្គការ *អុកស្វាម* ផងដែរ ដែលចូលរួមឲ្យអង្ករ ដើម្បីឲ្យកម្លាំងពលកម្មជីកយកឆ្អឹងខ្មោចនោះ។ យើងដាក់នៅគរក្បែរៗរណ្តៅ ឆ្អឹងខ្លះនៅជាប់នឹងសាច់ដែលគេច្បូតចេញមក។ យើងរាប់ឃើញ ១២.១៣២ក្បាល។ ក្រោយមកប្រហែលជាពីរអាទិត្យ ខ្ញុំទៅឃើញរប៉ាត់រប៉ាយ ក្បាលហ្នឹង។ សួរទៅអ្នកស្រុកថា "អ្ហើយ! ពូអើយ ឆ្កែពាំស៊ីនៅផ្ទះខ្ញុំនេះ ជ្រូកពាំមក។ លោកកុំធ្វើអ៊ីចឹងខ្ញុំខ្លាចណាស់"--

**ប្រធានអង្គជំនុំ៖**

បានហើយ លោកសាក្សី ចាំស្តាប់សំណួរឲ្យបាន ហើយឆ្លើយ១ភាពចាំបាច់ពេញលេញទៅនឹងតបនឹងសំណួរបានហើយ។ ពេលវេលាមានកំណត់។

[១៤:១០:៤៩]

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** ខ្ញុំសូមអភ័យទោសលោក ដែលកាត់រំខានលោក។ ខ្ញុំមានតែសំណួរ បីបួនសំណួរទៀតទេ។ សំណួរទី១ គឺរណ្តៅចំនួនប្រាំបី ដែលលោកបានគាស់នៅក្នុងឆ្នាំ១៩៧៩។ តើជាទីតាំងដែល១គេឲ្យលោកអូសសាកសពយកទៅកប់នៅពេលដែលលោកជាប់គុកនៅក្រាំងតាចាន់ហ្នឹង ថាតើជារណ្តៅតែមួយហ្នឹងឬក៏អត់?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** មិនមែនទាំងអស់នោះទេ។ កន្លែងខ្លះអ្នកទោសដែលជាប់ជាមួយនោះ ដូច កែវ សំអាតនេះ គាត់ជាប់ក្រោយខ្ញុំ គាត់ដឹងថាគេមានជីកត្រង់នោះទៀត។ អ្នកស្រុកដែលធ្លាប់ដឹងក៏គេ -- ហើយយើងមើលឃើញដីដែលកន្លែងធ្វើរណ្តៅនោះវាស្រុត។ ត្រង់ហ្នឹងយើងយល់ថារណ្តៅកប់ខ្មោចហើយវាទាបជាងគេ យើងគាស់ត្រង់ហ្នឹង បាទ។ គាស់ទៅឃើញឆ្អឹងហើយ។ ហើយឆ្អឹងដែលរប៉ាត់រប៉ាយហ្នឹង

យើងធ្វើផ្ទះមួយដាក់ បាទ សុំអង្ករពួក អុកហ្វាម ហ្នឹង ដើម្បីឲ្យគេ -- ទៅសុំផ្ទះគេយកមកសង់នៅកន្លែងហ្នឹងដាក់។ ហើយក្នុងពេលដែលយើងសង់ដាក់ហ្នឹង ឃើញមួយរយ -- អ៎! ១២.១៣២នាក់។

សុំនិយាយហួសពីហ្នឹងបន្តិចបានទេ? ក្រោយពេលដែលយើងប្រមូលឆ្អឹងហ្នឹងយកដាក់ក្នុងស្តូបបាទ។ បាទក្នុងស្តូបហ្នឹង បច្ចុប្បន្នទៅឃើញស្តូបហ្នឹងហើយ ស្តូបដាក់ឆ្អឹងហ្នឹង ដាក់ជាកញ្ចក់ ជញ្ជាំងកញ្ចក់។ ឆ្អឹងនេះអត់បាននៅគ្រប់ដូចកាលដែលយើងគាស់--

**ស៖** *(គ្មានការបកប្រែ)*

[១៤:១២:២០]

**ប្រធានអង្គជំនុំ៖**

លោកបន្តសំណួរទៀត លោកសហព្រះរាជអាជ្ញាអន្តរជាតិ!

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** បាទ អរគុណលោកប្រធាន។ សំណួរចុងក្រោយរបស់ខ្ញុំ<។>លោក<បាន>និយាយពីការរាប់លលាដ៍ក្បាលជាក់ស្តែង<>។ <ខ្ញុំគិតថា>លោកថា<>មានជាង <១២.០០០>លលាដ៍ក្បាល<>។ លោកអាច<ប្រាប់ខ្ញុំបានទេថាអ្នកណាជាអ្នក>រាប់លលាដ៍ក្បាលហ្នឹង<ផ្ទាល់ និងរាប់ឃើញចំនួនជាង ១២.០០០ លលាដ៍ក្បាលនោះ?>

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** សូមលោកមានប្រសាសន៍ម្តងទៀត។

**ស៖** បាទ ខ្ញុំ<ចង់ដឹង>ថាតើអ្នកណាជាអ្នករាប់លលាដ៍ហ្នឹងពិតប្រាកដ ហើយក៏<អ្នកណាជាអ្នករាប់លលាដ៍ក្បាលហ្នឹងផ្ទាល់ និងរាប់ឃើញចំនួនជាង ១២.០០០លលាដ៍ក្បាលនោះ?>

**ប្រធានអង្គជំនុំ៖**

បកប្រែខុសទេអី ឬក៏សួរខុស មិនមែនដប់ម៉ឺនទេណ៎ា ជាងមួយម៉ឺន។ កែៗតម្រូវឡើងវិញសំណួរមិនមែនជាង ដប់ម៉ឺនទេ។ ជាងមួយម៉ឺន និយាយយូរហើយ ហើយមកបកប្រែជាង ដប់ម៉ឺនយ៉ាងម៉េច? អត់ៗឮសោះដប់ម៉ឺនតាំងពីព្រឹកមក។

[១៤:១៣:៥៤]

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** លោកសាក្សី សូមលោកជម្រាបម្តងទៀត តើចំនួនលលាដ៍ក្បាលដែលរាប់ពិតប្រាកដហ្នឹង

មានចំនួនប៉ុន្មានដែរ?

**ប្រធានអង្គជំនុំ៖**

កុំទាន់អាលឆ្លើយតបសាក្សី!

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** ពេលដែលយើងគាស់ភ្លាមនោះ លលាដ៍ក្បាលក្នុងមួយរណ្ដៅៗ យើងលើកដាក់មាត់រណ្ដៅសឹងអស់ ហើយប្រាំបីរណ្ដៅនេះឃើញ ១២.១៣២លលាដ៍ក្បាល។ តែក្រោយពីលើកពីកន្លែងហ្នឹង យកមកដាក់លើផ្ទះឈើមួយដែលយើងសុំលុយអុកហ្វាម មកសង់ដើម្បីកុំឲ្យឆ្កែជ្រូកអីទៅពាំនោះ យើងបាត់ ៧លលាដ៍ក្បាល គឺនៅសល់តែ ១២.០១៣ក្បាល បាទឆ្កែវាពាំបាត់។ ហើយសូមជម្រាបផងដែរថាការដែលបាត់មិនមែនសុទ្ធតែឆ្កែពាំ ហើយនិងជ្រូកពាំទេ។ មានគេអ្នកដែលគេបាត់បង បាត់ប្អូន បាត់កូន បាត់ប្រពន្ធគេ គេទៅឈរធ្មេច ស្លឹងស្មាតសុំ អធិដ្ឋាន ទៅចាប់លលាដ៍ក្បាលហ្នឹងយកមក "ឲ្យខ្ញុំសុំតោងឲ្យចំក្បាលប្ដីខ្ញុំ" "ខ្ញុំសុំទៅតោងឲ្យចំក្បាលប្រពន្ធខ្ញុំ" "ខ្ញុំសូមទៅតោងចំក្បាលឪខ្ញុំ"។ ហើយគេតោងបានមក គេយកទៅផ្ទះគេទៅ គេយកទៅធ្វើបុណ្យនៅនោះ។ អ៊ីចឹងវាបាត់ៗហ្នឹងមកពីអ៊ីចឹងទេបាទ។ ក្រោយពេលយើងយកទៅដាក់ក្នុងស្តូប យើងយកទៅឃើញក្បាលនេះខើចចេញពីហ្នឹងទៀត។

**ស៖** លោកសាក្សី សំណួរចុងក្រោយបំផុតហើយ អ្នកណាជាអ្នករាប់ក្បាលហ្នឹងដាក់ស្ដែងតែម្ដង ជាអ្នករាប់លលាដ៍ហ្នឹងដាក់ស្ដែងតែម្ដង?

[១៤:១៥:៥៧]

**ឆ៖** បាទមិនមែនតែរូបខ្ញុំមួយផ្ទាល់ទេ មានលោកគ្រូចៅអធិការវត្ត និគ្រោធវង្សី –នៅខាងត្បូងមន្ទីរពេទ្យក្រាំងតាចាន់ហ្នឹង– ជួយធ្វើអន្តរាគមន៍ក្នុងការលើកកាប់គាស់ លើកសពក្បាលលលាដ៍ហ្នឹងដាក់ទុកផងដែរ។ ជាពិសេសទៅទៀត បច្ចុប្បន្ននេះមិនទាន់ចាកសិក្ខាបទទេ ព្រះតេជគុណ ធិរវង្សាចារ្យ, ព្រះអនុគណ ខែម សុខ អនុគណស្រុកត្រាំកក់ ចូលជួយរួម ដើម្បីរាប់លលាដ៍ក្បាលហ្នឹង និងលើកទៅដាក់ក្នុងស្តូប។

**លោក ត្រាវិស ហ្វារ៖**

លោក កែវ ច័ន្ទតារ៉ា សូមអរគុណលោកច្រើន ដែលលោកបានឆ្លើយទៅនឹងសំណួរ -- សំណួររបស់ខ្ញុំ។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាអស់សំណួរហើយឬនៅ? បើអស់ហើយ សូមអញ្ជើញប្រគល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន ជម្រាបសួរលោកសាក្សី។ ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាមេធាវីអន្តរជាតិដែលតំណាងឲ្យក្រុមដើមបណ្ដឹងរដ្ឋប្បវេណី។

**ស៖** ខ្ញុំមានសំណួរតែមួយទេលោក គឺសំណួរទាក់ទងទៅនឹងចម្លើយរបស់លោក ដែលលោកបានឆ្លើយអម្បាញ់មិញនេះ ខ្ញុំយល់មិនច្បាស់ អ៊ីចឹងខ្ញុំសូមឲ្យលោកពន្យល់ពាក្យមួយដែលលោកបាននិយាយអម្បាញ់មិញនេះ គឺលោកនិយាយថាមានអ្នក១៧–១៧មេសា ហើយនិង១៨ មេសា ឬក៏១៨ មីនាទេ ខ្ញុំយល់មិនច្បាស់កន្លែងនេះ។ តើពួក១៧មេសា ហើយនិង -- បើតាមអ្វីដែលលោកនិយាយហ្នឹង គឺថាអ្នក១៨ មីនា ឬ១៨ មេសា នេះ ដែលតាមខ្ញុំឮតាមអ្នកបកប្រែ។ អ៊ីចឹងសូមលោកបញ្ជាក់ពាក្យទាំងពីរហ្នឹងមក ថាតើ១៧ មេសា និង ១៨មីនា ហ្នឹង ឬក៏ ១៨មេសា ទេឬក៏យ៉ាងម៉េច?

**ឆ៖** សូមជម្រាប ១៧មេសា គឺជនដែលនៅក្នុងរបបលន់ នល់ ។ ចេង ហេង, ឌុក ដាវ៉ាស៊ី, កេង វ៉ាង, របប លន់ នល់ និងចេញមកថ្ងៃ១៧ មេសា គេហៅជន១៧មេសា។ តែ ១៨មេសា នោះគឺពួកជនដែលនៅតំបន់រំដោះ នៅជាមួយខ្មែរក្រហមតាំងពីឆ្នាំ៧០ មកបាទ។

[១៤:១៩:០២]

**ស៖** បើអ៊ីចឹង ដល់ពួក១៨មេសា ហ្នឹង ជាប្រជាជនមូលដ្ឋាន ឬក៏យ៉ាងម៉េចលោក?

**ឆ៖** បាទ ការសន្មតរបស់ប្រជាជននៅមូលដ្ឋានហ្នឹង គេថា គេអ្នក១៨មេសា ហើយអ្នកបែកមក ១៧ មេសា គឺអ្នកដែលមកខាងក្រោយ។ នៅមុនៗមុន១៧មេសា ហ្នឹង គឺគេអ្នក១៨ មេសា ទាំងអស់ពីឆ្នាំ១៩៧០ មកទល់១៨ មេសា ហ្នឹង គឺគេថាគេប្រជាជនចាស់។ និយាយអ៊ីចេះ។ ពាក្យគ្រាមៗភាសារបស់អ្នកនៅតំបន់រំដោះហ្នឹង គេនិយាយអ៊ីចឹង។ ហ្នឹងយើងនិយាយលើកតាមគេហ្នឹង។

**ស៖** ខ្ញុំសូមបញ្ជាក់បន្តិចហ្នឹង ខ្ញុំនិយាយឲ្យច្បាស់។ ប្រជាជនមូលដ្ឋានគឺមិនមែនអ្នកនៅក្នុងឃុំរបស់លោកស្រីទេ គឺអ្នកមកពីកន្លែងផ្សេងតំបន់ផ្សេងអ៊ីចឹងមែនទេ ដែលគេហៅ ១៨មេសា អំមិញដែលលោកបាននិយាយអំមិញនេះ?

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ
ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

**ឆ៖** បាទ អ្នក១៨មេសា បានន័យថាប្រជាជនទាំងអស់ អ្នកទាំងអស់ ស្រីប្រុស ចាស់ក្មេងដែលមិនមែននៅក្នុងរបបលន់នល់ គឺអ្នកដែលគេបានរំដោះហើយនៅក្នុងតំបន់ខាងក្រៅៗ ក្រៅពីទីរួមខេត្ត រួមក្រុង រួមធានី ដែលនៅក្នុងរបបខាងក្រហមហ្នឹង គេថា ជន១៨មេសា។ អ្នក១៧មេសា រួមគឺពេលដែលបែកហើយហ្នឹង គ្រប់ខេត្ត គ្រប់ក្រុង គ្រប់រាជធានីទាំងអស់ដែលចេញមកក្រៅគេហៅថា ជន ១៧ មេសា។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំនៅតែមិនទាន់ច្បាស់នៅឡើយទេ។ តើលោកអាចពន្យល់តុលាការបានទេ ថាពួក១៧មេសា ទទួលការប្រព្រឹត្តប្រសើរជាង ពួក១៧មេសា?

**ឆ៖** បាទ សុំលោកជម្រាបខ្ញុំម្តងទៀត ខ្ញុំស្តាប់សំណួរអត់ទាន់បានច្បាស់ល្អទេទាន។

[១៤:២១:៣៤]

**ប្រធានអង្គជំនុំ៖**

លោកស្រីតាំងសំណួរសាជាថ្មីម្តងទៀត។ ហើយ ១៧មេសា ហើយវាមានភាពប្រសើរជាង១៧មេសា យ៉ាងម៉េច? ដូចជាភាសាហ្នឹងមិនដឹងស្តាប់មានន័យថាម៉េចទេ? ឆ្លើយក៏មិនដឹងថាម៉េចដែរ?

មេធាវីសួរ តាំងសំណួរចុងក្រោយចំពោះសាក្សីម្តងទៀត ដើម្បីឱ្យគាត់ស្តាប់យល់។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

**ស៖** សំណួរខ្ញុំអម្បាញ់មិញនេះគឺថា តើពួក១៧មេសា ទទួលការប្រព្រឹត្តខុសពីអ្នកដែលគេហៅថា១៨មេសា។ តើការប្រព្រឹត្តហ្នឹងខុសគ្នាទេ? តើទទួលរបបអាហារដូចគ្នា របបការងារដូចគ្នា មានផ្ទះសម្បែងដូចគ្នា? តើមានការប្រព្រឹត្តខុសគ្នារវាងអ្នកដែលគេហៅថា ១៧មេសា ហើយនិងអ្នក១៨មេសាដែរឬទេ?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បាទ អ្នក១៨មេសានោះ គេយល់ថា ពួកខ្មែរក្រហមហ្នឹងគេយល់ថា បានរស់នៅ បានទទួលការអប់រំ បានធ្វើការងារជាមួយគេតាំងពីឆ្នាំ១៩៧០ រហូតមក។ ហើយពួក១៧មេសា គឺពួក ដែលទើបតែបែកចេញនៅក្នុងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ ពួកនេះគេអត់ទាន់បានអប់រំ អត់ទាន់បានចូលរួមការងារជាមួយគ្នា អត់ទាន់បានធ្វើអ្វីៗក្នុងតំបន់រំដោះជាមួយពួកខ្មែរក្រហមនោះទេ។ យល់នៅទានប៉ុណ្ណឹង?

[១៤:២៣:១៨]

**ប្រធានអង្គជំនុំ៖**

សំណួរមិនដូច្នេះទេ សំណួរចង់សួរបញ្ជាក់ថា តើការប្រព្រឹត្តរបស់ថ្នាក់ដឹកនាំ ឬក៏សង្គមហ្នឹងសម័យនោះចំពោះអ្នក១៨មេសា ហ្នឹង និងចំពោះអ្នក១៧មេសា ដែលទើបរំដោះចេញពីទីក្រុងភ្នំពេញក្រោយថ្ងៃ១៧ មេសា ៧៥ ហ្នឹង ការប្រព្រឹត្តហ្នឹងវាដូចគ្នា ឬក៏ខុសគ្នា ដូចជាការហូបចុក ការរស់នៅការប្រាស្រ័យទាក់ទងអ្វីផ្សេងៗ ដូចសិទ្ធិសេរីភាពអីចឹង តើវាដូចគ្នាដែរឬទេ?

**ឆ៖** បាទ អ្នក១៧មេសាហ្នឹង គេយល់ថា អ្នកស្គាល់ហេតុស្គាល់ផលនៅក្នុងតំបន់បដិវត្តន៍ហ្នឹងតិចណាស់ ព្រោះទើបតែចេញមកក្នុងថ្ងៃ១៧ មេសា តែអ្នក១៨មេសាហ្នឹង នោះគឺគេបានរស់នៅក្នុងតំបន់រំដោះ រស់នៅក្នុងរបបខ្មែរក្រហមហ្នឹងតាំងពីឆ្នាំ៧០ មកគឺវា ៨ឆ្នាំ ៨ខែ ២០ថ្ងៃ។ រីឯអ្នក១៧មេសារស់ក្នុងតំបន់រំដោះហ្នឹង តែ ៣ឆ្នាំ ៨ខែ ២០ថ្ងៃ។ ប៉ុណ្ណឹងគួរលោកយល់ហើយ។ អស់លោកទាំងអស់មានបញ្ញាប៉ាតធី អាចកាត់យល់ហើយ។

[១៤:២៤:៣០]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី សូមតាំងសំណួរឱ្យជាក់លាក់ទៅកុំសួរទូលាយពេក ប្រហែលជាគាត់ស្តាប់សំណួរមិនយល់ទេ ហើយពិបាកមិនឆ្លើយចំសំណួរ អាចចំណាយពេលច្រើន។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ខ្ញុំមានសំណួរចុងក្រោយមួយ សំណួរស្រដៀងគ្នាទេ លោកសាក្សី។ ខ្ញុំសួរថាតើអ្នកដែលគេហៅថា ១៨មេសា ហ្នឹងមានទទួលការប្រព្រឹត្តខុសពីប្រជាជនមូលដ្ឋានទេ?

**ឆ៖** បាទ ក្នុងរបបខ្មែរក្រហមច្បាប់របស់គេនោះ គឺហូបដូចគ្នា ធ្វើការងារដូចគ្នា បញ្ចេញកម្លាំងពលកម្មដូចគ្នា។ គ្រាន់តែការទំនុកទុកចិត្តរបស់អង្គការគេនោះ គេទុកចិត្តទៅលើអ្នក១៧មេសា គឺតិចណាស់ ព្រោះនៅជាប់កម្អែលរបបលន់នល់។ អីចឹង គេគ្រាន់តែគិតប៉ុណ្ណឹងទេ។ តែការងារអីត្រូវតែចេញពលកម្មឱ្យអស់ដូចគ្នា។ ប៉ុន្តែខ្ញុំពិនិត្យមើលឃើញភាគច្រើន អ្នកដែលនៅក្នុងរបប១៧មេសា គេច្រើនបានធ្វើមេកង មេក្រុម មេពួកអីអីចឹងទៅ ទាំងស្រីទាំងប្រុស។ រីឯអ្នក១៧មេសា គឺមិនដែលបានក្នុងថ្នាក់ដឹកនាំជាក្រុមៗ ជាពួកជាកងទេ។

[១៤:២៦:២៧]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកសាក្សី។ លោកប្រធានខ្ញុំអស់សំណួរហើយ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីលោក នួន ជា ដើម្បីមានឱកាសការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សួន វិសាល៖**

សូមគោរពលោកប្រធាន។ សូមជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនសួរទៅលោក។

**ស៖** សំណួរសួរទី១ របស់ខ្ញុំ គឺថាខ្ញុំចង់ដឹងថា តើពិតប្រាកដ ថ្ងៃខែពិតប្រាកដនៃការចាប់ខ្លួនរបស់លោក តើចាប់នៅពេលណាដែរ?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** ពេលដែលគេចាប់ខ្លួនខ្ញុំ ក្នុងថ្ងៃ២០ ខែមីនា ហើយខ្ញុំត្រូវរួចឡើងវិញ ក្នុងថ្ងៃ -- ក្នុងដាច់ខែមេសា បាទ បំណាច់ខែមេសា គិតទៅក្នុងរយៈពេលពាក់កណ្តាលចុងខែមីនា និងដើមខែមេសា ឆ្នាំ១៩៧៥។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមដកស្រង់ចម្លើយរបស់លោកបន្តិច តើលោកមានបានផ្តល់ចម្លើយនៅចំពោះមុខចៅក្រមស៊ើបអង្កេត ឬការិយាល័យសហចៅក្រមស៊ើបអង្កេត កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៧ ឬទេបាទ?

**ឆ៖** សូមលោកមានប្រសាសន៍ម្តងទៀតបាទ។

[១៤:២៨:៣០]

**ស៖** ខ្ញុំចង់បញ្ជាក់ឡើងវិញនូវចម្លើយរបស់លោក គឺថាលោកបានឆ្លើយនៅចំពោះមុខការិយា-ល័យសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៧។ តើលោកមានបានឆ្លើយ ឬក៏មិនបានឆ្លើយទេ?

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបសាក្សី!

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** អ្វីដែលមាននៅក្នុងក្រដាសកត់ស្មាម គឺខ្ញុំសុទ្ធតែបានចុះហត្ថលេខា។

**សួរដោយលោក សួន វិសាល៖**

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមដកស្រង់ចម្លើយរបស់លោក គឺនៅក្នុងឯកសារ D25/24 ERN ជាភាសាខ្មែរ 00163456, ជាភាសាអង់គ្លេសគឺ 00223452, "សំណួរ៖ គេចាប់ខ្លួនអ្នកនៅពេលណា?" ចម្លើយរបស់លោកឆ្លើយថា៖ "នៅចន្លោះឆ្នាំ៧៣ ឆ្នាំ៧៤ មុនបែកទូទាំងប្រទេស"។ តើចម្លើយនេះ គឺជាចម្លើយរបស់លោកនៅចំពោះមុខចៅក្រមស៊ើបអង្កេតទេបាទ?

**ឆ៖** បាទ ចម្លើយនេះ មិនពិតប្រាកដទេ ពីព្រោះ--

**ស៖** បាទៗ សូមអរគុណ។ ខ្ញុំចង់ដឹងថា ពិត ឬមិនពិតប៉ុណ្ណឹងបានហើយ ព្រោះអីពេលវេលាខ្លី គឺថាខ្ញុំចង់--

**ឆ៖** បាទ ចម្លើយនេះពិតដូចខ្ញុំ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

សូមៗអញ្ជើញ!

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** --បាទ ចម្លើយណាដែលមាននៅក្នុងក្រដាស ហើយខ្ញុំចុះហត្ថលេខា គឺចម្លើយនោះពិត។ តែពីនោះមកដល់ឥឡូវវាច្រើនឆ្នាំដែរ វាអាចយើងភ្លេចខ្លះអីខ្លះបាទ។ មកនិយាយក្នុងពេលនេះ សាឡើងវិញ គឺ *អ៊ែរ៉ី* អស់ខ្លះហើយ វាខុសខ្លះអីខ្លះហើយ ប៉ុន្តែមិនចាកប្រធានប៉ុន្មានទេ។

**សួរដោយលោក សួន វិសាល៖**

**ស៖** ដូចនេះមានន័យថា លោកបានឆ្លើយនៅចំពោះមុខចៅក្រមអង្កេតថា លោកបានចាប់ខ្លួននៅចន្លោះឆ្នាំ៧៣-៧៤ មុនពេលបែកទូទាំងប្រទេស។ អ៊ីចឹង លោកចាំសម្ដីហ្នឹងឡើងវិញ ឬទេបាទ?

**ឆ៖** ខ្ញុំបានបើកឯកសារកំណត់ហេតុរបស់ខ្ញុំ ក្នុងពេលដែលខ្ញុំធ្វើមេឃុំទៅ ខ្ញុំសម្រាន្តគិតហើយសរសេរទៅ ឃើញថាចម្លើយនេះអត់ទាន់ត្រឹមត្រូវទេ។ បាទ ពីព្រោះថាខ្ញុំជាប់គុកនៅក្រាំងតាចាន់--

[១៤:៣១:១៥]

**ស៖** បាទៗ សូមអរគុណ។ ខ្ញុំចង់បានប៉ុណ្ណឹងបាទ ខ្ញុំសូមសួរបន្តទៅមុខទៀត។ ខ្ញុំចង់សួរលោកម្ដងទៀតទាក់ទងទៅនឹងការឃុំខ្លួន។ តើពេលគេចាប់ខ្លួនភ្លាម តើបញ្ជូនលោកទៅមន្ទីរក្រាំងតាចាន់ភ្លាម ឬក៏ដាក់គុកលោកកន្លែងណាដែរ?

**ឆ៖** បាទ បញ្ជូនទៅមន្ទីរក្របីព្រៃ អស់ប្រាំថ្ងៃ។ កន្លែងនោះគេអត់មានដាក់គុកដាក់អីចឹងទេ អត់គុកទេកន្លែងមន្ទីរក្របីព្រៃទាន។ តែបើមានពួកទោសទាន់ហន់ដែលគេដឹងច្បាស់របស់គ្នាគេតែម្ដង គេយកទៅសម្លាប់ភ្លាមកន្លែងហ្នឹងតែម្ដង។ ហើយបើសិនជាមិនមានទោសពៃរ៍អីទេ ទៅសួរចម្លើយអី គេបញ្ជូនទៅមន្ទីរក្រាំងតាចាន់។ ឯអ្នកដែលមកសួរចម្លើយនៅមន្ទីរក្របីព្រៃនោះ ឃើញតែមនុស្សហ្នឹងទេ អាចារ្យឆេន ហ្នឹង ព្រោះខ្ញុំធ្លាប់ស្គាល់គេតាំងពីគេនៅធ្វើអាចារ្យវត្តគុស។

**ស៖** នៅពេលបញ្ជូនលោកទៅ តើមានគេចាប់ខ្លួនអ្នកណាផ្សេងដែលត្រូវបញ្ជូនទៅជាមួយលោកទេ ឬក៏អត់ទេ?

**ឆ៖** បាទមានទាន គឺមនុស្សទៅគ្នាបួននាក់ យាយតាត នៅក្នុងឃុំតាភេមដែរ ប៉ុន្តែភូមិដោយខ្លួន។ តាប៉ាន់ នៅភូមិតាមុំ ក៏គាត់ស្លាប់បាត់ហើយទាំងពីរនាក់បាទ ហើយ យាយយឿន គេសម្លាប់នៅក្របីព្រៃតែម្ដង។

[១៤:៣២:៥៧]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរបន្តទៀត តើគេឃុំខ្លួនលោកនៅមន្ទីរក្រាំងតាចាន់ប៉ុន្មានថ្ងៃដែរឬទេ?

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបសាក្សី!

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បាទ ខ្ញុំចេះតែភ្លេចអីចឹងមិនបានមើលភ្លើងក្រហម សូមអធ្យាស្រ័យ។ បូកទាំងមន្ទីរក្រាំងតាចាន់២៤ថ្ងៃ ហើយនិង៥ថ្ងៃនៅមន្ទីរក្របីព្រៃ វា២៩ថ្ងៃ។

**សួរដោយលោក សួន វិសាល៖**

**ស៖** បាទ សូមអរគុណ។ តើគេលែងលោកនៅពេលណាដែរ ចេញពីមន្ទីរឃុំឃាំងនោះ?

**ឆ៖** សូមលោកមានប្រសាសន៍ម្តងទៀត។

**ស៖** សូមអរគុណ។ ខ្ញុំចង់ដឹងថាតើនៅពេលដែលនៅជាប់ពន្ធនាគារនៅទីនោះ ឬក៏មន្ទីរឃុំឃាំងនៅទីនោះ ថាតើគេលែងលោកនៅពេលណា? លែង ដោះលែងលោកនៅពេលណាដែរ?

[១៤:៣៤:២២]

**ឆ៖** បាទ ថ្ងៃខ្ញុំមិនសូវចាំច្បាស់ទេ ប៉ុន្តែក្នុងខែមេសា ក្រោយពេលបែកទូទាំងប្រទេសប្រហែលជា១២ ឬ១៣ថ្ងៃ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់រំឭកលោកឡើងវិញផងដែរ ខ្ញុំចង់ដកស្រង់សម្តីលោកតែម្តងនៅចំពោះមុខចៅក្រមស៊ើបអង្កេត គឺឯកសារ D25/24, ERN ជាភាសាខ្មែរ 00163461, ភាសាអង់គ្លេស 00223456។ សំណួររបស់អ្នកស៊ើបអង្កេតគឺថា។ “តើលោកចេញពីពន្ធនាគារនៅពេលណា?” លោកបានឆ្លើយថា៖ “ជិតបែកឆ្នាំ១៩៧៥”។ តើនេះគឺជាចម្លើយរបស់លោកឬក៏យ៉ាងណាបាទ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បាទមិនមែនជិតបែកទេ ព្រោះពេលបែកនោះ--

**សួរដោយលោក សួន វិសាល៖**

**ស៖** បាទៗ សូមអរគុណ ប៉ុណ្ណឹងហើយ។ ប៉ុន្តែខ្ញុំចង់បញ្ជាក់ថា នេះជាចម្លើយរបស់លោក ឬក៏មិនមែនជាចម្លើយរបស់លោក?

**ឆ៖** បាទ ដូចខ្ញុំជម្រាបហើយ ថាចម្លើយរបស់ខ្ញុំ ពិតជាមានចុះហត្ថលេខាខ្ញុំហើយ។

**ស៖** អ៊ីចឹងបាទ លោក មានន័យថាលោកទទួលស្គាល់ចម្លើយរបស់លោកឆ្លើយនៅចំពោះមុខចៅក្រមស៊ើបអង្កេតហ្នឹង។ តើអ៊ីចឹងមែនទេបាទ?

**ឆ៖** បាទ ខ្ញុំ មិនដែលអ្នកណាទៅសួរខ្ញុំផ្តេសផ្តាសក្រៅពីអង្គជំនុំជម្រះខ្មែរក្រហមនោះទេ បាទគឺពិតជាគេទៅសួរខ្ញុំដល់ផ្ទះហើយ ហើយខ្ញុំចុះហត្ថលេខាមុននឹងខ្ញុំឆ្លើយ ខ្ញុំសុទ្ធតែឆែកឆេមើលអ្នកដែលចុះទៅស៊ើបអង្កេតហ្នឹងគឺប្រាកដជា *ហ្លួ*របស់សាលាក្តីខ្មែរក្រហមហ្នឹងហើយ។

**ស៖** បាទ សូមអរគុណ អ៊ីចឹងសួរទៅសំណួរមួយទៀតបាទ។ នៅក្នុងមន្ទីរក្រាំងតាចាន់ហ្នឹង តើមានបន្ទប់ឃុំឃាំងប៉ុន្មានដែរបាទ?

**ឆ៖** ពេលខ្ញុំជាប់នៅក្នុងក្រាំងតាចាន់ ខ្ញុំយល់ថាមានតែមួយហ្នឹងទេ ដូចខ្ញុំជម្រាបពីមុនហើយណ៎ះ!។ បាទ មន្ទីរវាមានប្រវែងបណ្ដោយទទឹងអីហើយអស់ហើយ។ តែដល់ក្រោយមកខ្ញុំទៅគាស់សពខ្មោចហ្នឹង ខ្ញុំឃើញរណ្ដៅមួយផុង ដល់ខ្ញុំមើលមានប្ញូកដីដំបូកពីលើ ជីកទៅពីក្រោមមានឆ្អឹងខ្មោចទៀត។

[១៤:៣៧:០៨]

**ស៖** បាទៗ សុំ ប្រហែលជាលោកមិនទាន់យល់ សុំកាត់បន្តិច មិនទាន់យល់សំណួរខ្ញុំ។ ខ្ញុំសួរថា តើមន្ទីរកន្លែងគេដាក់មនុស្ស បានន័យថាដាក់អ្នកទោសហ្នឹង តើមានអគារប៉ុន្មានដែរសម្រាប់មនុស្សអ្នកទោសនៅ?

**ប្រធានអង្គជំនុំ៖**

កុំទាន់អាលឆ្លើយតប។ ក្បាលមីក្រូហ្វូនមិនទាន់ប្រត្តិបត្តិការទេ។

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បាទ មានតែមួយទេដែលយកមនុស្សទៅឃុំឃាំង ប៉ុន្តែដូចខ្ញុំជម្រាបលោកពីមុន--

**ស៖** បាទៗសុំអរគុណ។ ពេលវេលាមានកំណត់ អ៊ីចឹងខ្ញុំចង់បានសំណួរដែល ចម្លើយណាដែលខ្ញុំចង់សួរបាទ។ ខ្ញុំសួរបន្តទៀត តើនៅពេលដែលក្រោយពី៧៩ មកលោកទៅគាស់សាកសព ដែលលោកបានឆ្លើយអម្បាញ់មិញ សួរថាតើនៅពេលនុ៎ង តើមានអគារប៉ុន្មានដែរនៅទីលាននោះ ឬក៏បរិវេណពន្ធនាគារនោះបាទ?

**ឆ៖** ពេលទៅគាស់សាកសព គឺអត់មានអគារអីមួយទេ។ កន្លែងហ្នឹងព្រៃស្មសានសុទ្ធសាធហើយ មានតែព្រៃ ដើមឈើធំតូចតែម្ដង។ អត់មានអគារទេ សូម្បីអគារកាលសម័យខ្មែរក្រហមគេធ្វើដាក់មនុស្ស គេធ្វើដាក់មនុស្សនៅក្នុងដីហ្នឹង វាពុកបាក់ហើយប្រជាជនរុះក្នុងថ្ងៃដែល ៧៩ ហ្នឹងអស់រលីងហើយ។ គាត់រុះយកទៅដុតអស់ហើយ។

[១៤:៣៨:៤០]

**ស៖** បាទ សូមអរគុណ។ នៅពេលដែលលោកទៅដល់ តើនៅក្នុងបរិវេណពន្ធនាគារហ្នឹង ឬក៏មន្ទីរក្រាំងតាចាន់ តើមានរបងមានអីព័ទ្ធជុំវិញទេ? ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** អត់មានរបងឃាំងពីក្រៅទាល់តែសោះ។ ក្នុងសម័យខ្មែរក្រហមលោក គេហៅគុកអត់ជញ្ជាំង មានជញ្ជាំងតែគុកឃុំឃាំងអ្នកទោសដែលខ្ញុំជម្រាបលោកថាមានទទឹងប្រហែលជា ៣ម៉ែត្រ

បណ្ដោយប្រហែលជា ២០ម៉ែត្រជាងមួយហ្នឹងទេ ដែលគេដាក់លួសបន្លាព័ទ្ធពីរបីជាន់ពីលើផងពីក្រោមដីផង បាទ ក្រៅពីហ្នឹងអត់មានរបងទេ។

**ស៖** លោកមានន័យថាលោក នៅក្រៅបរិវេណពន្ធនាគារហ្នឹងឬក៏មន្ទីរហ្នឹងគឺថាអត់មានរបងអីទាំងអស់មានតែលួសនៅក្នុងកន្លែងដែលជាប់ដែលឃុំហ្នឹងតែម្ដងនៅតាមជញ្ជាំង។ តើគេធ្វើជញ្ជាំងហ្នឹងពីអីដែរ?

**ឆ៖** ជញ្ជាំងអគារឃុំឃាំងហ្នឹងធ្វើពីស្លឹកដូងទេ។ ប្រក់ស្លឹកតែលួសបន្លាណ៎ា ទាំងបន្ទាឡាមបន្លាបីជ្រុងហ្នឹង គឺគេយកទៅព័ទ្ធពីរបីជាន់។

**ស៖** បាទ សូមអរគុណ។ តើមាននៅក្នុងនោះមានកន្លែងគេសម្រាប់សួរចម្លើយអ្នកទោសឬទេ?

**ឆ៖** កន្លែងសួរចម្លើយដូចខ្ញុំបានជម្រាបពីព្រឹកមិញហើយ គឺមានរោងមួយនៅជាប់ខាងលិចអគារហ្នឹងនៅផ្ទាល់ដី អត់មានរានឲ្យដេកអីចឹងទេ នៅនឹងដីមានកន្លែង រោងហ្នឹងប្រក់ស្លឹក ក៏ធ្វើជញ្ជាំងពីស្លឹកដូងដែរ។ អ្នកដែលៗត្រូវគេត្រូវសួរចម្លើយទាំងអស់គឺទៅអង្គុយនឹងដីបត់ជើងទាន ហើយអ្នកដែលគេអង្គុយសួរយើងគេមានកៅអីគេ កៅអីឈើ។

**ស៖** តើនៅកន្លែងសួរចម្លើយនោះមានធ្វើ មានទ្វារបិទបើក ឬក៏នរណាក៏អាចមើលឃើញដែរ? គេបាំងឲ្យជិតឈឹងតែម្ដងឬយ៉ាងម៉េចបាទ?

**ឆ៖** គេបាំង ៗស្លឹកដូង ប៉ុន្តែមិនជាជិតអីប៉ុន្មានទេស្លឹកដូងទាន កណ្ដៀរវាស៊ី ពេលខ្ញុំទៅហ្នឹងស្លឹកដូងដូចជាចាស់ណាស់ដែរទៅហើយ ឃើញកណ្ដៀរស៊ីខ្លះៗអីធ្លាក់ប្រហោងអីមើលឃើញខ្លះៗ ប៉ុន្តែសូមជម្រាបលោកផងដែរថាក្នុងរបបខ្មែរក្រហម ដែលគេថាគុកឥតជញ្ជាំងហ្នឹង ខ្លាំងជាងគុកជញ្ជាំងថ្មសសរឥដ្ឋហ្នឹងទៅទៀត។

**លោក សួន វិសាល៖**

បាទ សូមអរគុណ ខ្ញុំមានសំណួរតែប៉ុណ្ណឹងទេ សូមសហការីរបស់ខ្ញុំបន្តបាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ លោកអរគុណមេធាវី អរគុណសាក្សី ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាប់នៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់

សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រលប់មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី មុនអង្គជំនុំជម្រះចូលមកកាន់អាសនៈ។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះបន្ត អង្គជំនុំជម្រះប្រកាសសេចក្តីសម្រេចផ្ទាល់មាត់ទាក់ទិនទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជា លើទម្លាប់នៃការអនុវត្តរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271។ អង្គជំនុំជម្រះបានទទួលសំណើមួយពីក្រុមមេធាវីការពារក្តី នួន ជា ស្នើសុំឲ្យអង្គជំនុំជម្រះពិចារណាឡើងវិញអំពីការអនុវត្តជាក់លាក់មួយចំនួនក្នុងការសួរដេញដោលទៅលើសាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវីការពារក្តី នួន ជា បានសន្និដ្ឋានថាសំណើនេះមានលក្ខណៈជាបន្ទាន់ ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-271 នឹងមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃពុធ សប្តាហ៍នេះ។ អង្គជំនុំជម្រះនឹងសម្រេចលើសំណើនេះជាបន្ទាន់ ដោយផ្ទាល់មាត់ ដោយសេចក្តីសម្រេចដែលមានសំអាងហេតុពេញលេញនឹងចេញនៅពេលក្រោយ។ មេធាវីការពារក្តី នួន ជា ជំទាស់ចំពោះការអនុវត្តជាក់លាក់ចំនួន៣។ ១) ការអនុវត្តនៅក្នុងការអនុញ្ញាតឲ្យសាក្សីអានកំណត់ហេតុនៃការស្តាប់ចម្លើយរបស់ខ្លួនជាមុន មុននឹងមកផ្តល់សក្ខីកម្ម និងបន្ទាប់មកឆ្លើយតបទៅនឹងសំណួរដោយផ្អែកលើឯកសារកំណត់ហេតុនៃការស្តាប់ចម្លើយទាំងនោះ។ ២) ការកម្រិតដែលដែនដែលហួសហេតុពេកនៃវិសាលភាពនៃការសួរដេញដោលរបស់ក្រុមមេធាវីការពារក្តី។ ៣) ការជឿទុកចិត្តហួសហេតុពេកទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចបដិសេធចោលនូវសំណើសុំមេធាវីការពារក្តី នួន ជា។ ហើយសំអាងហេតុជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចនេះនឹងចេញនៅក្នុងពេលឆាប់ៗខាងមុខនេះ។

បាទ ជាបន្តទៅទៀត អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតតាំង តាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ បើសិនបើមាន។ សូមអញ្ជើញ!

[១៥:០៥:៤៦]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**សៈ** ជម្រាបសួរលោក កែវ ច័ន្ទតារ៉ា ខ្ញុំមានសំណួរមួយចំនួនតូចសួរទៅលោក។ សំណួរដំបូងទាក់ទងទៅនឹងប្រវត្តិរបស់លោក ក្រោយពីលោកបានសិក្សាវិជ្ជាខាងផ្នែកវេជ្ជសាស្ត្រ លោកបានបញ្ចប់ការសិក្សានៅម៉ាកសី ទីក្រុងនៅៗបារាំង។ តើនេះជាការត្រឹមត្រូវដែរទេ?

**លោក កែវ ច័ន្ទតារ៉ាៈ**

**ឆៈ** ខ្ញុំមិនបានបញ្ចប់ការសិក្សានៅម៉ាកសីទេ ខ្ញុំគ្រាន់តែទៅទទួលមិត្តម្នាក់ដែលឈ្មោះ ស៊ូ ណែម គេត្រលប់មកប្រទេសកម្ពុជាវិញ។ ខ្ញុំបញ្ចប់ការសិក្សានៅហ្វាំងហ្វាក់ត័រ នៅហ្វាក់មេដេស៊ីនកម្ពុជា។

**សៈ** តើលោកនៅភ្នំពេញ លោកទទួលខាងជំនាញខាងផ្នែក -- បន្ទាប់មកពីបារាំងវិញ លោកមានជំនាញខាងផ្នែកខាងថត ខាងស្កេនហ្នឹង ឬក៏យ៉ាងម៉េចនៅទីក្រុងភ្នំពេញ?

**ឆៈ** នៅទីក្រុងភ្នំពេញនេះ នៅមន្ទីរពេទ្យបីដែលខ្ញុំបានសុំដាក់ពាក្យចូលធ្វើការ។ បាទ នៅក្នុងពេទ្យហ្សុងដាស្ស៊ុងកាល់ម៉ែត្រ ខ្ញុំជំនាញខ្ញុំធ្វើនៅខាងរ៉េអានីដាស្យុង នៅក្នុងមន្ទីរព្រះកេតុមាលា ខាងម៉ាទែរនីតេ នៅក្នុងពេទ្យមិត្តភាពខ្មែរ-សូត្រវៀត ខ្ញុំនៅខាងហ្វេយ៉ាទ្រី។ សូមជ្រាប។

[១៥:០៧:៤៨]

**សៈ** ដូច្នេះនៅក្នុងទសវត្សរ៍ទី៦០ មុនរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ។ តើលោកធ្វើការនៅខាងផ្នែកវិទ្យុសាស្ត្រហ្នឹងនៅឯណា?

**ឆៈ** នៅខាងផ្នែកវិទ្យុសាស្ត្រហ្នឹង ខ្ញុំមិនកាន់កាប់ផ្ទាល់ទេ ប៉ុន្តែគ្រូពេទ្យម្នាក់ៗសួរអាចទៅមើលចូលទៅពិនិត្យក្នុងពេលយើងស្កប់រ៉ាដ្យូក្រាហ្វីហ្នឹង តើប្រព័ន្ធជំងឺហ្នឹងវាយ៉ាងណាៗ យើងគ្រូពេទ្យយើងត្រូវតែដឹង មិនចាំបាច់គេធ្វើការឲ្យយើងមក មិនចាំបាច់អ្នកកាន់រ៉ាដ្យូក្រាហ្វីហ្នឹងគេឲ្យព័ត៌មានទេ។ ត្រូវគ្រូពេទ្យទៅមើលដោយខ្លួនឯង ព្រោះថាការថតយកមកមើលហ្នឹងមិនច្បាស់ដូចយើងទៅមើលនៅ

ក្នុងអេក្រង់របស់វ៉ាដ្យូក្រាហ្វីហ្នឹងទេ។

**ស៖** ខ្ញុំសូមសួរបញ្ជាក់ឲ្យច្បាស់ អ៊ីចឹងថាតើលោកធ្វើជាអ្នកជំនាញវិទ្យាសាស្ត្រ ឬក៏មិនមែនទេ ឬក៏ខាងផ្នែកអ៊ិច្ស-រេ ឬក៏អត់ទេនៅក្នុងទសវត្សរ៍៦០នោះ?

**ឆ៖** សូមប្រសាសន៍លោកម្ដងទៀតទាន។

**ស៖** សំណួររបស់ខ្ញុំងាយទេ គឺថាតើលោកធ្វើជាអ្នកជំនាញខាងផ្នែកវិទ្យុសាស្ត្រនៅមន្ទីរពេទ្យផ្សេងៗនៅក្នុងប្រទេសកម្ពុជាក្នុងទសវត្សរ៍៦០ឬមួយក៏ធ្វើខាងៗផ្នែកម៉ាស៊ីនអ៊ិច្ស-រេ?

**ឆ៖** ខ្ញុំសូមជម្រាបលោករួចស្រេចទៅហើយ ខ្ញុំជំនាញខាងជំងឺទូទៅ។ ដូច្នេះ នៅក្នុងពេទ្យកាល់ម៉ែត្រ ខ្ញុំជម្រាបហើយថាខ្ញុំនៅខាងហ្សេយ៉ាទ្រី -- នៅខាងរ៉េអានីដាស្យុង ពេទ្យហ្វុងដាស្យុងកាល់ម៉ែត្រសព្វថ្ងៃហ្នឹង ពេទ្យព្រះកេតុមាលា កាលហ្នឹងមិនមែនពេទ្យយោធាសព្វថ្ងៃហ្នឹងទេ គឺពេទ្យធំទូទៅនៅក្នុងប្រទេសកម្ពុជា ខ្ញុំនៅខាងម៉ាទែរនីតេ គឺវាជាភាសាខ្មែរគឺសម្ភោធទាន សម្ភពសម្រាលកូនង៉ែត ហើយខ្ញុំសូមដាក់ពាក្យមួយទៀតនៅក្នុងពេទ្យរុស្ស៊ី ព្រោះតែមួយកន្លែងគេឲ្យខ្ញុំធ្វើការតែមួយម៉ោងៗ ខ្ញុំត្រូវធ្វើការឲ្យបានច្រើនកន្លែង ដើម្បីមានប្រាក់ខែដើម្បីចិញ្ចឹមជីវិតនោះ។ បាទ អ៊ីចឹងពេទ្យព្រះកេតុមាលា -- ពេទ្យរុស្ស៊ី – ពេទ្យមិត្តភាពខ្មែរ-សូវៀតកាលពីសម័យនោះ គឺខ្ញុំធ្វើនៅខាង--

**ស៖** សូមទោសលោកដែលខ្ញុំកាត់រំខានលោក។ ថាតើលោកគឺជាអ្នកជំនាញខាងផ្នែកវិទ្យុសាស្ត្រ ឬក៏អត់ទេ?

**ឆ៖** មិនជំនាញខាងផ្នែកវិទ្យុសាស្ត្រទេ។

**ស៖** លោកសាក្សី លោកបានឆ្លើយពីខាងដើមថាលោកពាក់ព័ន្ធនៅក្នុងការគាស់រណ្ដៅសាកសពដែលនៅពេលនោះលោកបានរកឃើញលលាដ៍ក្បាលអ្នកទោសនៅឯក្រាំងតាចាន់។ លោកក៏បាននិយាយខាងដើមថា គឺមានក្បាលហ្នឹងជាងដប់ពាន់នាក់ឯណោះ។ នៅក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយ នៅពេលដែលលោកទៅពិនិត្យមើលនៅមន្ទីរសន្តិសុខក្រាំងតាចាន់ តើលោកមានបានឃើញបូជនីយដ្ឋានដែលគេដាក់លលាដ៍ក្បាលនៅឯក្រាំងតាចាន់ហ្នឹងដែរឬទេ?

[១៥:១១:៣៤]

**ឆ៖** ខ្ញុំមិនមែនគ្រាន់តែបានឃើញទេ ស្តូបមួយដែលដាក់លលាដ៍ក្បាលមនុស្ស ឆ្អឹងមនុស្សហ្នឹង គឺជាការសុំអង្វររបស់ខ្ញុំដល់ឯកឧត្តមនានា អ្នកមានទុនប្រាក់នានា អ្នកដែលមានបងប្អូនស្លាប់ជាកូនជាចៅ ជាមា ជាមីងរបស់គេដែលស្លាប់នោះ ខ្ញុំសុំលុយគេទៅកសាងស្តូបហ្នឹងផង។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះ ថាតើលលាដ៍ក្បាលជាងប៉ពាន់នាក់ហ្នឹងដែលលោកគិតថា ជាជំនួនដែលមានចំនួនប្រហាក់ប្រហែលគ្នា ដូច -- បើយើងរាប់នៅក្នុងពេលឥឡូវនេះ មើលឃើញក្នុងពេលឥឡូវនេះ តើមានចំនួនហ្នឹងវានៅដូចគ្នា ឬក៏ប្រហាក់ប្រហែលគ្នា ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំជម្រាបដល់អង្គប្រជុំរួចហើយតើ ថាលលាដ៍ក្បាលនេះចាប់បាត់តាំងពីថ្ងៃដែលគាស់ដំបូងនោះ ដាក់លលាដ៍ក្បាលហ្នឹងនៅក្បែរមាត់រណ្ដៅនោះ ចាប់បាត់ៗ។ ហើយយើងលើកដាក់ទៅលើផ្ទះមួយដែលយើងយកអង្ករទៅឲ្យគេ១០០គីឡូក្រាមនោះ សូមផ្ទះមួយយកមកដាក់លលាដ៍ ដើម្បីកុំឲ្យជ្រូកឆ្កែ អីពាំលលាដ៍ក្បាលហ្នឹង។ ដល់រាប់ចេញពីហ្នឹងទៅទៀត យកទៅដាក់ក្នុងស្តូបនោះបាត់ទៀតហើយ។ អ៊ីចឹង ក្បាលហ្នឹងនៅតែជាងមួយម៉ឺនក្បាលទេ ជាងមួយម៉ឺនតិចបន្តួចដែលក្បាលនេះ ដែលយើងគាស់មកគឺ១២.១៣២ក្បាល។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះសង្ខេបៗថា តើក្បាលទាំងអស់ហ្នឹងនៅកំពុងតែរក្សាទុកនៅឯស្តូបហ្នឹង ឬយ៉ាងណា?

[១៥:១៣:២៧]

**ឆ៖** ក្បាលដែលរក្សាទុកក្នុងស្តូបហ្នឹង មិនបានគ្រប់គ្រាន់ដូចចំនួនដែលយើងកត់បញ្ជីហ្នឹងទេ។ ពីព្រោះថា ខ្ញុំជម្រាបគ្នាខាងដើមហើយ ឪពុកម្ដាយ បងប្អូន ប្រពន្ធកូន ប្ដីសីគេទៅឈរសមាធិ សុំបួងសួង "បើខ្ញុំទៅចាប់ទៅឲ្យចំក្បាលប្ដីខ្ញុំ" "បើខ្ញុំទៅចាប់ចំក្បាលកូនខ្ញុំ" "បើខ្ញុំទៅចាប់ទៅឲ្យចំក្បាលឪខ្ញុំ"។ ហើយគេចេះតែទៅយកឱបមួយម្នាក់ៗ មួយថ្ងៃពីរបីមនុស្ស ដើម្បីយកក្បាលនេះទៅថែរក្សាទុកធ្វើបុណ្យនៅឯផ្ទះគេនោះ។ នេះជម្រាបលោករួចហើយតើ។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះថា តើលលាដ៍ក្បាលប៉ុន្មានបាត់? ហើយលលាដ៍ក្បាលប៉ុន្មាននៅសល់នៅក្នុងស្តូបសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំអត់ទាន់ធ្វើការរំលែកដែលការបាត់ក្បាលនោះទេ។ ខ្ញុំគ្រាន់តែកត់ត្រាជាព្រះតេជគុណធិរវង្សាចារ្យ ព្រះអនុគណស្រុកត្រាំកក់ និងព្រះសង្ឃទាំងអស់ដែលមាន ៥៦វត្តនៅក្នុងស្រុកត្រាំកក់នេះ គឺកំណត់ក្បាលដែលរាប់ដែលដាក់នៅក្នុងស្តូបនេះមាន ១០.០១៣ក្បាល។ បាទ ១០.០១៣ក្បាល ដែលយកទៅដាក់ក្នុងស្តូប។ ហើយខោអាវដែលជាចំណាំរបស់បងប្អូន ម៉ែឪគេៗ ចំណាំពីផ្ទះមក គេចំណាំថាអាហ្នឹងអាវឪគេ ហ្នឹងអាវម៉ែគេ អាហ្នឹងក្រមារបស់កូនគេ។ ខ្ញុំអត់បានទុកដាក់ទេ គឺបូជាចោលព្រោះថាវាក្លិនស្អុយណាស់ យកតែលលាដ៍ក្បាល ហើយនៅក្នុងនោះលលាដ៍កូនក្មេង រាងដូចវែងអ៊ីចឹង

បន្តិចៗៗនៅក្នុងរណ្ដៅខាងត្បូងផុត ខាងកើតផុតហ្នឹង គឺបើតាមខ្ញុំអង្គុយមើលក្នុងរយៈពេល២៩ថ្ងៃនេះ ច្រើនណាស់កូនក្មេង ព្រោះមកជាមួយម៉ែឪវា។ តែដល់ទៅកាប់ អត់ឃើញក្បាលកូនក្មេងនោះទេ ឃើញតែក្បាលប្រពន្ធ ឃើញក្បាលម្ដាយដែលនៅឱបឆ្អឹងកូនក្មេងនោះនៅឱបលលាដ៍បន្តិចៗរបស់កូនក្មេងហ្នឹង អាហ្នឹងទៅវិញ ឆ្អឹងកូនក្មេងនោះអត់ឃើញទេលោក។

[១៥:១៥:៥០]

**ស៖** លោកសាក្សីខ្ញុំសូមរកកាត់ផ្ដាច់លោក។ ខ្ញុំដឹងថាមានលលាដ៍ក្បាលប្រហែលជាជាង ១៥០០នាក់ តិចជាង២០០០នាក់។ តើខ្ញុំស្មានអ៊ីចឹងវាអាចត្រឹមត្រូវដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

**លោក ត្រាវិស ហ្វារ៖**

លោកប្រធាន ខ្ញុំសូមជំទាស់ចំពោះសំណួរដែលមេធាវីការពារក្ដីសួរបម្លាញ់មិញនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមសួរឡើងវិញ។ លោកសាក្សីថាតើវាអាចជាការពិតទេ ដែលថាសព្វថ្ងៃនេះមានក្បាលប្រហែលជាជាង១០០០នាក់ ទៅ -- ពីជាង១០០០ក្បាល ទៅតែត្រឹម២០០០លលាដ៍ហ្នឹង។ តើវាអាចត្រឹមត្រូវទេ?

[១៥:១៦:៤៩]

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** ខ្ញុំបានជម្រាបលោកហើយតើ ខ្ញុំនិយាយនេះមានសាក្សីរបស់ខ្ញុំជាព្រះសង្ឃ។ ព្រះសង្ឃមិនមានសីលបួន សីលប្រាំ សីលប្រាំបីដូចយើងទេ មានសីល២២៧។ លោកមានពុទ្ធដីកាច្បាស់ណាស់ ព្រះតេជព្រះគុណធិរវង្សាចារ្យព្រះអនុគណស្រុកត្រាំកក់សព្វថ្ងៃនេះនៅបួសវត្តអង្គតាសោម។ លោករាប់ច្បាស់ជាមួយខ្ញុំ ១០.០១៣នាក់។ ១០.០១៣ក្បាល ដែលយកទៅដាក់ក្នុងស្តូបនោះ។ តែចំពោះបងប្អូនម៉ែឪគេទៅសុំចាក់សោ ហើយយកក្បាលជានិមិត្តរូបហ្នឹង យកទៅថែរក្សាទុកធ្វើបុណ្យឯផ្ទះឯសម្បែង ខ្ញុំមិនអាចដឹងទេ។ សូម្បីតែច្រវាក់ធំៗ អាកងខ្នោះអ៊ីចឹងធំៗ អាដាវមួយវែង យកបាត់អស់ហើយ ក្មេងលួចយកទៅលក់ឲ្យពួកអេតចាយអស់ទៅហើយហ្នឹង មានអីជាភស្តុតាងទៀត លោកសួរថ្ងៃនេះ។

**ស៖** តើលោកដឹងថាក្រាំងតាចាន់ -- ខ្ញុំសូមសួរសាថ្មី។ តើលោកដឹងទីតាំងគុកក្រាំងតាចាន់ហ្នឹង

ធ្លាប់ប្រើប្រាស់ជារណ្ដៅសាកសពដែរទេ? ខ្ញុំនិយាយអំពីទីតាំងរណ្ដៅសាកសពទូទៅតែម្ដងនៅក្រាំងតាចាន់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ត្រាវិស ហ្វារ៖**

លោកប្រធាន <ប្រសិនបើអង្គហេតុនេះគឺជា>ភស្តុតាង<ក្នុងសំណុំរឿង យើងចង់ឲ្យមានការលើកយោងឯកសារ។ ហើយប្រសិនបើ>មេធាវីការពារក្ដីយោងទៅលើឯកសារណាមួយ<ផ្សេងទៀត ខ្ញុំក៏សូមឲ្យមានការលើកយោងដែរ។>

**<>លោក វ៉ិចទ័រ កូប៉េ៖**

<ខ្ញុំចង់ឲ្យមេធាវីដឹងអំពីសំណុំរឿងនេះ មុនពេលធ្វើការជំទាស់ ព្រោះថាខ្ញុំបានឃើញការយោងពីរចំណុចនៅក្នុងឯកសារដែលបានដាក់នៅក្នុងអ៊ីនធឺហ្វេស (interface) ដែលមានការលើកឡើងថាទីកន្លែងនេះ ពេលមុនជាទីតាំងរណ្ដៅសាកសព។>

**<លោក ត្រាវិស ហ្វារ៖>**

<លោកប្រធាន ឯកសារមួយនៃ -->

**<សួរដោយលោក វ៉ិចទ័រ កូប៉េ៖>**

<ឯកសារ >E3/2062 និង<ឯកសារ D175/8.90។ ដូច្នេះ >លោកសាក្សី <សំណួររបស់ខ្ញុំគឺថា៖ >តើលោកដឹង<ដែរឬទេ>ថាទីតាំងក្រាំងតាចាន់ហ្នឹង<ពីមុនជា>រណ្ដៅកប់សាកសព<>?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** នៅក្រាំងតាចាន់នេះ ខ្ញុំសូមជម្រាបពាក្យ "ក្រាំងតាចាន់" ហ្នឹងផងដែរ។ ជាចម្ការរបស់តាចាន់ មិនមែនជាកន្លែងកប់សាកសពទេ ពីមុនមក។ "ក្រាំងតាចាន់" ភាសាក្រៀមមួយភាសារបស់ក្រាំងហ្នឹង គឺជាកន្លែងចម្ការមួយយូរណាស់មកហើយរបស់តាចាន់។ ហើយមិនមែនជាកន្លែងកប់សាកសពទេ ជាចម្ការរបស់គាត់ ជាកម្មសិទ្ធិរបស់គាត់ដែនដីហ្នឹង។

[១៥:២០:០០]

**សះ** ខ្ញុំគ្រាន់តែ -- គឺE3/62 (សូមទោស) កែប្រែពី02 គឺ អង់គ្លេស 0031 -- 00301363 ក្រាំងតាចាន់ធ្លាប់ជាកន្លែងព្រៃស្ងប់ស្ងាត់ ហើយជាកន្លែងទីស្មសានដែលគេកប់សពតាំងពីដូចតាមក។ គឺ

រួចហើយក៏ជារណ្ដៅសាកសពនៅក្នុងរបប ប៉ុល ពត – បនប៉ុល ពត, អៀង សារី។ ថាតើខ្ញុំសួរអ៊ីចេះ សួរថាតើវាពិតទេ ដែលថាក្រាំងតាចាន់ពីមុនមកធ្លាប់ជាទីស្មសាន?

**ឆ៖** បាទ សូមលោកជ្រាបឲ្យច្បាស់ថា ព្រៃស្មសាន គឺជាព្រៃស្ងាត់។ មិនមែនចាំតែកន្លែងកប់សព បានគេហៅថា ព្រៃស្មសានទេ ព្រៃស្ងាត់។ តែតាចាន់ ទៅធ្វើចំការនៅកន្លែងហ្នឹង គឺជាការស្ងាត់ ហើយផ្ទះនៅជុំវិញនោះ ក៏ពុំទាន់មានដែរ មានតែភូមិមួយនៅជ្រុងនិរតី ភូមិមួយនៅជ្រុងឧត្តរ និងភូមិនៅជ្រុងខាងអាគ្នេយ៍តែប៉ុណ្ណឹងទេ។ ហើយតាចាន់ គាត់ទៅធ្វើនៅកន្លែងហ្នឹង មិនមែនកប់សាកសពទេពីមុនមក ខ្ញុំសួរហើយស្រេចទៅហើយ។

**ស៖** មូលហេតុដែលខ្ញុំសួរ ដោយសារថាធ្លាប់ជាទីកន្លែងកប់សពមុនឆ្នាំ១៩៧៥ ឬក្នុងទសវត្សរ៍ ៦០។ តើមាននីតិវិធីអ្វីកំណត់ឲ្យច្បាស់លាស់ថា ក្បាលដែលបានគាស់ឃើញហ្នឹង ជាលលាដ៍ក្បាលពីរបបខ្មែរក្រហម -- លលាដ៍ក្បាលពីក្រាំងតាចាន់នុ៎ង? នៅពេលដែលចូលរួមបដិវត្តក្នុងឆ្នាំ៧០ តើលោកធ្លាប់ស្គាល់ឈ្មោះសហការីបដិវត្តដែលលោកធ្លាប់ធ្វើការជាមួយចន្លោះពី៧០ ទៅ៧៥ទេ ធ្លាប់បានជួបអតីតសហការីលោកទេ?

[១៥:២២:២៩]

**ឆ៖** ពីឆ្នាំ១៩៧០ ទៅទល់គ្នា៧៥ មកថ្ងៃនេះ យើងបាត់បង់គ្នាគ្មីអស់ គ្មានសល់។ អ៊ីចឹងហើយបានជាខ្ញុំសំណូមពរដល់អង្គជំនុំជម្រះសាលាក្ដីនេះ រួតរះកាត់ឲ្យបានរហ័សរហួន កុំថាឡើយថាភាគីជាប់ចោទ ភាគីអ្នកដើមបណ្ដឹង ភាគីសាក្សី ដូចរូបខ្ញុំនេះ អាយុពិតប្រាកដរបស់ខ្ញុំ ៨០ឆ្នាំទៅហើយ ខ្ញុំនឹងស្លាប់ខានបានមកចូលរួម--

**ប្រធានអង្គជំនុំ៖**

សាក្សីមានករណីយកិច្ចឆ្លើយតបនឹងសំណួរ។ សាក្សីមិនគប្បីធ្វើសំណើសុំអ្វីផ្សេងៗទេ។ ជំរុញនីតិវិធីអីទេ នុ៎ងជារឿងកិច្ចការរបស់អង្គជំនុំជម្រះដែលត្រូវប្រឹងប្រែង។ ស្ដាប់សំណួរឲ្យបាន ហើយឆ្លើយតបទៅនឹង ចាំបាច់ និងពេញលេញ សមស្របទៅនឹងសំណួរដែលសួរបានហើយ។ កាលណាលោកឆ្លើយវែងទៅ វានាំឲ្យអាចម្លើយដែលលោកលានចេញដែលមិនភាពចាំបាច់ វាទៅជាពាក់ព័ន្ធនឹងការសួរបន្ថែម សំណួរបន្ថែមៗទៀត ហើយធ្វើឲ្យលោកហ្នឹង មានការភាពអាចទប់អារម្មណ៍មិនបាន។ ព្យាយាមអាចឆ្លើយតិច។ និយាយរួមពាក្យថាតុលាការ ខ្មែរគេប្រើពាក្យថា “សួរអីឆ្លើយនឹង”។ នេះជាពាក្យខ្មែរដែលយើងប្រើទូទៅ។ គេសួរអំពីបញ្ហាអី ឆ្លើយតបអំពីបញ្ហាហ្នឹងបានហើយ។ នេះគឺជាចម្លើយ

តបនៅចំពោះមុខតុលាការ។

[១៥:២៤:១២]

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងរៀបចំសំណួរឡើងវិញ ដើម្បីឲ្យងាយយល់។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** នៅចន្លោះពីឆ្នាំ១៩៧០ ទៅ៧៥ លោកធ្លាប់បានជួបជនបដិវត្ត ដូចជា ហ៊ូ នឹម, ហ៊ូ យន់, ជួន ជឿន។ តើលោកធ្លាប់រស់នៅជាមួយអ្នកទាំងអស់នេះដែរ ក្នុងអំឡុងពេលនោះ?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** ខ្ញុំមិនបានរស់នៅជាមួយ ហ៊ូ យន់, ហ៊ូ នឹម បើឌុកទ័រ ជួន ជឿន យើងធ្លាប់បានទៅជួបគ្នានៅដំណាក់ស្នួល។

**ស៖** តើៗអតីតសហការី ដូចជាវេជ្ជបណ្ឌិត ជួន ជឿន ជាដើម តើលោកធ្លាប់បានជួបទេក្នុងអំឡុងពេលនោះ?

**ឆ៖** ក្នុងឆ្នាំ១៩៧០ យើងចេញពីភ្នំពេញទៅជាមួយគ្នា។ តែទៅដល់នោះខ្មែរក្រហមបំបែកយើងអត់ឲ្យនៅជាមួយគ្នាទេ។ ខ្ញុំនៅភូមិដំណាក់ស្នួល សព្វថ្ងៃនេះក្នុងស្រុកជុំគីរីខេត្តកំពតឯណោះ។ ហើយលោកជួន ជឿន គឺធ្វើដំណើរចេញពីខ្ញុំទៅ គេថាគេជូនលោកទៅភូមិភាគឧត្តរ។ ខ្ញុំក៏អត់ដឹងថាគាត់ទៅកន្លែងណាដែរ។

**ស៖** សំណួររបស់ខ្ញុំថាតើលោកចាត់ទុកថាខ្លួនឯង ថាជាជនបដិវត្តចន្លោះពីឆ្នាំ៧០ ទៅ ៧៥ ដែរទេ?

**ឆ៖** ខ្ញុំតាំងខ្លួនខ្ញុំថា ជាខ្ញុំជាអ្នកបម្រើថោកទាបបំផុតរបស់របបខ្មែរក្រហម គឺរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង មិនមែនជាជនបដិវត្តទេ។

**ស៖** តើលោកធ្វើជាវេជ្ជបណ្ឌិតនៅសមរភូមិមុខ ដើម្បីព្យាបាលកងទ័ពខ្មែរក្រហមដែលរបួសនៅសមរភូមិ ឬក៏អត់ទេ?

**ឆ៖** ក្នុងនាមជាគ្រូពេទ្យអត់មានរើសអើងថាអ្នកនេះ ខ្ញុំគេ អ្នកនេះស្ដេច មន្ត្រី ឬសេដ្ឋី អ្នកមានអ្នកក្រអីទេ សូម្បីសត្វតិរច្ឆាន ឲ្យតែមានជំងឺ ជួបប្រទះគ្រូពេទ្យតែងតែសង្គ្រោះទាំងអស់។ ហើយគ្រូពេទ្យអត់មានសត្រូវជាមួយបក្សណា ពួកណាដែរ។

[១៥:២៦:៥៨]

**ស៖** ជាថ្មីម្តងទៀតលោកសាក្សី នេះមិនមែនជាសំណួររបស់ខ្ញុំទេ។ សំណួរខ្ញុំ សួរថាតើលោកគឺធ្វើជាពេទ្យយ៉ាងសកម្ម ជួយព្យាបាលកងទ័ពខ្មែរក្រហមដែលរបួសនៅពេលប្រយុទ្ធជាមួយទាហានលន់ នល់ដែរឬក៏អត់?

**ឆ៖** យើងទៅនៅកន្លែងនុ៎ងទៅហើយ យើងមិនជួយគេយ៉ាងម៉េច? យើងត្រូវតែជួយធ្វើព្យាបាលគេ តាមលទ្ធភាពដែលធ្វើទៅបាន។

**ស៖** ខ្ញុំសូមសួរផ្សេងពីនេះ ថាតើលោកធ្វើជាវេជ្ជបណ្ឌិតនៅភ្នំពេញ ឬក៏ជាអ្នកជំនាញខាងផ្នែកវេជ្ជសាស្ត្រ ជួយទៅដល់ខ្មែរក្រហមក្នុងការព្យាបាលកងទ័ពខ្មែរក្រហម ដែលវាយប្រយុទ្ធជាមួយនឹងកងទ័ពលន់នល់។ ដែលលោកគឺថា ដែលៗតើលោកដើរតួយ៉ាងសំខាន់នៅក្នុងសង្គ្រាមរំដោះប្រទេសជាតិហ្នឹងដែរឬក៏អត់?

**ឆ៖** ខ្ញុំ អត់បានតាំងខ្លួនថាជាជនសំខាន់នៅក្នុងរបបខ្មែរក្រហមនោះទេគឺ ខ្ញុំនៅតែគិតថាខ្ញុំជាគ្រូពេទ្យម្នាក់ដែលខ្ញុំតែងតែជួយសង្គ្រោះសត្វមនុស្សលោកទាំងអស់ កុំថាបារាំង អាល្លឺម៉ង់ អ៊ីតាលីអេស្ប៉ាញ៉ុលអី គឺមើលទាំងអស់ ជួយព្យាបាលទាំងអស់។ សូមជ្រាប។

**ស៖** លោកសាក្សី មេត្តាកុំឆ្លើយវាងនេះ -- ខ្ញុំសួរ ព្រោះ -- គឺងាយទេ ថាតើលោកពិតជាបានជួយដល់ខ្មែរក្រហមនៅក្នុងពេលគេប្រយុទ្ធរំដោះប្រទេសជាតិ។ មានន័យ ខ្ញុំសួរថាតើលោកបានជួយព្យាបាលកងទ័ពខ្មែរក្រហមរងរបួសដោយការប្រយុទ្ធវាយជាមួយទាហានលន់ នល់ដែរទេ?

**ឆ៖** ពិតជាបានជួយ បើយើងមិនជួយយើងធ្វើគ្រូពេទ្យធ្វើអី។

[១៥:២៩:១៦]

**ស៖** សូមអរគុណលោកសាក្សី។ សំណួរបន្ទាប់របស់ខ្ញុំគឺ មូលហេតុនៃការ គឺនៅក្នុងខែមីនា ឆ្នាំ១៩៧៥ លោកត្រូវបានចាប់ខ្លួន។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះមូលហេតុ អំពីមូលហេតុចាប់ខ្លួនបានទេ? លោកអាចគិតមើលថាហេតុអ្វីបានជាគេចាប់ខ្លួនលោក?

**ឆ៖** អាហ្នឹង ខ្ញុំមិនដឹង ទាល់តែសួរគេអ្នកចាប់។ ពីព្រោះខ្ញុំអត់ដឹងខ្លួនថាខ្ញុំមានកំហុសអ្វីដែរ។ ជាងមួយម៉ឺននាក់នៅមន្ទីរក្រាំងតាចាន់ត្អូញត្អែរប្រាប់គ្នាថា “យើងអត់ដឹងខុសអ្វីសោះ ប៉ុន្តែខ្មែរក្រហមគេចេះតែចាប់យើងទៅធ្វើទោស ធ្វើទារុណកម្ម”។

**ស៖** លោកសាក្សី គឺថាស្ថិតក្នុងពេលហ្នឹង តើលោកជាជនបដិវត្ត ឬក៏ជាវេជ្ជបណ្ឌិត ដោយសារ

មូលហេតុថា គ្រាន់តែឆ្នាំ៧៥ លោកត្រូវបានចាប់ខ្លួន? តើអ្នកគេចាប់ខ្លួនហ្នឹង គេមានបានប្រាប់លោកទេ ថាបានជាគេចាប់ខ្លួន គឺលោកខុសអ៊ីចេះ ខុសអ៊ីចុះទេ?

**ឆ៖** លោកសួរដដែលៗ ខ្ញុំជម្រាបរួចហើយ។ ខ្ញុំពិចារណាខ្លួនខ្ញុំហ្នឹង មិនទាន់ដឹងខុសពីអ្វីទេ ដែលគេចាប់យកទៅហ្នឹង។ មិនមែនរូបខ្ញុំម្នាក់ទេ ព្រះសង្ឃក្តី ស្តេច--

[១៥:៣០:៤៩]

**ប្រធានអង្គជំនុំ៖**

លោកៗលោកសាក្សី គេសំណួរមិនសួរអ៊ីចឹងទេ សួរថាពេលដែលគេចាប់លោកហ្នឹង គេប្រាប់ថាលោកខុសរឿងអីទេ? បើលោកមិនដឹងទេ លោកឆ្លើយថាទេ។ បើលោកដឹងគេប្រាប់ថាម៉េច លោកអាចរៀបរាប់នូវពាក្យពេចន៍ដែលពួកខ្មែរក្រហមហ្នឹង ប្រាប់លោកនុង់ណា! ថាគេប្រាប់លោកហ្នឹង ថាលោកខុសរឿងអី បានគេចាប់ខ្លួនអ៊ីចឹង លោកពេលហ្នឹង បានហើយ។ យើងបានប្រាប់ហើយ ម្តងហើយម្តងទៀតថា សូមរៀប -- ចាប់ស្តាប់សំណួរឲ្យបាន។ ឆ្លើយតបទៅនឹងភាពចាំបាច់ និងសមស្របទៅនឹងចម្លើយហ្នឹងបានហើយ ចៀសវាងឆ្លើយវែងអន្លាយហួសពីព្រំដែនចាំបាច់នៃការឆ្លើយតប វានាំឲ្យមានបន្ទុកទៅលើសាក្សីខ្លួនឯង។ អាកន្ទុយហ្នឹង វានឹងអាចបង្កើតនូវសំណួរផ្សេងៗទៀត។ ហើយតុលាការអត់ចង់បានទេ ពីព្រោះសំណួរដែលមិន -- ចម្លើយដែលមិនសួរ គឺមិនមានប្រយោជន៍អីនៅក្នុងរឿងយក -- អង្គជំនុំជម្រះយកទៅពិចារណានោះឡើយ។

**ស៖** បាទជាថ្មីម្តងទៀត លោកសាក្សី តើលោកអាចប្រាប់ពីមូលហេតុ លោកអាចដឹងអំពីមូលហេតុ តើហេតុអ្វីបានជាគេចាប់ខ្លួនលោក? ក្នុងនាមជាជនបដិវត្ត ឬក៏ជាវេជ្ជបណ្ឌិតអ៊ីចឹង ខ្ញុំៗជឿថាអ្នកចាប់ហ្នឹង មានហេតុផលអាចនឹងប្រាប់លោកបានហើយ។

**ឆ៖** ខ្ញុំអត់បានដឹងថា ខ្ញុំមានកំហុសអី។

**ស៖** មិនបញ្ហាអ្វីទេ វាមិនទាន់ច្បាស់នៅឡើយទេ ថាតើហេតុអ្វីបានជាគេចាប់ខ្លួនលោក។ តាមដែលខ្ញុំយល់ គឺនៅក្នុងខែមីនា ឬក៏ខែមេសា ឆ្នាំ១៩៧៥ លោកត្រូវបានចាប់ខ្លួន។ ដូចដែលយើងទាំងអស់គ្នា គឺនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ជាថ្ងៃសំខាន់បំផុត។ តើគេនៅឃុំខ្លួនលោកនៅឡើយ ឬក៏យ៉ាងម៉េចនៅថ្ងៃរំដោះនុង់? ឬក៏គេដោះលែងខ្លួនលោកភ្លាមៗមុនថ្ងៃរំដោះ? ឬក៏ដោះលែងក្រោយថ្ងៃរំដោះ ១៧ មេសា ៧៥?

[១៥:៣៣:១២]

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ
ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

**ឆ៖** បាទគេយកខ្ញុំបញ្ចេញពីមន្ទីរឃុំឃាំងក្រាំងតាចាន់ ក្រោយថ្ងៃរំដោះ១៤ថ្ងៃ។ ក្រោយថ្ងៃរំដោះ ១៩៧៥ ហ្នឹង ១៤ថ្ងៃ។

**ស៖** ដូច្នេះចម្លើយរបស់លោកហ្នឹង គឺគេដោះលែងនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៧៥។ តើអ៊ីចឹងទេ?

**ឆ៖** មិន ដូចមិនមែនអ៊ីចឹងទេ ព្រោះគេរំដោះបានថ្ងៃ១៥ ខែមេសា រំដោះបើតាមខ្ញុំចាំ ថ្ងៃហ្នឹងថ្ងៃ១៥ ខែមេសា ហ្នឹង។ ហើយខ្ញុំរួចក្រោយថ្ងៃ១៥ ខែមេសា ហ្នឹងទាន ចេញពីក្រាំងតាចាន់ហ្នឹងមក។ គឺយើងចេញមក ឃើញមនុស្សព្រោងព្រាតចេញមកភ្នំពេញហើយ។ ហើយនៅក្នុងមន្ទីរក្រាំងតាចាន់ ក៏ឃើញអ្នកមកពីភ្នំពេញហ្នឹង គេបញ្ជូនទៅក្រាំងតាចាន់ហ្នឹងដែរ។ អ៊ីចឹង គឺក្រោយថ្ងៃរំដោះ ៧៥ ខែមេសា ហ្នឹងហើយ។ ហ្នឹងខ្ញុំចំណាំអ៊ីចឹង។

**ស៖** ខ្ញុំជឿជាក់ថា លោកសាក្សីប្រហែលកំពុងតែច្រឡំជាមួយនឹងថ្ងៃរំដោះហើយ។ គឺលោកនិយាយថា ចង់ -- លោកចង់និយាយថា គឺក្រោយថ្ងៃរំដោះ គឺនៅថ្ងៃ១៥ ខែមេសា ៧៥ ហ្នឹងមានមនុស្សនៅក្រាំងតាចាន់ហើយ។ លោកចង់និយាយអ៊ីចឹង?

**លោក ត្រាវិស ហ្សារ៖**

ខ្ញុំសូមជំទាស់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ អ្នកជំទាស់!

**លោក ត្រាវិស ហ្សារ៖**

សាក្សីមិនបាននិយាយថា ប្រជាជន១៧មេសា មកដល់ក្រាំងតាចាន់ហ្នឹង នៅខែមេសា ហ្នឹងទេ។

[១៥:៣៥:១៤]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ហើយខ្ញុំក៏ច្របូកច្របល់ដោយសារតែចម្លើយរបស់សាក្សីហ្នឹងដែរ។ អ៊ីចឹងខ្ញុំសូមសួរតទៅមុខទៀតទៅចុះ។ លោកសាក្សី ដោយសារតែចំណុចនេះវាសំខាន់ណាស់ដើម្បីឲ្យខ្ញុំស្វែងយល់ឲ្យបានត្រឹមត្រូវ។ ថាតើក្រោយថ្ងៃរំដោះប៉ុន្មានថ្ងៃដែលលោកនៅក្រាំងតាចាន់ហ្នឹង គឺរហូតដល់ក្រោយថ្ងៃរំដោះប៉ុន្មានថ្ងៃ?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បាទ ថ្ងៃរំដោះទូទាំងប្រទេសនោះ គឺថ្ងៃ១៧ មេសា អ៊ីចឹងមែនទេ? ក្រោយថ្ងៃ ១៧ មេសា ហ្នឹងបាទ គឺជាង១០ថ្ងៃខ្ញុំបានរួចហើយ ខ្ញុំបានចេញពីក្រាំងតាចាន់ហើយ ព្រោះខ្ញុំបានឃើញមនុស្សមក ពីភ្នំពេញចូលទៅដល់ក្រាំងតាចាន់ហើយ។ ខ្ញុំមកដល់វត្តចំប៉ាវិញ ឃើញអ្នកដែលគេរំដោះពីភ្នំពេញក៏មក នៅវត្តចំប៉ា គេបញ្ជូនទៅនេះ ទៅណាខ្លះច្រើនដែរ។

**ស៖** លោកសាក្សី <>លោកមិនអាចផ្ដល់សក្ខីកម្ម<ពាក់ព័ន្ធនឹងមូលហេតុដែលលោកត្រូវបាន>គេចាប់ខ្លួន<ទេ។ ប៉ុន្តែ> តើលោកអាច<ប្រាប់យើង>បានទេអំពីសំណួរទាំងឡាយដែលកម្មាភិបាលខ្មែរក្រហម<គ្នាលោកបាន> សួរមកលោក<>?

[១៥:៣៦:៤៧]

**ឆ៖** ខ្ញុំចាប់អារម្មណ៍ពីរ។ ទី១ គេខ្សឹបខ្សៀវគ្នាថា “ជនដែលជាសីហនុនិយម មិនគួរទុក។ គួរយកទៅកសាង កែប្រែអប់រំ ឬក៏ពិឃាដចោល កម្ទេចចោលតែម្ដង”។ អារម្មណ៍ទីពីរ ខ្ញុំនឹកឃើញថា “បញ្ញវន្តអនុធន ជាស្រទាប់សើរើ មិនគួរទុក ត្រូវតែកម្ទេច”។ ហ្នឹងឮគេនិយាយអ៊ីចឹង។ ប្រហែលខ្ញុំ នៅសង្ស័យតែរឿងហ្នឹងទេ។

**ស៖** ប៉ុន្តែលោកជាអ្នកបដិវត្តនដែរ ហើយលោកក៏បានចូលព្រៃម៉ាកគី អ៊ីចឹង បើដោយសារលោកខាងខ្មែរក្រហមដែរ លោកក៏ជាទាហានដែរ ហើយប្រហែលជាផ្នែកខាងពេទ្យហ្នឹងពិតប្រាកដហើយ។ អ៊ីចឹងតើកាលនោះគេសួរសំណួរអីខ្លះទៅលោកនោះ?

**ឆ៖** លោកសួរសំដៅត្រង់នៅក្នុងមន្ទីរក្រាំងតាចាន់ ឬមួយនៅក្នុងមន្ទីរនានាដែលខ្ញុំបានចូលទៅរួមការងារ?

**ស៖** <សូមប្រាប់ខ្ញុំតែសំណួរពីរបីដែលកម្មាភិបាលខ្មែរក្រហមគ្នាលោកបានសួរមកលោក។>

**ប្រធានអង្គជំនុំ៖**

ស្ដាប់អត់បានទេ អត់យល់ទេ ខ្មែរហ្នឹងមិនយល់សោះតែម្ដង។ លោក កូប៉េ តាំងសំណួរសាជាថ្មីម្ដងទៀត។ សួរខ្លីបានហើយ សួរឲ្យច្បាស់លាស់។ ភាសាខ្មែរហ្នឹងស្ដាប់អត់យល់ទេ បកប្រែហ្នឹង។ អ៊ីចឹងឆ្លើយមិនកើតទេ ព្រោះអ្នកស្ដាប់ទូទៅហ្នឹងបកប្រែមិនយល់ផង យើងប្រធានអង្គជំនុំជម្រះមិនយល់ផង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ សំណួរសួរម្តងទៀត។ ខ្ញុំសួរលើសំណួរដែលគេសួរទៅលោក អ្នកដែលនៅរួម កម្មាភិបាលធ្វើការជាមួយលោកនោះ តើគេសួរអីខ្លះទៅលោក កាលនោះនៅក្រាំងតាចាន់ ឬក៏កន្លែងផ្សេងទៀតក៏ដោយ គេសួរសំណួរអីខ្លះទៅលោក? ហើយទាក់ទងនឹងរឿងរ៉ាវលោកនោះ តើហេតុអីបានជាគេចាប់ខ្លួនលោក តើគេសួរលោកបានធ្វើអីខ្លះ? គេចោទប្រកាន់រឿងអីខ្លះទៅលើលោក? អ៊ីចឹងលោកអាចនិយាយឲ្យបានលម្អិតបន្តិចបានទេ? គេសង្ស័យរឿងអីខ្លះ?

**ឆ៖** នៅក្នុងមន្ទីរក្រាំងតាចាន់ គេជជីកសួរខ្ញុំតែពីរឿងថា "ជនណាដែលមកបំពាក់ សេ.អ៊ី.អា ឲ្យលោកឯង? ឲ្យសមមិត្តឯង? ជនណាដែលមកបំពាក់ កា.ហ្សេ.បេ ឲ្យសមមិត្តឯង?" គេសួរតែប៉ុណ្ណឹង។ ខ្ញុំថា "គ្មាន"។ ខ្ញុំមិនដែលបានទទួល។ ហើយពាក្យទាំងអស់ហ្នឹង ខ្ញុំក៏មិនទាន់យល់ថា ជាអ្វីដែរ អាកា.ហ្សេ.បេ, អាសេ.អ៊ី.អា អីហ្នឹងខ្ញុំមិនស្គាល់ផង។

**ស៖** អ៊ីចឹងសូមលោកឲ្យ និយាយឲ្យច្បាស់បន្តិចមើល ថាហេតុអីបានគេគិតថាលោកពាក់ព័ន្ធនឹងខ្សែ សេ.អ៊ី.អា ឬក៏ កា.ហ្សេ.បេ អីហ្នឹង។ គេមានសួរឈ្មោះ រកសុំឈ្មោះ រកកិច្ចប្រជុំអីដែល ឲ្យ -- សូមផ្តល់ព័ត៌មានឲ្យច្បាស់លាស់បន្តិចមើល ម៉េចបានគេសង្ស័យអ៊ីចឹង?

[១៥:៤០:៣២]

**ឆ៖** ខ្ញុំមិនដឹងថា ខ្ញុំមានកំហុសអី ដូចជម្រាបលោកពីខាងដើមអ៊ីចឹង។ គេសួរ គេសួរប៉ុណ្ណឹង ខ្ញុំក៏រកនឹកមិនឃើញដែរ អាពាក្យទាំងអស់ហ្នឹង ព្រោះខ្ញុំមិនដែលទៅរៀនសូត្រ កា.ហ្សេ.បេ ហ្នឹង។ មិនដែលទៅរៀនសូត្រ សេ.អ៊ី.អា ហ្នឹងដែរ។ ខ្ញុំដូច បើរៀនពេទ្យ ខ្ញុំយល់។ បើគេសួរថាអ្នកឯងចេះពេទ្យស្អីខ្លះខ្ញុំប្រាប់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតសំណួរទៀតលោក កូប៉េ!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើគេឲ្យលោកសរសេរចម្លើយសារភាពអីទេ?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** គេអត់បានឲ្យសរសេរចម្លើយសារភាពអីទេ។

**ស៖** លោកសាក្សី ខ្ញុំដូចជាអស់អែកដល់ហើយ ខ្ញុំឆ្ងល់លោកជាមិត្តភក្តិរបស់ តាម៉ុក។ អ៊ីចឹង

តើយើងត្រូវយល់ថា លោកហ្នឹងជាអ្នកបដិវត្តន៍ពិតប្រាកដ ហើយអង្កាល់នោះ ជិត -- គេជិតធ្វើបដិវត្តន៍ ហើយក្រោយមកស្រាប់តែលោកត្រូវបានគេចាប់ខ្លួន ហើយគេឃុំខ្លួនដល់បួនសប្ដាហ៍ ហើយលោកអត់មានចាំសំណួរដែលគេសួរទៅលោកទេ ពេលនោះ។ អ៊ីចឹងគេមិនឱ្យលោកសរសេរជាលាយលក្ខណ៍អក្សរ ចម្លើយសារភាពទេអី? អ៊ីចឹងខ្ញុំគិតថាលោកប្រហែលជាលោកមិនត្រូវបានគេចាប់ខ្លួនទេ ហើយមិនដែលបានគេឃុំខ្លួននៅក្រាំងតាចាន់ទេ ហើយកន្លែងផ្សេងក៏មិនត្រូវបានឃុំខ្លួនលោកដែរ។ តើការយល់របស់ខ្ញុំនេះត្រឹមត្រូវទេ?

[១៥:៤២:២១]

**ឆ៖** ខ្ញុំយល់ថា លោកយល់ហ្នឹងអត់ទាន់ត្រឹមត្រូវទេ ព្រោះលោកថា គេមិនបានចាប់ខ្លួន។ ខ្ញុំត្រូវបានគេចាប់ខ្លួន។ ខ្លួនខ្ញុំ ខ្ញុំយល់ជាងលោក។ អ្វីដែលខ្ញុំធ្វើ គឺខ្ញុំស្គាល់ច្បាស់នៅខ្លួនខ្ញុំ ហើយលោកនៅ មិនមែនខ្លួនខ្ញុំផង លោកម៉េចដឹង? ម៉េចក៏--

**ប្រធានអង្គជំនុំ៖**

បន្តទៅទៀតបានហើយ ប្រហែលជាទំនងអស់សំណួរហើយលោក កូប៉េ តាមសំណួរចុងក្រោយដូចវាអត់មាន ទំនងមិនមានរួមវិភាគទានអីឱ្យតុលាការស្វែងរកថា ពិតលើចម្លើយតបរបស់សាក្សីរូបនេះទេ ហើយបញ្ហាសំណួរចុងក្រោយអម្បាញ់មិញនេះ គឺមានលក្ខណៈជាការធ្វើសេចក្ដីសន្និដ្ឋាន ហើយឱ្យសាក្សីឆ្លើយបញ្ជាក់នៅលើសេចក្ដីសន្និដ្ឋានរបស់មេធាវី។ ប្រភេទសំណួរនេះ យើងបានហាមឃាត់មិនឱ្យប្រើប្រាស់ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគ្រាន់តែនិយាយអំពីអ្វីដែលខ្ញុំគិតឃើញតែប៉ុណ្ណឹងទេ ព្រោះថាកាលនោះគាត់ជាពេទ្យ អ៊ីចឹងគាត់គួរតែយល់ហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវនេះ ខ្ញុំសូមសួរសំណួរផ្សេងទៀត។ លោកសាក្សី លោកអាចនិយាយអំពីអ្នកទោសស្រីម្នាក់ដែលជាប់ទោសជាមួយ ជាប់ឃុំឃាំងជាមួយលោកនៅក្រាំងតាចាន់ដែរឬទេ?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** អ្នកស្រី កែវ សំអាត អ៊ីចឹងអេ្ហស៎?

**ស៖** បាទ គឺជា -- ហ្នឹងហើយអ្នកទោសម្នាក់ដែលនៅសប្ដាហ៍ដែលលោកនៅក្រាំងតាចាន់ដែរ

ហ្នឹងអ៊ីចឹងមែនទេ?

[១៥:៤៣:០៨]

**ឆ៖** បាទ កែវ សំអាត ហ្នឹងវាជាប់ទោសក្នុងអាយុមិនទាន់គ្រប់អាយុផងទេ គឺប្រហែលជាអាយុ១៣ ឬ១៤ឆ្នាំ។ ប៉ុន្តែពាក់ព័ន្ធទៅលើបងប្អូន កូនក្មួយរបស់គាត់ហ្នឹង គេយកទៅសម្លាប់ច្រើននៅក្នុងទីណាៗនោះ មិនកន្លែងក្រាំងតាចាន់ហ្នឹងទាំងអស់ទេ ហើយក៏គេចាប់ខ្លួនវាទៅ។ លោកចង់សួរថាម៉េចជាមួយ កែវ សំអាត ហ្នឹង?

**ស៖** ខ្ញុំគ្រាន់តែចង់ដឹងថា តើគាត់នៅរស់ដែរទេសព្វថ្ងៃនេះ?

**ឆ៖** ពេលបែកចេញពីគ្នាមកក្នុងរំដោះ១៩៧៩នេះ ខ្ញុំជួបគាត់ពីរដង។ តែមកដល់ឥឡូវនេះប្រហែលជា២០ឆ្នាំហើយ ជិត៣០ឆ្នាំទៅហើយ មិនដែលបានជួបទៀតទេ។ តែការជួបគេនោះ គេជាអ្នកគ្រូបង្រៀននៅមតេយ្យ។ ឥឡូវអត់ដែលបានជួបទេ។

**ស៖** ខ្ញុំដូចជាមិនយល់ចម្លើយលោកប៉ុន្មានទេ។ ឥឡូវខ្ញុំសួរម្តងទៀត។ បន្ទាប់ពី -- ក្រោយឆ្នាំ១៩៧៩ លោកបានជួបគាត់។ អ៊ីចឹង ខ្ញុំសួរសំណួរថាតើបានជួបគាត់នៅលើកចុងក្រោយនៅពេលណាដែរ?

**ឆ៖** ខ្ញុំមិនបានកត់ត្រាថ្ងៃខែឆ្នាំដែលជួបគាត់នោះ។ ក៏ដូចជាការជួបហ្នឹង ដូចជាគ្មានអ្វីគួរឲ្យសំខាន់។ អត់មានកត់អីទុកផង អត់មានចំណាំក្នុងចិត្តផង ហើយក៏ខ្ញុំមិនអាចចងចាំបាននៅក្នុងពេលនេះដែរ។

**ស៖** តើពីរបីឆ្នាំមុន ឬក៏ ២០ឆ្នាំមុន ឬក៏ ៣០ឆ្នាំ ឬយ៉ាងម៉េច? ជួបគាត់លើកចុងក្រោយហ្នឹង?

**ឆ៖** ជួបចុងក្រោយហ្នឹងគឺជាង ២០ឆ្នាំទៅហើយ ព្រោះ ៧៩ មកឥឡូវ ២០១៥។

**ស៖** បាទ ទាក់ទងទៅហ្នឹងអ្នកទោសស្ត្រីម្នាក់ហ្នឹង តើលោកមានរឿងអ្វីអាចនិយាយរៀបរាប់បានទៀតទេទាក់ទងនឹងគាត់? តើលោកគឺជាអ្នករស់រានមានជីវិតតែប៉ុន្មាននាក់ហ្នឹងទេ? ឬក៏មានអ្នករស់រានមានជីវិតផ្សេងទៀតដែរ?

[១៥:៤៧:០២]

**ឆ៖** មន្ទីរក្រាំងតាចាន់នេះ មានតាំងពីឆ្នាំ១៩៧២ មកទល់គ្នានឹងថ្ងៃបែក ០៧ មករា ១៩៧៩ រយៈពេលវែងណាស់ ហើយខ្ញុំមានពេលដែលនៅក្នុងមន្ទីរក្រាំងតាចាន់ហ្នឹង តែ២៩ថ្ងៃ។ តើខ្ញុំដឹងថាអ្នកណាខ្លះដែលនៅរស់? ខ្ញុំអត់ដឹងទេ។ និយាយទៅអស់លោកដែលអ្នកស៊ើបសួររកសាក្សីក្រាំងតាចាន់ហ្នឹង

ទេ ដែលស្រាវជ្រាវទៅដឹងថាអ្នករស់ប៉ុន្មាន ស្លាប់ប៉ុន្មាន។

**ស៖** តើលោកមានបានប្រាប់អ្នកផ្សេងទៀតទេថា គាត់ហើយនិងលោកជាមនុស្សតែពីរនាក់គត់ ដែលរស់រានមានជីវិតពីមន្ទីរក្រាំងតាចាន់នោះ? មានបាននិយាយអ៊ីចឹងទេប្រាប់អ្នកដទៃទេ?

**ឆ៖** ខ្ញុំអត់បាននិយាយប្រាប់អ្នកដទៃដែរ។ ក្នុងទីនេះក៏ខ្ញុំនិយាយអ៊ីចឹងដែរ ខ្ញុំអត់ដឹង ខ្ញុំដឹងថា ខ្ញុំមួយរស់ តែប៉ុណ្ណឹងទេ។

**ស៖** តើលោកស្គាល់សៀវភៅមួយក្បាលដែលមានចំណងជើងថា "សង្គ្រាម ហើយនិងប្រល័យពូជសាសន៍ ហើយនិងអំពើហឹង្សាគ្មានទីបញ្ចប់" ដែលសរសេរដោយបុគ្គលម្នាក់បាទ?

**លោក ត្រាវិស ហ្វារ៖**

<លោកប្រធាន សូមជំទាស់។>

**លោក វ៉ិចទ័រ កូប៉េ៖**

<លោកមេធាវី សូមធ្វើការរបស់លោក។>

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយ!

**លោក ត្រាវិស ហ្វារ៖**

បើតាមខ្ញុំដឹង<សំណួរនេះផ្អែកទៅលើឯកសារមួយដែលមិនទាន់បានជូនដំណឹងនៅឡើយទេសម្រាប់សាក្សីនេះ។ សូមកែតម្រូវខ្ញុំ ប្រសិនបើខ្ញុំយល់ខុស។>

**លោក វ៉ិចទ័រ កូប៉េ៖**

<ដូច្នេះ ខ្ញុំឆ្លើយថា សូមលោកមេធាវីធ្វើការលោកចុះ។ ខ្ញុំកំពុងតែសួរសំណួរ។>

**<លោក ត្រាវិស ហ្វារ៖>**

<លោកប្រធាន ចម្លើយនេះមិនអាចទទួលយកបានទេ។ តាមពិតទៅ ឯកសារនេះត្រូវបានជូនដំណឹងរួចហើយ សម្រាប់សាក្សីនេះ ឬមិនទាន់បានជូនដំណឹងនៅឡើយទេ។>

**<សួរដោយលោក វ៉ិចទ័រ កូប៉េ៖>**

<តែវាមិនមានន័យថា មិនមានសៀវភៅនេះនោះទេ>។ អ៊ីចឹង<សាជាថ្មីទៀត សំណួររបស់ខ្ញុំគឺថា តើលោក>ស្គាល់សៀវភៅហ្នឹងឬក៏អត់?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

លោកសាក្សី

តើលោក<ធ្លាប់>បានសរសេរអត្ថបទ<សម្រាប់>ទស្សនាវដ្ដីស្វែងរកការពិត<ដែរឬទេ?>

**លោកត្រាវិស ហ្វារ៖**

<លោកប្រធាន សូមជំទាស់ដែរ។>

[១៥:៤៩:៥០]

**លោក វ៉ិចទ័រ កូប៉េ៖**

<ជាថ្មីម្ដងទៀត ខ្ញុំសួរអំពីអ្វីដែលសាក្សីបានធ្វើ។ ខ្ញុំមិនមែនសំដៅទៅលើ -->

**ប្រធានអង្គជំនុំ៖**

លោកបង្ហាញជំទាស់ឲ្យបានច្បាស់លាស់មើល៍ និយាយឲ្យវាមានមូលហេតុ និយាយឲ្យវាមានភាពឃ្លោងឃ្លាឲ្យច្បាស់លាស់មើល វាយ៉ាងម៉េច? នេះជាសវនាការផ្លូវការ មិនមែនមកជជែកសេរីភាពអីចឹងទេ! អាណាធិបតេយ្យអីចឹងទេណ៎ះ!

**លោក ត្រាវិស ហ្វារ៖**

បើតាមខ្ញុំយល់ពីវិធាននោះដែលទាក់ទងការសួរសាក្សីនោះ ឯកសារ -- សំណួរទាំងអស់ដែលទាក់ទងនឹងឯកសារត្រូវតែជូនដំណឹងដល់ភាគី ហើយបើៗសិនជាចោទសំណួរមិនមានមូលដ្ឋានទាក់ទងនឹងឯកសារហ្នឹងទេ គឺមិនអាចទៅទាក់ --មិនអាចទៅសួរបានទេ ហើយឯកសារនេះអត់មានបានដាក់ជូនដំណឹងទេ។ អីចឹងសំណួរនេះមិនអាចចោទសួរបានទេ។

[១៥:៥១:០២]

**លោក វ៉ិចទ័រ កូប៉េ៖**

<ជាថ្មីម្ដងទៀត លោកប្រធាន ខ្ញុំមិនមែនសំដៅទៅឯកសារទេ។ ខ្ញុំកំពុងតែសួរសំណួរថាតើសាក្សីរូបនេះបានសរសេរអ្វី។ ខ្ញុំដឹងថាលោកមិនចង់បានដូច្នេះទេ ប៉ុន្តែនេះជាភារកិច្ចរបស់ខ្ញុំក្នុងការសួរយ៉ាងដូច្នេះ ក៏ដូចជាភារកិច្ចរបស់លោកដែរ។>

**ប្រធានអង្គជំនុំ៖**

លោកអត្ថបទអីគេ លោកអាចយកឱ្យដាក់ចំណាងជើងអីច្បាស់លាស់ទេ ហើយមានមូលដ្ឋានអីដែលនាំលោក អង្គហេតុណាដែលលោកឱ្យបានឃើញនូវសៀវភៅដែលតែងនិពន្ធដោយសាក្សីរូបនេះដែលលោកមានតាំងសំណួរនេះ។ លោក កូប៉េ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនទាន់<ឈានដល់ចំណុចនោះទេ។ ជាដំបូង ខ្ញុំគ្រាន់តែចង់សួរឱ្យសាក្សីឆ្លើយសំណួរទូទៅមួយថាតើគាត់ធ្លាប់បានសរសេរអ្វីទេ ទោះជាសរសេរជាជំពូកក្នុងសៀវភៅមួយ ឬក៏ក្នុង>ទស្សនាវដ្ដីស្វែងរកការពិត<។ ខ្ញុំចង់សួរតែប៉ុណ្ណឹងទេ។> ខ្ញុំមិន<មែន>បង្ហាញឯកសារទៅគាត់ទេ<។ សំណួររបស់ខ្ញុំមានតែប៉ុណ្ណឹង ហើយខ្ញុំគិតថាខ្ញុំមានសិទ្ធិពេញលេញក្នុងការសួរសំណួរនេះ មិនសំខាន់ថាតើលោកចង់ឱ្យខ្ញុំសួរដូច្នេះ ឬមិនចង់ឱ្យសួរនោះទេ។>

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥២:៤០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក កូប៉េ ព្រោះភាសាបកប្រែហ្នឹងគឺវាមិនបានល្អដូចលោកសួរអីចឹងទេ។ វាអត់ច្បាស់លាស់ ឥឡូវបើថាលោកច្បាស់លាស់ហើយ លោកសួរបើកអីចឹងគឺយើងអនុញ្ញាតឱ្យសួរ ប៉ុន្តែសូមរំឭកលោកថា សូមលោកប្រព្រឹត្ត និងធ្វើអាកប្បកិរិយាឱ្យបានសមស្របថ្លៃថ្នូរតាមវិជ្ជាជីវៈមេធាវីដំណើរការនៅសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** <លោកប្រធាន ខ្ញុំនឹងសម្រួលសំណួរបន្តិច។> នៅត្រីមាសទី១ <នៃ>ឆ្នាំ២០១៣ លោកបានសរសេរអត្ថបទមួយនៅក្នុងទស្សនាវដ្ដី<“>ស្វែងរកការពិត<”>ទាក់ទងទៅនឹងបទពិសោធន៍របស់លោកនៅក្នុងរបប<កម្ពុជាប្រជាធិបតេយ្យ>។ អីចឹងមែនទេ?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** ខ្ញុំអត់បានសរសេរអត្ថបទអ្វីក្នុងសៀវភៅណានោះទេ។

**ស៖** តើលោកច្បាស់ទេលោកសាក្សី?

**ឆ៖** ច្បាស់ហើយ។

**ស៖** លោកសាក្សី អ្នកណាឈ្មោះ -- ប៉ែន សុវណ្ណ នោះជាអ្នកណា?

**ឆ៖** ខ្ញុំមានដែលទៅស្គាល់អីលោក ប៉ែន សុវណ្ណ ឃើញតែមុខតាមរូបថត ទូរទស្សន៍ អ៊ីចឹង។ ពិតមែនតែមនុស្សនៅស្រុកជាមួយគ្នា ប៉ុន្តែខ្ញុំមិនដែលស្គាល់គេទេ។

**ស៖** ដូច្នេះ លោក ប៉ែន សុវណ្ណ មិនដែលជួយលោកទេ នៅពេលដែលគេលោកមានការព្រួយបារម្ភថាខ្លាចគេចាប់ខ្លួននៅឆ្នាំ១៩៧៩នោះ មែនទេ?

[១៥:៥៥:១៦]

**ប្រធានអង្គជំនុំ៖**

មិនចាំបាច់ឆ្លើយតបទេលោកសាក្សី ព្រោះលោកសាក្សីឆ្លើយច្បាស់ហើយថា ខ្លួនមិនដែលស្គាល់ប្រាស្រ័យទាក់ទងជាមួយលោក ប៉ែន សុវណ្ណ នោះទេ។ លោកមេធាវីអស់សំណួរហើយ លោក វ៉ិចទ័រ កូប៉េ។

សូមអញ្ជើញលោក គង់ សំអុន!

លោកអស់សំណួរឬនៅ? សំណួរដូចជាកាន់តែឆ្ងាយទៅ ដូចជាអត់មានអីមានប្រយោជន៍ដល់ការស្វែងរកការពិតទល់តែសោះ សំណួរចុងក្រោយប៉ុន្មាននេះ។ សូមអញ្ជើញលោក គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន សូមគោរពអង្គជំនុំជម្រះ។ សូមជម្រាបសួរលោកសាក្សី។

ខ្ញុំ -- លោកប្រធាន មុននឹងខ្ញុំបាទតាំងសំណួរ ខ្ញុំបាទសូមអនុញ្ញាតពីការប្រើប្រាស់ឯកសារ D118/24 ដែលជាឯកសារមួយដាក់ដោយការិយាល័យសហព្រះរាជអាជ្ញា ហើយដោយសារតែចម្លើយខ្ញុំយល់ពីលក្ខខណ្ឌមួយចំនួននៃការប្រើប្រាស់ឯកសារនេះ ក៏ប៉ុន្តែដោយសារបុគ្គលដែលត្រូវឆ្លើយជាមនុស្សតែម្នាក់។ អ៊ីចឹង ខ្ញុំសូមលោកប្រធានអនុញ្ញាតដើម្បីឲ្យបានផ្តល់ជូនទៅសាក្សីពិនិត្យ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវីយកទៅជូនសាក្សីពិនិត្យ។

[១៥:៥៦:៥០]

**លោក គង់ សំអុន៖**

បាទ លោកប្រធានសូមអធ្យាស្រ័យដោយសារតែនៅក្នុងលក្ខខណ្ឌមិនអនុញ្ញាតឲ្យខាងយើងធ្វើ

ហ្វតូកូពីថតចម្លងទេ។ ដូច្នេះ សូមអនុញ្ញាតពីខាងសហព្រះរាជអាជ្ញាអាចជួយព្រីនឯកសារនេះ ឲ្យបានមួយច្បាប់ផង។

**ប្រធានអង្គជំនុំ៖**

មានទេ ខាងសហព្រះរាជអាជ្ញាមានៗទេ? ឯកសារ E -- D118/24?

**លោក ត្រាវិច ហ្វារ៖**

បាទ ខ្ញុំមានតែមួយច្បាប់ទេ ហើយខ្ញុំមានត្រឹមចំណារជាច្រើនដែរ។

**លោក ឌេល លីសាក់៖**

ឯកសារនេះបានដាក់សំណុំរឿងដែរ តែឯកសារ E3/19.1.5 ហើយខ្ញុំមិនដឹងថាមានបញ្ហាអ្វីកើតឡើងដែរទេ។

[១៥:៥៨:០៥]

**លោក គង់ សំអុន៖**

បាទ សូមអធ្យាស្រ័យ ខ្ញុំឆ្លើយតបទៅនឹងតំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងឯកសារដែលលោកតំណាងសហព្រះរាជអាជ្ញាលើកអំម្បាញ់មិញនេះ។ គឺ E319.1.5 ហើយឯកសារនេះ ខាងយើងចុកបើកទៅវាអត់បាន អត់ចេញទេ។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ឥឡូវមានទេសហព្រះរាជអាជ្ញាមានទេ?

**កញ្ញា សុង ឆវ័ន្ត៖**

ចាស លោកប្រធានយើងមានសូមប្រគល់ជូនឯកសារ E319.1.5 ទៅដល់សាក្សី។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការយកទៅជូនសាក្សីពិនិត្យ។

[១៥:៥៨:០៥]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទសូមលោកសាក្សីពិនិត្យមើលនៅទំព័រទី៤ ទំព័រចុងក្រោយដែលមានស្នាមមេដៃ ហើយមានដាក់ឈ្មោះថា កែវ ច័ន្ទតារ៉ា។ តើនេះជាឈ្មោះរបស់លោកមែនទេ? ប្រហែលជាស្នាមមេដៃរបស់លោកដែរឬទេ?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បាទ អាហ្នឹងជាមេដៃខ្ញុំហើយ។ ហើយការសរសេរឈ្មោះនេះទៀត ក៏ខ្ញុំដែរ។

**ស៖** បាទ សូមអរគុណ។ ដើម្បីជាកំណត់ហេតុ ខ្ញុំបាទសូមបញ្ជាក់ថាឯកសារនេះ មានឈ្មោះ D118/24 ហើយដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានធ្វើកំណត់ហេតុពីឆ្នាំ២០១៣ ខែកុម្ភៈ ថ្ងៃទី២០ បាទ នៅវេលាម៉ោងដប់និងប្រាំនាទីព្រឹក នៅភូមិមហាសេនា ឃុំតាអោម ស្រុកត្រាំកក់ ខេត្តតាកែវ។ អ៊ីចឹងលោកទទួលស្គាល់ថា នេះជាឯកសារដែលលោកបានឆ្លើយចំពោះការិយាល័យសហចៅក្រមស៊ើបអង្កេតមែនទេ?

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយតប!

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បាទ ឯកសារនេះគឺខ្ញុំបានចុះហត្ថលេខាពិតប្រាកដហើយ។

**ស៖** បាទ សូមលោកបញ្ជាក់សាថ្មី ដោយសារអំមិញលោកឆ្លើយថា ហត្ថលេខា ប៉ុន្តែតាមពិតជាស្នាមមេដៃ។

**ឆ៖** បាទ នេះស្នាមមេដៃខ្ញុំហើយ។

**ស៖** លោកបានអាន ឬក៏មានការអានឲ្យស្តាប់ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៅក្នុងឯកសារនេះទេ មុនពេលដែលលោកផ្តិតមេដៃ?

[១៦:០១:៣៨]

**ឆ៖** បាទ មានពេលខ្លះដែលលោកអានទៅដោយការប្រញាប់ទៅ ខ្ញុំក៏បានទទួល -- អ្វីខ្លះដែលអាចទៅច្បាស់លាស់ ខ្ញុំក៏ទទួលស្គាល់។ អ្វីខ្លះដែលមិនច្បាស់លាស់ ខ្ញុំក៏អត់ទទួលស្គាល់ទាំងស្រុងដែរនៅក្នុងឯកសារនេះ។ បាទ សូម--

**ស៖** បាទ សូមអរគុណ។ ឥឡូវសូមលោកពិនិត្យទៅលើសំណួរចម្លើយទី១៧ នៅក្នុងទំព័រទី៤នៃឯកសារនៅលើដៃលោក។ លោកឃើញ ឆ១៧ទេ នៅក្នុងទំព័រទី៤? បាទ ខ្ញុំសូមសួរ។ សំណួរ “ស៖ តើលោកបានដឹងពីការធ្វើបាបពួកខ្មែរក្រោមដែរឬទេ?” ឆ្លើយ, ឆ-១៧, ខ្ញុំសូមអាន៖ “ខ្ញុំមិនបានដឹងទេ ខ្ញុំគ្រាន់តែឮគេនិយាយថា ទ័ពខ្មែរក្រហមវាយយកទឹកដីកម្ពុជាក្រោមមកវិញ។ ខ្ញុំជាប់នៅក្រាំងតាចាន់ ៥ –ប្រាំពីរដង មានលេខប្រាំ និង អក្សរប្រាំ, បាទ សូមអធ្យាស្រ័យ– នៅចុងឆ្នាំ១៩៧៤ ហើយជាប់២៤ថ្ងៃ

ទៀតនៅឆ្នាំ១៩៧៥។ ក្រោយមកគេដោះលែងខ្ញុំវិញ គេឲ្យខ្ញុំធ្វើការជាជាងម៉ាស៊ីន"។ ខ្ញុំសូមឲ្យលោកបញ្ជាក់ថា តើការដែលលោកជាប់ឃុំនៅក្រាំងតាចាន់ គឺនៅចុងឆ្នាំ១៩៧៤ ឬមួយ -- និងដើមឆ្នាំ១៩៧៥ ឬក៏ជាចម្លើយផ្សេងដូចដែលបាន -- លោកបានឆ្លើយអម្បាញ់មិញមុននេះថា លោកជាប់នៅក្នុងខែ៣ និងខែ៤ ឆ្នាំ១៩៧៥នោះ?

[១៦:០៣:៤១]

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

លោកកុំអាល់ទាន់ឆ្លើយ!

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** ឯកសារនេះនិយាយមិនបានច្បាស់លាស់ត្រង់ថា ជាប់នៅក្នុងឆ្នាំ១៩៧៤ គឺក្នុងឆ្នាំ១៩៧៥ ខែមីនា ចុងឆ្នាំខែមីនា និងដើមឆ្នាំខែមេសា។ បាទ អាហ្នឹងប្រាកដ។ តែត្រង់នេះដូចជាអត់ទាន់ត្រូវទេ ដូចជា១៩៧៤នេះ។ ព្រោះខ្ញុំជាប់ពាក់កណ្ដាល ពេលជិតបែកខែមេសាហ្នឹង ហើយនិងឆ្លងចូលដល់ដែលបែកហើយ ខែមេសាហ្នឹងដែរ ក្នុងខែពីរហ្នឹងពាក់កណ្ដាលខែម្នាក់ គឺបាន២៩ថ្ងៃ។ ហ្នឹងសូមជ្រាបអីចឹង។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីភាពខុសគ្នាទាំងពីរនេះបានទេថា នៅក្នុងឯកសារនេះលោកបញ្ជាក់ពីឆ្នាំពីរ គឺឆ្នាំ១៩៧៤ និងឆ្នាំ១៩៧៥ គឺច្បាស់ណាស់ ហើយចំនួនថ្ងៃ២៩ថ្ងៃដែលលោកជាប់ឃុំ គឺមានចំនួននៅដដែល ស្មើដូចគ្នា ក៏ប៉ុន្តែឥឡូវនេះលោកបានបញ្ជាក់អំពីខែពីរវិញ គឺខែមីនា និងខែមេសា។ លោកអាចបញ្ជាក់បានទេថា ភាពខុសគ្នានេះវាកើតឡើងដោយសារអ្វីដែរ?

**ឆ៖** ក្នុងខែទាំងពីរនេះ ដែរខុសគ្នាមកអំពីខ្ញុំគិតថាទៅខុសថា ខ្ញុំមិនបានដឹងថាការជាប់ហ្នឹង ២៩ថ្ងៃ ប៉ុន្តែមិនដឹងនៅថាក្នុងខែណា និងខែណា។ ខ្ញុំសម្រេចគិតមើលទៅ ហើយសួរប្រពន្ធកូនដែលប្រាប់មក គឺថាខ្ញុំចាកចេញពីទៅនៅក្រាំងតាចាន់ហ្នឹងគឺក្នុងឆ្នាំដែលគេបែកភ្នំពេញហើយ ប៉ុន្តែមុនបែកភ្នំពេញហ្នឹងជាង១០ថ្ងៃ និងក្រោយបែកភ្នំពេញហ្នឹងជាង១០ថ្ងៃ បាទក្នុងឆ្នាំ១៩៧៥ដែរ ក្នុងខែមីនា គឺចុងខែ ហើយខែមេសា គឺដើមខែទាន។ បូកសរុបទៅ២៩ថ្ងៃហ្នឹង។ ហើយបូកទាំង៥ថ្ងៃនៅក្របីថ្ងៃផងដែរ។ ប៉ុណ្ណឹងថ្ងៃដែលខ្ញុំត្រូវជាប់ពិរុទ្ធនៅក្នុងឃុំឃាំងរបស់បនប្រល័យពូជសាសន៍ហ្នឹងទាន។

**ស៖** បាទសូមអរគុណ។ លោកអម្បាញ់មិញ ខ្ញុំស្ដាប់បានថា រយៈពេល--

**ប្រធានអង្គជំនុំ៖**

លោកមេធាវី នៅសំណួរច្រើនទេ លោកមេធាវី?

**លោក គង់ សំអុន៖**

បាទលោកប្រធាន យើងនៅមានសំណួរច្រើនទៀត។

**ប្រធានអង្គជំនុំ៖**

លោកសាក្សី នៅថ្ងៃខានស្អែក តើលោកអាចអញ្ជើញមកផ្ដល់បន្តផ្ដល់សក្ខីកម្មបញ្ចប់បានដែរឬទេ?

**លោក កែវ ច័ន្ទតារ៉ា៖**

បាទ ខ្ញុំមិនទាន់សន្និដ្ឋានបានទាន ព្រោះថាខ្ញុំមួយថ្ងៃកាត់ មួយថ្ងៃកោបច្ចុប្បន្ននេះ។ ហើយអង្គុយយូរទៅស្ពឹកជើងម្ខាង បើដើរ ហើយនិងឈរ គឺអត់បានទាល់តែសោះ។ ថ្ងៃខាងមុខទៀតមិនដឹងយ៉ាងណាទាន សុខភាពខ្ញុំមិនអាចជម្រាបលោកបានទេ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ លោកនៅមានត្រូវផ្ដល់សក្ខីកម្មហ្នឹងមួយពេលទៀត ប្រហែលជាមួយម៉ោងៗទៀតចប់ហើយ។ នេះជាពេលវេលាសម្រាប់មេធាវីការពារក្ដី។ ហើយដោយសារបញ្ហានោះគឺមិនទាន់យើងព្យាករបានទេបញ្ហាហ្នឹង លើកលែងតែមានធុរៈផ្សេងទៀត ដែលមានមូលហេតុដែលចាំបាច់ នោះគឺយើងមិនទាន់ព្យាករបានទេ។ ដូច្នេះអង្គជំនុំជម្រះសន្មតថាលោកមានសុខភាពល្អ ហើយនិងមកផ្ដល់សក្ខីកម្មបន្តសក្ខីកម្មបញ្ចប់នៅក្នុងនៅថ្ងៃពុធៗទៀតណ៎ា។ ខានស្អែកណ៎ា។

អង្គជំនុំជម្រះជម្រះសូមអរគុណលោក កែវ ច័ន្ទតារ៉ា ហើយដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឱ្យមកបន្តផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃពុធ ទី០៤ ខែកុម្ភៈ ឆ្នាំ២០០១៥ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយលោកអាចវិលត្រឡប់ទៅកាន់ទីកន្លែងដែលលោកស្នាក់នៅវិញបានហើយ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនលោក កែវ ច័ន្ទតារ៉ា វិលត្រឡប់ទៅកាន់កន្លែងស្នាក់ ដែលគាត់ស្នាក់នៅវិញចុះ ហើយឱ្យអញ្ជើញគាត់មកចូលរួមសវនាការនៅបន្ទប់សវនាការនេះវិញនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១០១៥ ឱ្យបានមុនម៉ោងប្រាំបួនព្រឹក។

ហើយអង្គជំនុំជម្រះសូមជម្រាបជូនថា សវនាការនៅរសៀលនេះ គឺប្រកាសកិច្ចដំណើរការសវនាការត្រឹមនេះ ហើយសវនាការលើកបន្តធ្វើនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥ ខានស្អែកនេះ ចាប់ផ្ដើម

ពីម៉ោងប្រាំមួយព្រឹកដូចសព្វដង ដោយនៅថ្ងៃស្អែក អ៎! នៅថ្ងៃពុធនោះ អង្គជំនុំជម្រះនឹងក្រៅពីស្តាប់សក្ខីកម្មសាក្សី កែវ ច័ន្ទតារ៉ា ចប់ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271។ សូមភាគីជ្រាប។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងបង្គាប់ឱ្យនាំខ្លួនគាត់ទាំងពីរនាក់មកចូលរួមសវនាការនេះវិញនៅថ្ងៃពុធទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥ឱ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១០ នាទី)*